ក្រសួងសុខាភិបាល

មជ្ឈមណ្ឌលជាតិប្រយុទ្ធនឹងជម្ងឺអេដស៍ សើស្បែក និង កាមរោគ

## ឯកសារបណ្តុះបណ្តាល

# ការគ្រប់គ្រងកម្មវិធីប្រយុទ្ធនឹងជម្ងឺកាមរោគ




Family Health International

អង្គការសុខភាពគ្រួសារអន្តរជាតិ

USAID

UNITED STATES AGENCY FOR INTERNATIONAL DEVELOPMENT

## ម៉ូឌុលទី ១

# គោលបំណង និង កម្មវត្ថុ
# នៃកម្មវិធីប្រយុទ្ធនឹងជំងឺការរោគ

### 1-1. បញ្ហាក្នុងការបង្ការ និងថែទាំព្យាបាលជំងឺកាមរោគ

ជំងឺកាមរោគជាមូលហេតុបង្កឱ្យមានជំងឺផ្សេងៗ ហើយថែមទាំងអាចនាំទៅរកសេចក្តីស្លាប់ ផងដែរ ។ វាបណ្តាលឱ្យបុគ្គលម្នាក់ៗមានការឈឺចាប់ដោយសារការប៉ះពាល់ដល់សម្ព័ន្ធមេត្រីភាពរវាងដៃគូ ឬដោយសារផលវិបាកយូរអង្វែងរបស់វា ជាពិសេសគឺ ភាពគ្មានសមត្ថភាពបន្តពូជ ។

ជំងឺអេដស៍ គឺជាជំងឺដែលឆ្លងភាគច្រើនតាមរយៈការរួមភេទ ហើយវិធានការបង្ការទប់ស្កាត់ការរីករាលដាលនៃជំងឺកាមរោគនឹងអាចបង្ការទប់ស្កាត់ការរីករាលដាលនៃ មេរោគអេដស៍ បានដូចគ្នា ។

ជាការពិតណាស់ដែលថា ជំងឺកាមរោគនឹងបង្កើននូវការប្រឈមមុខនឹងការចំលងមេរោគអេដស៍ ហើយការព្យាបាលជំងឺកាមរោគទាំងនោះអាចកាត់បន្ថយការប្រឈមមុខនឹងការចំលងមេរោគអេដស៍បាន។

ជំងឺកាមរោគជាជំងឺដែលងាយស្រួលក្នុងការបង្ការ ហើយភាគច្រើននៃជំងឺនេះអាចព្យាបាលជាសះស្បើយបាន ។ ទោះបីជាដូច្នេះក៏ដោយ ក៏ជំងឺកាមរោគនៅតែកើតមានច្រើនឡើងនៅលើពិភពលោកទាំងមូល។

- ហេតុអ្វីបានជាជំងឺកាមរោគនៅតែកើតមានច្រើនយ៉ាងដូច្នេះ ?
- ហេតុអ្វីបានជាយើងមានការលំបាកក្នុងការទប់ស្កាត់ការរីករាលដាលនៃជំងឺកាមរោគ ?
- តើអ្វីដែលជាបញ្ហា ?

រូបភាពខាងក្រោមនឹងបង្ហាញពីមូលហេតុទាំងឡាយនៃបញ្ហាទាំងអស់នេះ។ រូបភាពទាំងនេះក៏បានបង្ហាញផងដែរ អំពីហេតុផលដែលគេត្រូវតែបញ្ចូលការថែទាំវេជ្ជសាស្ត្រ និងការលើកកំពស់សុខភាព ទៅក្នុងកម្មវិធី ថែទាំសុខភាព ផ្សេងៗទៀត ។

## ដំណាក់កាលទី១

### *មនុស្សម្នាក់ៗដែលមាន (ឬនឹងចាប់ផ្តើមមាន) សកម្មភាពផ្លូវភេទ*

មនុស្សគ្រប់រូបដែលមានសកម្មភាពផ្លូវភេទ ឬនឹងចាប់ផ្តើមមានសកម្មភាពផ្លូវភេទ ចាំបាច់ត្រូវយល់ដឹងអំពីជំងឺកាមរោគ និងអំពីវិធីការពារជំងឺនេះ ។ គេត្រូវយល់ដឹងផងដែរ អំពីសារៈសំខាន់ក្នុងការស្វែងរកការព្យាបាល និងការស្គាល់ពីទីកន្លែងដែលត្រូវទៅព្យាបាល ប្រសិនបើគេគិតថា គេនឹងអាចកើតជំងឺកាមរោគ ។ ដូច្នេះមនុស្សម្នាក់ៗត្រូវការនូវព័ត៌មាន និងការអប់រំស្តីអំពីជំងឺនេះ ។

**ជំណាក់កាលទី១**

ចំនួនសរុបនៃមនុស្សពេញវ័យ

| | |
|---|---|
|  ជំងឺកាមរោគដែលយើងបង្ការបាន |  កើតជំងឺកាមរោគ |

**ជំណាក់កាលទី២**

***អ្នកដែលកើតជំងឺកាមរោគ***

មនុស្សជាច្រើនដែលកើតជំងឺកាមរោគ នឹងមានលេចចេញជារោគសញ្ញា ក៏ប៉ុន្តែមានជំងឺកាមរោគ ជាច្រើន (ពិសេស គឺកាមរោគដែលកើតលើស្ត្រី) មានរោគសញ្ញាតែបន្តិចបន្តួចប៉ុណ្ណោះ ឬ ក៏គ្មានរោគសញ្ញាសោះតែម្តង។ ដូច្នេះមនុស្សគ្រប់រូបត្រូវការនូវពត៌មាន និងការអប់រំ ដើម្បីឱ្យពួកគេ ៖

- ដឹងថា ពួកគេប្រហែលជាអាចកើតជំងឺកាមរោគ
- អាចស្គាល់នូវរោគសញ្ញានានារបស់ជំងឺកាមរោគ
- យល់ថា ពួកគេត្រូវតែស្វែងរកការព្យាបាលសមស្រប
- ស្គាល់ពីទីកន្លែងដែលពួកគេត្រូវទៅទទួលយកការព្យាបាល

នៅពេលមនុស្សបារម្ភថា ពួកគេប្រហែលជាកើតជំងឺកាមរោគដោយសារតែការប្រព្រឹត្តរបស់គេ ឬដោយសារការប្រព្រឹត្តនៃដៃគូរបស់គេ ជាការសំខាន់ណាស់ដែលពួកគេត្រូវតែទទួលបាននូវការថែទាំព្យាបាលដែលមានប្រសិទ្ធិភាព ដោយងាយស្រួលនិងយ៉ាងឆាប់រហ័ស ។ នៅក្នុងករណីភាគច្រើន អ្នកគ្រប់គ្រងកម្មវិធីចាំបាច់ ត្រូវធ្វើឱ្យកាន់តែប្រសើរឡើងនូវគ្លីនិកដែលផ្តល់សេវាថែទាំកាមរោគ ដើម្បីសំរេចបាននូវកិច្ចការនេះ។

អ្វីដែលសំខាន់បំផុតនោះ គឺ មនុស្សគ្រប់រូបត្រូវដឹងថា គេអាចកើតជំងឺកាមរោគតែពុំមានលេចចេញជារោគសញ្ញាឡើយ ។

## ដំណាក់កាលទី២

| ដំណាក់កាលទី១<br>ចំនួនសរុបនៃមនុស្សពេញវ័យ | ចំនួនមនុស្សដែលកើតកាមរោគ | |
|---|---|---|
| | <br>ពុំមានរោគសញ្ញា | <br>មានរោគសញ្ញា |
| <br>ជំងឺកាមរោគដែលយើងបង្ការបាន | <br>កើតជំងឺកាមរោគ | |

## ដំណាក់កាលទី៣

### *អ្នកដែលដឹងថា គេប្រហែលជាកើតជំងឺកាមរោគ*

មានមនុស្សជាច្រើនដែលគិតថា ពួកគេប្រហែលជាកើតជំងឺកាមរោគ ដោយសារតែពួកគេមានរោគសញ្ញាកាមរោគ ឬដោយសារតែការប្រព្រឹត្តរួមភេទរបស់គេប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលងជំងឺនេះ ក៏ប៉ុន្តែ ពួកគេមិនបានទៅស្វែងរកការព្យាបាលឱ្យបានសមស្របទេ ។

បញ្ហានេះអាចបណ្តាលមកពី :

- ការអៀនខ្មាស
- ពួកគេចូលចិត្តរង់ចាំដោយសង្ឃឹមថា ជំងឺកាមរោគនឹងជាសះស្បើយដោយឯកឯង
- ពួកគេមិនមានលទ្ធភាពបង់ថ្លៃព្យាបាល
- ពួកគេពុំអាចស្វែងរកគ្លីនិកដែលផ្តល់សេវាថែទាំព្យាបាលជំងឺកាមរោគបាន
- ពួកគេប្រហែលជាធ្លាប់ទៅព្យាបាលនៅគ្លីនិកដែលពុំមានបទពិសោធន៍ល្អក្នុងការព្យាបាល ឬ គ្លីនិកដែលមានកេរ្តិ៍ឈ្មោះមិនសូវល្អ ។

អ្នកខ្លះសំរេចចិត្តថានឹងស្វែងរកការព្យាបាល ក្នុងនោះមានមួយចំនួនតូចប៉ុណ្ណោះដែលទៅទទួលការព្យាបាលនៅតាមគ្លីនិកកាមរោគ អ្នកខ្លះទៀតនឹងទៅរកគ្រូពេទ្យឯកជនដើម្បីទទួលការព្យាបាល ។ ក៏ប៉ុន្តែ អ្នកជំងឺភាគច្រើនចូលចិត្តទៅរក "អ្នកថែទាំព្យាបាលដែលគ្មានការបណ្តុះបណ្តាលត្រឹមត្រូវ" (informal carers) ដូចជា អ្នកលក់ថ្នាំពេទ្យ ឬ គ្រូឱសថបុរាណជាដើម ។

**ដំណាក់កាលទី៣**




**ដំណាក់កាលទី៤**

***អ្នកដែលទទួលការព្យាបាលជំងឺកាមរោគ***

នៅពេលអ្នកជំងឺមកទទួលការព្យាបាល ពួកគេមិនមែនសុទ្ធតែបានទទួលនូវការព្យាបាលដ៏មានប្រសិទ្ធិភាពគ្រប់ពេលនោះទេ ។ មានអ្នកជំងឺតិចតួចប៉ុណ្ណោះដែលបានទទួលនូវការព្យាបាលដែលប្រកបដោយប្រសិទ្ធិភាព ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានអ្នកជំងឺជាច្រើនដែលមិនបានទទួលនូវការព្យាបាលសោះ ឬក៏បានទទួលការព្យាបាលដែរ តែមិនបានសមស្រប ។ ជាញឹកញាប់ បញ្ហានេះច្រើនតែបណ្តាលមកពីការធ្វើរោគវិនិច្ឆ័យខុស ការព្យាបាលមិនត្រឹមត្រូវ ឬ មួយក៏អ្នកជំងឺមិនបានប្រើប្រាស់ឱសថឱ្យបានត្រឹមត្រូវតាមវេជ្ជបញ្ជា ។




អ្នកថែទាំសុខភាពភាគច្រើនយល់ឃើញថា “ការព្យាបាលត្រឹមត្រូវ” មានន័យថា ជាការធ្វើរោគវិនិច្ឆ័យបានត្រឹមត្រូវ និងផ្តល់ការព្យាបាលប្រកបដោយប្រសិទ្ធិភាព ។ ប៉ុន្តែនេះគ្រាន់តែជាផ្នែកមួយនៃការថែទាំព្យាបាលអ្នកជំងឺកាមរោគតែប៉ុណ្ណោះ ។

ការថែទាំព្យាបាលកាមរោគដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ មិនមែនគ្រាន់តែផ្តល់ការព្យាបាលដោយឱសថល្អៗតែប៉ុណ្ណោះទេ ។ គេត្រូវបញ្ចូលផងដែរនូវការអប់រំ និងការផ្តល់ពត៌មានស្តីអំពី :

- របៀបបង្ការកុំអោយឆ្លងទៅអ្នកដទៃទៀត
- ការចៀសវាងការឆ្លងជំងឺក្នុងពេលអនាគត
- ការបញ្ជូនដៃគូឱ្យមកទទួលការព្យាបាល
- ការប្រើប្រាស់ស្រោមអនាម័យ

ប្រសិនបើគ្មានការផ្តល់ព័ត៌មាននិងអប់រំបន្ថែមទេនោះ ការផ្តល់សេវាថែទាំកាមរោគអាចទប់ស្កាត់ ការរីករាលដាលជំងឺកាមរោគបាន ក្នុងកំរិតមួយយ៉ាងទាប ។

អ្នកគ្រប់គ្រងកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគទាំងអស់ គួរតែផ្តល់អាទិភាពទៅលើការពង្រីកសេវាថែទាំព្យាបាលជំងឺកាមរោគ និងធ្វើឱ្យសេវាទាំងនេះឱ្យមានដំណើរការកាន់តែប្រសើរឡើង ដើម្បីឱ្យការផ្តល់ការថែទាំព្យាបាលជំងឺកាមរោគមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

**សង្ខេប**

ដើម្បីឱ្យការបង្ការជំងឺកាមរោគមានប្រសិទ្ធិភាពខ្ពស់ កម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគត្រូវ :

❖ ជួយឱ្យមនុស្សចៀសផុតពីការឆ្លងជំងឺកាមរោគតាមរយៈ ការលើកកំពស់សុខភាព ការចែកចាយ និងការជំរុញការប្រើប្រាស់ស្រោមអនាម័យ ។

❖ ធានាយ៉ាងណាឱ្យអ្នកដែលគិតថា ខ្លួនគេប្រហែលជាកើតជំងឺកាមរោគ អាចស្វែងរកគ្លីនិកដែលផ្តល់សេវាថែទាំព្យាបាលកាមរោគបានដោយងាយស្រួល ។

❖ ធានាយ៉ាងណាឱ្យគ្លីនិកកាមរោគ :

- មានលក្ខណៈទាក់ទាញចិត្តអ្នកជំងឺបាន
- អាចធ្វើរោគវិនិច្ឆ័យជំងឺកាមរោគនិងផ្តល់ឱសថ ត្រឹមត្រូវ ជូនអ្នកជំងឺក្នុងតំលៃមួយសមស្រប
- អាចជួយអ្នកជំងឺអោយជំរុញដៃគូរបស់គាត់មកទទួលការព្យាបាល
- អាចផ្តល់ស្រោមអនាម័យក្នុងតំលៃថោក និងមានគុណភាពដែលទទួលស្គាល់ជាអន្តរជាតិ ។

❖ បញ្ចូលកម្មវិធីបណ្តុះបណ្តាលអ្នកថែទាំសុខភាព ដោយមិនគ្រាន់បង្រៀនអោយចេះត្រឹមតែធ្វើរោគវិនិច្ឆ័យនិងព្យាបាលជំងឺកាមរោគប៉ុណ្ណោះទេ ប៉ុន្តែត្រូវផ្តល់ឱ្យគេផងដែរនូវជំនាញក្នុងការអប់រំអ្នកជំងឺអំពីសុខភាពផ្លូវភេទ និងជំងឺកាមរោគ ។

វគ្គសិក្សានេះផ្តោតទៅលើ វិធីដែលធ្វើឱ្យការថែទាំអ្នកជំងឺកាមរោគកាន់តែប្រសើរឡើង និងធ្វើយ៉ាងណា ឱ្យអ្នកដែលកើត ឬអ្នកដែលគិតថាគេកើតជំងឺកាមរោគ អាចទៅទទួលការផ្តល់សេវាថែទាំជំងឺកាមរោគបានដោយងាយស្រួល ។

ការថែទាំជំងឺកាមរោគគ្រាន់តែជាផ្នែកមួយនៃកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគតែប៉ុណ្ណោះ ។ មុននឹងលើកយកផ្នែកនេះមកពិចារណា យើងគួរតែគិតអំពីកម្មវត្ថុ និងយុទ្ធសាស្ត្ររបស់កម្មវិធីទាំងមូលសិន ហើយត្រូវគិតថាហេតុអ្វីបានជាការទប់ស្កាត់នូវការរីករាលដាលជំងឺកាមរោគមានការលំបាកយ៉ាងដូច្នេះ ។

## ១.២ - កម្មវត្ថុ និងយុទ្ធសាស្ត្រ នៃកម្មវិធីបង្ការ និងថែទាំជំងឺកាមរោគ

កម្មវត្ថុនៃកម្មវិធីជាតិប្រយុទ្ធនឹងជំងឺកាមរោគ គឺ កាត់បន្ថយចំនួនអ្នកកើតជំងឺកាមរោគ (Prevalence) ហើយនឹង កាត់បន្ថយនូវចំនួនអ្នកកើតជំងឺកាមរោគថ្មី (incidence) នៅក្នុងប្រទេស ។ កម្មវត្ថុនេះអាចសំរេចទៅបានតាមរយៈយុទ្ធសាស្ត្រមួយចំនួន ។ យុទ្ធសាស្ត្រទាំងនោះ រួមមាន :

- ធានាឱ្យអ្នកជំងឺកាមរោគបានទទួលនូវការព្យាបាលដ៏ត្រឹមត្រូវ
- លើកទឹកចិត្តអ្នកដែលគិតថា គេប្រហែលជាកើតជំងឺកាមរោគ ឱ្យស្វែងរកការព្យាបាលដ៏ត្រឹមត្រូវ
- ស្វែងរក និងព្យាបាលអ្នកដែលផ្ទុកជំងឺកាមរោគ ដែលពុំបានដឹងខ្លួនថា កើតជំងឺកាមរោគ
- បង្ការមនុស្សគ្រប់រូបកុំឱ្យមានឆ្លងជំងឺកាមរោគសារជាថ្មីទៀត រួមទាំងការឆ្លងមេរោគអេដស៍ផង

## ១.៣ - ការចាំបាច់ក្នុងការទទួលបាននូវការជួយគាំទ្រពីផ្នែកផ្សេងៗទៀត

ក្រោយពេលដែលកម្មវិធីរបស់អ្នកត្រូវបានបង្កើតឡើងរួចហើយ អ្នកត្រូវធ្វើអោយកម្មវិធីនេះដំណើរការ។ ដើម្បីអនុវត្តនូវការងារទាំងនេះបាន អ្នកត្រូវតែស្វែងរកនូវ ការយោគយល់និងការសហប្រតិបត្តិការ ពីអាជ្ញាធរនិងស្ថាប័នទាំងអស់ដែលបំរើការនៅក្នុងនិងក្រៅវិស័យសុខាភិបាល ហើយដែលបានចូលរួមនៅក្នុងកម្មវិធីនេះ ។

ដូចកម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍ដែរ កម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគចាំបាច់ត្រូវសហការជាមួយនឹងកម្មវិធីផ្សេងៗទៀតដែរ ។ ឧទាហរណ៍ :

- ដើម្បីអប់រំក្រុមយុវជន : យើងត្រូវការនូវការចូលរួមពីស្ថាប័នអប់រំ គ្រូបង្រៀន អ្នកដឹកនាំក្រុម យុវជន (youth leaders) ។ល។
- ការអប់រំអ្នករកស៊ីផ្លូវភេទត្រូវការឱ្យមានកិច្ចសហប្រតិបត្តិការ និងមានការយល់ព្រមពីប៉ូលីស និងពីអ្នកច្បាប់ផ្សេងៗទៀត ។

- ការយោគយល់ និង ការសហការ ពីមេដឹកនាំសាសនានិងអ្នកដឹកនាំសហគមន៍ផ្សេងៗទៀត មានសារៈសំខាន់ណាស់ ប្រសិនបើយើងចង់ឱ្យប្រជាជនទទួលយកកម្មវិធីនេះ និង កាន់តែមានសារៈសំខាន់ពិសេសទៅទៀត ប្រសិនបើយើងចង់ឱ្យវាទទួលបានជោគជ័យ ។

នេះជាហេតុផលមួយដែលយើងត្រូវដាក់ កម្មវិធីបង្ការនិងទប់ស្កាត់ជំងឺកាមរោគ និង កម្មវិធីបង្ការនិងទប់ស្កាត់ជំងឺអេដស៍ នៅក្នុងកម្មវិធីតែមួយ ហើយប្រការដែលប្រសើរបំផុតនោះគឺ ត្រូវចងចាំថា គោលបំណងនៃកម្មវិធីគឺ ទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាមរោគ រួមបញ្ចូលទាំងជំងឺអេដស៍ផង ។

**លំហាត់ ១.២**

## ការពិភាក្សាតាមក្រុម

ចូរបំពេញប្រអប់ដែលបង្ហាញនូវអ្វីដែលកំពុងកើតមានក្នុងខេត្តរបស់អ្នក នៅក្នុងដំណាក់កាលនីមួយៗ ដែលបានបង្ហាញនៅក្នុងរូបភាព ។

បន្ទាប់ពីអ្នកបានបំពេញប្រអប់ទាំងនោះរួចហើយ នឹងមានការពិភាក្សាគ្នាជាទូទៅមួយស្តីអំពី កម្មវត្ថុនៃកម្មវិធីបង្ការនិងទប់ស្កាត់ជំងឺអេដស៍-កាមរោគ និងអំពីអ្វីដែលខេត្តរបស់អ្នកបានធ្វើ ក្នុងគោលបំណងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកាមរោគ ដោយរួមបញ្ចូលទាំងជំងឺអេដស៍ផង ។

**ការអាន**

## កិច្ចការសំរាប់សិក្ខាកាមម្នាក់ៗ

ចូរអានឧបសម្ព័ន្ធទី១ ស្តីពីការសិក្សាស្រាវជ្រាវអំពីការសាកល្បងថ្មីសំរាប់ អន្តរាគមន៍ថែទាំនិងបង្ការជំងឺកាមរោគ ដែលនៅផ្នែកបញ្ចប់នៃម៉ូឌុលនេះ ។

## ១ - *ការធ្វើឱ្យកាន់តែប្រសើរឡើងនូវការព្យាបាលជំងឺកាមរោគចំពោះអ្នកជំងឺដែលមានរោគសញ្ញា*

| | បានធ្វើ | កំពុងធ្វើ | មិនទាន់ធ្វើ |
|---|---|---|---|
| -ការជ្រើសរើសយកការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមកអនុវត្តនៅថ្នាក់មណ្ឌលសុខភាព | ☐ | ☐ | ☐ |
| ***ការធ្វើសមាហរណកម្មសេវាថែទាំកាមរោគ (Integration)*** | | | |
| -ទៅក្នុងមណ្ឌលសុខភាព | ☐ | ☐ | ☐ |
| -ទៅក្នុងសកម្មភាពគាំពារមាតា និងទារក | ☐ | ☐ | ☐ |
| -ទៅក្នុងគ្លីនិកផែនការគ្រួសារ | ☐ | ☐ | ☐ |
| -ទៅក្នុងកិច្ចសហការជាមួយគ្រូពេទ្យឯកជន | ☐ | ☐ | ☐ |
| ***ការបណ្តុះបណ្តាល*** | | | |
| -ការបណ្តុះបណ្តាលគ្រូពេទ្យលើកដំបូងអំពីការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា | ☐ | ☐ | ☐ |
| -ការបណ្តុះបណ្តាលគ្រូពេទ្យ បន្ត (In-service training) អំពីការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា | ☐ | ☐ | ☐ |
| -ការបណ្តុះបណ្តាលគិលានុប្បដ្ឋាក-យិកា / ឆ្មបអំពីការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា | ☐ | ☐ | ☐ |
| -ការបណ្តុះបណ្តាលគិលានុប្បដ្ឋាក-យិកា / ឆ្មបបន្ត អំពីការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា | ☐ | ☐ | ☐ |
| -ការបណ្តុះបណ្តាលអ្នកលក់ថ្នាំពេទ្យ | ☐ | ☐ | ☐ |

**ឱសថសំរាប់ព្យាបាលជំងឺកាមរោគ**

| | | | |
|---|---|---|---|
| -បានបញ្ចូល ឱសថសំរាប់ព្យាបាលជំងឺកាមរោគ ទៅក្នុងបញ្ជីឱសថសារវ័ន្ត | ☐ | ☐ | ☐ |
| -មានឱសថសំរាប់ព្យាបាលជំងឺកាមរោគ ប្រើប្រាស់នៅតាមបណ្តាសេវាកាមរោគសាធារណៈ | ☐ | ☐ | ☐ |
| -មានការតាមដាន ភាពស៊ាំនៃមេរោគហ្គោណូកូក ទៅនឹងថ្នាំអង់ទីប៊ីយូទិច | ☐ | ☐ | ☐ |

***២ - លើកទឹកចិត្តអ្នកដែលគិតថា ខ្លួនកើតជំងឺកាមរោគ ឱ្យមកទទួលការព្យាបាលត្រឹមត្រូវ***

| | | | |
|---|---|---|---|
| -តាមរយៈកម្មវិធីផ្សព្វផ្សាយដោយប្រើប្រព័ន្ធ ពត៌មាន (Mass media) | ☐ | ☐ | ☐ |
| -តាមរយៈសាលារៀន និងកម្មវិធីសំរាប់សំរាប់យុវវ័យ | ☐ | ☐ | ☐ |
| -តាមរយៈការស្វែងរកការគាំទ្រពីអ្នកដឹកនាំ | ☐ | ☐ | ☐ |
| -តាមរយៈកម្មវិធីតាមសហគមន៍ | ☐ | ☐ | ☐ |

***៣ - ការស្រាវជ្រាវរកវត្តមានជំងឺកាមរោគ (រួមទាំងមេរោគអេដស៍) លើអ្នកដែលគ្មានរោគសញ្ញា***

ក)-<u>**កម្មវិធីធ្វើតេស្តស្រាវជ្រាវរកអ្នកផ្ទុកមេរោគ**</u>

<u>**មេរោគ កាមរោគ**</u>

| | | | |
|---|---|---|---|
| -ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ | ☐ | ☐ | ☐ |
| -ក្នុងចំណោមស្រ្តីមានផ្ទៃពោះ | ☐ | ☐ | ☐ |
| -នៅតាមគ្លីនិកផែនការគ្រួសារ | ☐ | ☐ | ☐ |
| -ក្នុងចំណោមក្រុមយុវជនដែលប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ | ☐ | ☐ | ☐ |
| -ក្នុងចំណោមយោធា | ☐ | ☐ | ☐ |
| -ក្នុងចំណោមនគរបាល | ☐ | ☐ | ☐ |
| -ក្នុងចំណោមអ្នកផ្តល់ឈាម | ☐ | ☐ | ☐ |

| | | | |
|---|---|---|---|
| **<u>មេរោគ អេដស៍</u>** | | | |
| -ក្នុងចំណោមអ្នករកស៊ីផ្លូវភេទ | ☐ | ☐ | ☐ |
| -ក្នុងចំណោមស្ត្រីមានផ្ទៃពោះ | ☐ | ☐ | ☐ |
| -នៅតាមគ្លីនិកផែនការគ្រួសារ | ☐ | ☐ | ☐ |
| -ក្នុងចំណោមយោធា | ☐ | ☐ | ☐ |
| -ក្នុងចំណោមនគរបាល | ☐ | ☐ | ☐ |
| -ក្នុងចំណោមអ្នកផ្តល់ឈាម | ☐ | ☐ | ☐ |
| **ខ)-<u>ការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល អំពីការវាយតំលៃកត្តាប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ</u>** | ☐ | ☐ | ☐ |
| **គ)-<u>ការធ្វើតេស្តរកជំងឺស្វាយអាចធ្វើបាននៅតាមគ្រប់សេវាថែទាំសុខភាពសាធារណៈ</u>** | ☐ | ☐ | ☐ |

### *៤ - ការបង្ការការឆ្លងជំងឺកាមរោគថ្មីៗ (រួមបញ្ចូលទាំងមេរោគអេដស៍ផងដែរ)*

| | | | |
|---|---|---|---|
| **<u>ការអប់រំសុខភាព</u>** | | | |
| -តាមប្រព័ន្ធផ្សព្វផ្សាយពត៌មាន | ☐ | ☐ | ☐ |
| -តាមសាលារៀន | ☐ | ☐ | ☐ |
| -តាមសេវាថែទាំសុខភាព | ☐ | ☐ | ☐ |
| -តាមអង្គការនានាដែលបំរើការងារក្នុងសហគមន៍ | ☐ | ☐ | ☐ |
| **<u>ការបណ្តុះបណ្តាលបុគ្គលិកសុខភាព</u>** | | | |
| -បណ្តុះបណ្តាលគ្រូពេទ្យលើកដំបូងអំពីការអប់រំនិងផ្តល់ប្រឹក្សាស្តីពីជំងឺកាមរោគ | ☐ | ☐ | ☐ |
| -បណ្តុះបណ្តាលគ្រូពេទ្យ បន្តអំពីការអប់រំនិងផ្តល់ប្រឹក្សាស្តីពីជំងឺកាមរោគ | ☐ | ☐ | ☐ |
| -បណ្តុះបណ្តាលគិលានុប្បដ្ឋាក-យិកា_ឆ្មប លើកដំបូងអំពីការអប់រំនិងផ្តល់ប្រឹក្សាស្តីពីជំងឺកាមរោគ | ☐ | ☐ | ☐ |

| | | | |
|---|---|---|---|
| -បណ្តុះបណ្តាលគិលានុប្បដ្ឋាក-យិកា_ឆ្មប បន្តអំពីការអប់រំ និងផ្តល់ប្រឹក្សាស្តីពីជំងឺកាមរោគ | ☐ | ☐ | ☐ |
| **<u>ការបញ្ជូនដៃគូរួមភេទ</u>** | | | |
| -ធ្វើនៅតាមបណ្តាគ្លីនិកថែទាំព្យាបាលកាមរោគ | ☐ | ☐ | ☐ |
| -ធ្វើនៅតាមសេវាដទៃទៀតដែលមានផ្តល់សេវាថែទាំជំងឺកាមរោគ | ☐ | ☐ | ☐ |
| **<u>ការជំរុញការប្រើប្រាស់ស្រោមអនាម័យ</u>** | | | |
| **<u>មានស្រោមអនាម័យប្រើប្រាស់</u>** | | | |
| -នៅតាមគ្រប់សេវាដែលផ្តល់ការថែទាំកាមរោគ | ☐ | ☐ | ☐ |
| -នៅតាមគ្លីនិកដទៃទៀត | ☐ | ☐ | ☐ |
| -នៅតាមគ្លីនិកកាមរោគ | ☐ | ☐ | ☐ |
| -នៅតាមឱសថស្ថាន | ☐ | ☐ | ☐ |
| -នៅតាមទីផ្សារ ឬ ហាងលក់ទំនិញ | ☐ | ☐ | ☐ |
| **<u>មានការជំរុញអោយប្រើប្រាស់ស្រោមអនាម័យ</u>** | | | |
| -តាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មាន | ☐ | ☐ | ☐ |
| -នៅតាមសេវាថែទាំសុខភាព | ☐ | ☐ | ☐ |
| -នៅតាមគ្លីនិកផែនការគ្រួសារ | ☐ | ☐ | ☐ |
| -ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ | ☐ | ☐ | ☐ |
| **<u>ការចុះអប់រំផ្ទាល់ដល់ក្រុមជនដែលងាយទទួលរងនូវការឆ្លងកាមរោគ</u>** | | | |
| -ស្ត្រីរកស៊ីផ្លូវភេទ | ☐ | ☐ | ☐ |
| -យុវជន | ☐ | ☐ | ☐ |
| -អតិថិជននៃស្ត្រីរកស៊ីផ្លូវភេទ | ☐ | ☐ | ☐ |
| -អ្នកដែលចល័ត (Mobile) | ☐ | ☐ | ☐ |
| ***<u>សរុប</u>*** | | | |

## ឧបសម្ព័ន្ធ ១.១

## ការប្រយុទ្ធនឹងជំងឺកាមរោគ និងការកាត់បន្ថយការចំលងមេរោគអេដស៍ តាមការរួមភេទរវាងអ្នកដែលមានភេទផ្ទុយគ្នា

### *អត្ថបទសង្ខេបសំរាប់សន្និសីទអន្តរជាតិលើកទី ១២ ស្តីអំពីជំងឺអេដស៍នៅទីក្រុង Geneva កាលពីខែ កក្កដា ឆ្នាំ ១៩៩៨*

❖ **<u>ការសិក្សាស្រាវជ្រាវនៅ MWANZA (Mwanza study)</u>**

ការធ្វើអន្តរាគមន៍សាកល្បងដើម្បីទប់ស្កាត់ការឆ្លងរាលដាលជំងឺកាមរោគ នៅក្នុងសហគមន៍មួយ ក្នុង តំបន់ Mwanza នៃប្រទេស Tanzania ដែលបានធ្វើចប់សព្វគ្រប់នៅក្នុងឆ្នាំ ១៩៩៤ បាន បង្ហាញឱ្យឃើញថា ការធ្វើឱ្យប្រសើរឡើងចំពោះការធ្វើរោគវិនិច្ឆ័យ និងព្យាបាលថែទាំជំងឺកាមរោគដែល អាចព្យាបាលជា នៅតាមមណ្ឌលថែទាំសុខភាពបឋម អាចកាត់បន្ថយការចំលងមេរោគអេដស៍បាន លើសពី 40% ។

អន្តរាគមន៍នេះបានចំណាយថវិកាតិចតួចប៉ុណ្ណោះ ដោយប្រើប្រាស់នូវឱសថសាមញ្ញ និងបុគ្គលិកដែល មានស្រាប់នៅតាមមណ្ឌលសុខភាព។ ដូច្នេះអន្តរាគមន៍នេះ អាចយកទៅអនុវត្តបាននៅក្នុងប្រទេស ផ្សេងៗទៀត ដែលមានប្រព័ន្ធថែទាំសុខភាពបឋមកំពុងដំណើរការ ។ ការធ្វើអន្តរាគមន៍នេះចំណាយ អស់ធនធានតិច តែទទួលបាននូវប្រសិទ្ធិភាពខ្ពស់បើប្រៀបធៀបទៅនឹងអន្តរាគមន៍ផ្សេងៗទៀត ដូចជា ការចាក់ថ្នាំបង្ការជំងឺ កញ្ជ្រិល និងការស្រាវជ្រាវរកអ្នកជំងឺរបេង ។

គេទទួលបានលទ្ធផលដូចគ្នានឹងករណីនៅ Mwanza នោះដែរក្នុងការធ្វើអន្តរាគមន៍ទប់ស្កាត់ ជំងឺកាមរោគ លើក្រុមប្រឈមមុខនឹងការចំលងខ្ពស់ ដូចជាអ្នករកស៊ីផ្លូវភេទ ។

យន្តការ (Mechanism) ដែលនាំឱ្យទទួលបាននូវលទ្ធផលនេះ បានបញ្ជាក់ឱ្យគេឃើញកាន់តែច្បាស់ឡើងៗ។ បុរស ស្ត្រី ដែលកើតកាមរោគមានរោគសញ្ញា និងមិនបានព្យាបាល បានបញ្ចេញមេរោគអេដស៍ពីដំបៅ (lesions) ហើយកំរិតដែលបញ្ចេញមេរោគនេះនឹងថយចុះនៅពេលមានការព្យាបាលជំងឺកាមរោគ និងនៅពេល ដែលដំបៅនោះជាសះស្បើយ ។ ការសិក្សាស្រាវជ្រាវនេះ ក៏បានបញ្ជាក់ពីសារៈសំខាន់ក្នុងការធ្វើរោគវិនិច្ឆ័យ និងការព្យាបាល ***ជំងឺកាមរោគដែលមានរោគសញ្ញា*** ដើម្បីកាត់បន្ថយ នូវរយៈពេលដែលការចំលងនៃមេរោគ អេដស៍មានកំរិតខ្ពស់ នៅលើអ្នកដែលកើតជំងឺកាមរោគនិងជំងឺអេដស៍ក្នុងពេលជាមួយគ្នា ។

❖ **ការសិក្សាស្រាវជ្រាវនៅ RAKAI (RAKAI study)**

លទ្ធផលនៃការសិក្សាស្រាវជ្រាវមួយទៀតនៅ **RAKAI,** ប្រទេស Uganda ត្រូវបានរាយការណ៍នៅក្នុងសន្និសីទអន្តរជាតិលើកទី១២ ស្តីអំពីជំងឺអេដស៍ នៅទីក្រុង Geneva ។ ការស្រាវជ្រាវនេះមានភាពខុសប្លែកគ្នាពីការស្រាវជ្រាវនៅ Mwanza ដោយនៅទីនេះ គេប្រើប្រាស់វិធីព្យាបាលប្រជាជនដែលមានសកម្មភាពផ្លូវភេទទាំងអស់ (mass treatment) ។

នៅរៀងរាល់រយៈពេល១០ខែម្តង មនុស្សពេញវ័យទាំងអស់ដែលកំពុងរស់នៅក្នុងសហគមន៍ធ្វើអន្តរាគមន៍ (Intervention communities) ត្រូវទទួលការព្យាបាល គ្របដណ្តប់លើជំងឺកាមរោគដែលអាចព្យាបាលបានទាំងអស់ដោយប្រើការគួបផ្សំឱសថអង់ទីប៊ីយ៉ូទិកដែលមានប្រសិទ្ធិភាព ។ នៅក្នុងសហគមន៍ដែលទុកធ្វើការប្រៀបធៀប (Control communities) ពុំមានធ្វើអន្តរាគមន៍ព្យាបាលជំងឺកាមរោគទេ ។ ប្រជាជនដែលត្រូវបានរកឃើញថាកើតរោគស្វាយតាមរយៈការធ្វើតេស្តឈាម ត្រូវទទួលការព្យាបាលនៅក្នុងសហគមន៍ទាំងពីរ ។ ការសិក្សាស្រាវជ្រាវត្រូវបានបញ្ឈប់ក្រោយពីបានធ្វើការព្យាបាល mass treatment ចំនួនពីរដងពីព្រោះថា ទោះបីជាអន្តរាគមន៍នេះបានកាត់បន្ថយជំងឺកាមរោគនៅក្នុង សហគមន៍ដែលធ្វើអន្តរាគមន៍ (Intervention Communities) ក៏ដោយក៏អាំងស៊ីដង់នៃការឆ្លងមេរោគអេដស៍ ពុំមានភាពខុសគ្នាឡើយបើប្រៀបធៀបជាមួយនឹងសហគមន៍ដែលពុំមានធ្វើអន្តរាគមន៍។

❖ **ការពិភាក្សា**

នៅក្នុងសន្និសីទអន្តរជាតិលើកទី ១២ នេះ អ្នកឯកទេសអន្តរជាតិទាំងអស់បានព្រមព្រៀងគ្នាថា ការស្រាវជ្រាវនៅ **Rakai** និងនៅ **Mwanza** បានដំណើរការត្រឹមត្រូវ និងបានផ្តល់នូវលទ្ធផលច្បាស់លាស់ ទោះជាលទ្ធផលនោះខុសគ្នាក៏ដោយ ។ មានការពន្យល់បកស្រាយពីរយ៉ាង :

***<u>ទីមួយ</u>*** : ការស្រាវជ្រាវនៅ Rakai មិនបានធ្វើអន្តរាគមន៍ទៅលើអ្នកដែលកើតជំងឺកាមរោគ ហើយមានរោគសញ្ញានៅក្នុងចន្លោះពេលធ្វើ mass treatment ដែលតែងតែធ្វើក្នុងរយៈពេល ១០ខែម្តង នោះទេ ។ ទោះបីជាការធ្វើអន្តរាគមន៍នៅ Rakai បានកាត់បន្ថយប្រេវ៉ាឡង់ជំងឺកាមរោគ នៅក្នុងសហគមន៍ដែលធ្វើអន្តរាគមន៍ក៏ដោយក៏នៅតែមានជំងឺកាមរោគជាច្រើនទៀតដែលទើបកើតថ្មី (New STD) នៅក្នុងចន្លោះពេលធ្វើ mass treatment នីមួយៗ ។ បុរស និងស្ត្រីមួយចំនួន ដែលបានកើតជំងឺកាមរោគក្នុងចន្លោះពេលធ្វើ mass treatment នេះ បានទៅស្វែងរកការព្យាបាលពី សេវាថែទាំសុខភាពសាធារណៈរបស់រដ្ឋាភិបាល ប៉ុន្តែធនធាននៅទីកន្លែងទាំងនោះមិនទាន់មានភាពរឹងមាំនៅឡើយ ហេតុដូច្នេះជំងឺកាមរោគ

ទាំងនេះនៅតែមិនបានទទួលការព្យាបាលដដែល ។ នេះជាភាពខុសគ្នា ទៅនឹងការសិក្សានៅ Mwanza ដែលនៅទីនោះ ការថែទាំព្យាបាលជំងឺកាមរោគមានបន្តជាប់ជារហូតក្នុង រយៈពេលធ្វើអន្តរាគមន៍ ។

***ទីពីរ*** : ការរាលដាលនៃមេរោគអេដស៍នៅ Mwanza និងនៅ Rakai ស្ថិតនៅក្នុងដំណាក់កាលខុសគ្នា។ នៅ Mwanza ដែលជាកន្លែងដែលទើបតែមានការឆ្លងនៃមេរោគ អេដស៍ ចូលដល់សហគមន៍ក្នុងពេលថ្មីៗនោះ អត្រាប្រេវ៉ាឡង់នៃមេរោគអេដស៍មានពី 4% ទៅ 5% ដែលផ្ទុយពីនៅ Rakai (ជាតំបន់មួយក្នុងចំណោមតំបន់ទាំងឡាយនៃទ្វីបអាហ្វ្រិកខាងកើតដែលបានទទួលរងនូវការចំលងមេរោគអេដស៍ដ៏ធ្ងន់ធ្ងរមុនគេដំបូងបង្អស់) ដែលអត្រាប្រេវ៉ាឡង់នៃមេរោគ អេដស៍ មានប្រហែលជា 16% នៃចំនួនប្រជាជនដែលស្ថិតនៅក្រោមការស្រាវជ្រាវ ។

ការទប់ស្កាត់ជំងឺអេដស៍តាមរយៈការធ្វើអន្តរាគមន៍ទៅលើជំងឺកាមរោគ ទំនងជានឹងទទួលបានជោគជ័យច្រើនបំផុត តែនៅពេលណាដែលមេរោគអេដស៍ទើបតែចូលដល់សហគមន៍ថ្មីៗ ហើយនឹងមិនសូវទទួលបានជោគជ័យទេ នៅពេលដែលការចំលងបានរីករាលដាលដល់គ្រប់ស្រទាប់ប្រជាជនទាំងមូលរួចស្រេចទៅហើយ ។ ការសិក្សាស្រាវជ្រាវនៅ Rakai ក៏បានបង្ហាញផងដែរ អំពីតួនាទីនៃជំងឺរលាកទ្វារមាសដែលបង្កដោយបាក់តេរី (Bacterial Vaginosis) ក្នុងការបង្កើនការប្រឈមមុខនឹងការឆ្លងមេរោគអេដស៍តាមរយៈការរួមភេទរវាងអ្នកដែលមានភេទផ្ទុយគ្នា ។ នេះជាលទ្ធផលមួយដែលគួរឱ្យព្រួយបារម្ភ នៅតាមបណ្តាប្រទេសដែលកំពុងអភិវឌ្ឍន៍ ពីព្រោះការព្យាបាលជំងឺនេះ ភាគច្រើនវាគ្រាន់តែផ្តល់នូវភាពធូរស្រាលបណ្តោះអាសន្នប៉ុណ្ណោះ។

ការសន្និដ្ឋានដំបូងនៃការពិភាក្សានៅក្នុងសន្និសីទ គឺ :

- ***ធ្វើឱ្យកាន់តែប្រសើរឡើងនូវការស្វែងរក និងការថែទាំព្យាបាលជំងឺកាមរោគនៅតែមានសារៈសំខាន់ដដែលក្នុងការកាត់បន្ថយការចំលងនៃមេរោគអេដស៍ និងជំងឺកាមរោគផ្សេងទៀត ។***

- ធ្វើការកែលំអរការបណ្តុះបណ្តាល និងការចុះអភិបាលបុគ្គលិក ប្រាកដជាធ្វើឱ្យមានការព្យាបាល មួយសមស្របនិងត្រឹមត្រូវ នៅតាមសេវាថែទាំជំងឺកាមរោគ ។

- Mass treatment អាចមានតួនាទី តែនៅក្នុងកាលៈទេសៈពិសេសៗ ដែលទាក់ទងទៅនឹងការប្រឈមមុខនឹងការចំលងខ្ពស់ ដូចជា នៅក្នុងចំណោមអ្នករកស៊ីផ្លូវភេទ ប៉ុន្តែគួរតែធ្វើឡើង ជាមួយនឹងការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាថែទាំព្យាបាលកាមរោគផងដែរ ។

ការស្វែងរក និងការព្យាបាលជំងឺកាមរោគ (ដោយមាន ឬ គ្មាន mass treatment) ទំនងជាផ្តល់លទ្ធផលល្អ (cost-effective) នៅតាមកន្លែងដែល ជំងឺកាមរោគ មានអត្រាប្រេវ៉ាឡង់ខ្ពស់ និងមានការចំលងមេរោគអេដស៍ស្ថិតនៅក្នុងដំណាក់កាលដំបូង ។

## ម៉ូឌុលទី ២

# ការផ្តល់សេវាថែទាំជំងឺកាមរោគ

យើងនឹងពិភាក្សាអំពី មូលហេតុដែលអ្នកជំងឺកាមរោគជាច្រើន មិនដែលបានទទួលនូវការព្យាបាលដែលប្រកបដោយប្រសិទ្ធិភាពសោះ ទោះបីជាពួកគេមានរោគសញ្ញាក៏ដោយ ។

មូលហេតុចំបងគឺ នៅតាមប្រទេសជាច្រើន មានគ្លីនិកកាមរោគតិចណាស់ដែលអាចផ្តល់ការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺកាមរោគ ។

ក្នុងវគ្គនេះយើងនឹងពិភាក្សាអំពី:

- តើអ្នកដែលគិតថាខ្លួនប្រហែលជាមានជម្ងឺកាមរោគ ទៅរកការព្យាបាលនៅកន្លែងណា ?
- បើសិនមានការពង្រីក និងកែលំអសេវាថែទាំជំងឺ កាមរោគ តើពួកគេគួរទៅទីណា ?

យើងនឹងវាយតំលៃអំពីគំរូការនៃសេវានានាដើម្បីធ្វើឱ្យអ្នកជំងឺកាមរោគងាយស្រួលក្នុងការទទួលបានការព្យាបាលត្រឹមត្រូវ ។

យើងនឹងពិចារណាផងដែរអំពី:

- វិធីគ្រប់គ្រងនិងកន្លែងដែលត្រូវស្វែងរកអ្នកជំងឺកាមរោគដែលគ្មានរោគសញ្ញា
- អ្នកណាខ្លះដែលជាអ្នកប្រើប្រាស់សេវាថែទាំ និងចំណង់ចំណូលចិត្តរបស់ពួកគេ

## ២.១ នរណាជាអ្នកផ្តល់សេវាថែទាំជំងឺកាមរោគ?

### ២.១.១ សេវាសំរាប់ប្រជាជនដែលគិតថា ខ្លួនប្រហែលជាមានជម្ងឺកាមរោគ

* <u>គ្លីនិកឯកទេសព្យាបាលជំងឺកាមរោគ</u>

- ជាទូទៅសេវាថែទាំជំងឺកាមរោគពឹងផ្អែកទៅលើគ្លីនិកឯកទេស ហើយអ្នកជំងឺអាចទៅកាន់គ្លីនិកដោយខ្លួនឯង ឬត្រូវបញ្ជូនមកកាន់ទីនេះដោយគ្លីនិកដទៃៗទៀត ។ គេហៅប្រព័ន្ធនេះថាជា “ប្រព័ន្ធផ្តល់ការថែទាំកាមរោគតាមបែប vertical ” ។

  ចំណែកប្រព័ន្ធដែលផ្តល់សេវាថែទាំជំងឺកាមរោគនៅមន្ទីរពេទ្យបង្អែក ឬ នៅថ្នាក់មណ្ឌលសុខភាព ហៅថា “ប្រព័ន្ធផ្តល់ការថែទាំកាមរោគតាមបែប horizontal និងរួមបញ្ចូល (Horizontal and integrated STD care system) ។

ប្រព័ន្ធទាំងពីរនេះ មានគុណសម្បត្តិ និងគុណវិបត្តិរបស់វា ។

***គុណសម្បត្តិនៃប្រព័ន្ធ*** Vertical :

- គ្លីនិកឯកទេសជាច្រើនមានសំភារៈបរិក្ខារថែទាំ ហើយមានគ្រូពេទ្យឯកទេសបំរើការងារនៅទីនោះ (ឯកទេសផ្នែកកាមរោគ ឬ សើស្បែកនិងកាមរោគ) ។

- មានសេវាពិនិត្យមីក្រូទស្សន៍សំរាប់ប្រើប្រាស់នៅក្នុងគ្លីនិក ដែលអាចផ្តល់នូវរោគវិនិច្ឆ័យរកមូលហេតុបានភ្លាមៗ ក្នុងករណីភាគច្រើន ។

- គ្លីនិកភាគច្រើនអាចមានសេវាមន្ទីរពិសោធន៍ប្រើប្រាស់ ប៉ុន្តែជាញឹកញាប់ ត្រូវពឹងផ្អែកទៅលើការធ្វើរោគវិនិច្ឆ័យតាមបែបគ្លីនិក នៅពេលផ្តល់ការព្យាបាល ។

- គ្លីនិកទាំងនោះអាចផ្តល់ការថែទាំព្យាបាលបានល្អប្រសើរដល់អ្នកជម្ងឺ (ក៏ប៉ុន្តែអ្នកជំងឺដែលទៅទទួលសេវាទីនោះ គ្រាន់តែជាផ្នែកមួយតូចនៃករណីជំងឺកាមរោគទាំងអស់តែប៉ុណ្ណោះទេ) ។

***គុណវិបត្តិនៃប្រព័ន្ធ*** Vertical

- ត្រូវចំណាយថវិកាច្រើនសំរាប់បង្កើតនិងដាក់ឱ្យដំណើរការ ។ ជាទូទៅសេវានេះមានតែនៅតាមទីក្រុងធំៗតែប៉ុណ្ណោះ ។
- ដោយសារទីនោះជាកន្លែងឯកទេសព្យាបាលជំងឺកាមរោគ ដូច្នេះប្រជាជនអាចស្ទាក់ស្ទើរទៅពិគ្រោះជំងឺ ព្រោះខ្លាចគេឃើញ ។
- បុគ្គលិកសុខាភិបាលភាគច្រើនជាបុរស ដូច្នេះធ្វើឱ្យស្ត្រីស្ទាក់ស្ទើរក្នុងការប្រើប្រាស់សេវានោះ ។
- អ្នកដែលធ្វើការនៅទីនោះតែងតែគិតថា មានតែអ្នកឯកទេសទេដែលអាចព្យាបាលអ្នកជំងឺកាមរោគបាន ។

យើងដឹងថានៅតាមប្រទេសជាច្រើន មានអ្នកជំងឺកាមរោគតិចតួចប៉ុណ្ណោះដែលទៅស្វែងរកការព្យាបាលនៅឯគ្លីនិកឯកទេសកាមរោគ ។

| |
|---|
| ចំណុចសំខាន់បំផុត នៅក្នុងវគ្គបណ្តុះបណ្តាលនេះគឺ គ្លីនិកឯកទេសព្យាបាលជំងឺកាមរោគ មិនគ្រប់គ្រាន់សំរាប់ការផ្តល់សេវាថែទាំព្យាបាលដល់អ្នកជំងឺគ្រប់ៗគ្នាបានទេ ទោះបីជាគ្លីនិកមានសារៈប្រយោជន៍ច្រើនក៏ដោយ ។ |

*  *គ្លីនិកដែលមិនមានលក្ខណៈឯកទេស*

អ្នកជំងឺកាមរោគអាចស្វែងរកការព្យាបាលនៅតាមមណ្ឌលសុខភាពនិងមន្ទីរពេទ្យបង្អែកនានា ។

ស្រ្តីដែលមានរោគសញ្ញាជំងឺកាមរោគ ក៏អាចស្វែងរកការព្យាបាលនៅឯគ្លីនិកពន្យាកំណើតដែលស្ថិតនៅជិតបំផុតផងដែរ ។ ប្រសិនបើ បុគ្គលិកសុខាភិបាលនោះបានទទួលការបណ្តុះបណ្តាល ស្តីពីវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា នោះពួកគេអាចព្យាបាលអ្នកជំងឺបានភ្លាមៗតែម្តង ។

លើសពីលើនោះទៅទៀត គ្លីនិកពន្យាកំណើតជាកន្លែងដែលល្អបំផុតសំរាប់ស្វែងរកឃើញស្រ្តីដែលមានជំងឺកាមរោគ តែគ្មានរោគសញ្ញា ។ បុគ្គលិកនៅក្នុងគ្លីនិកនេះមានទំលាប់ក្នុងការពិភាក្សាពីបញ្ហាផ្លូវភេទដូច្នេះ ពួកគេមិនមានការលំបាកក្នុងការពិភាក្សាពីជំងឺកាមរោគទេ ។ នៅពេលប្រើប្រាស់ចំពុះទា (speculum) ដើម្បីពិនិត្យស្រ្តីដែលគ្មានរោគសញ្ញា បុគ្គលិកទាំងនោះអាចពិនិត្យរកឃើញភាពមិនធម្មតានៃមាត់ស្បូន និងការហូរខ្ទុះតាមទ្វារមាស ឬក៏ដំបៅនៅលើប្រដាប់បន្តពូជបាន ។

តាមមធ្យោបាយដូចគ្នានេះ បុគ្គលិកផ្នែកគាំពារមាតានិងទារក ក៏អាចរកឃើញរោគសញ្ញាជំងឺកាមរាគលើស្រ្តីដែលគ្មានរោគសញ្ញាដែរ ។ ឧទាហរណ៍ៈ គ្រប់ស្រ្តីមានផ្ទៃពោះគួរទទួលការធ្វើតេស្តរកជំងឺស្វាយ ឬការពិនិត្យរកឃើញការហូរខ្ទុះលើភ្នែកទារក ដែលទើបនឹងកើត អាចបញ្ជាក់បានថាម្តាយមានជំងឺបង្កឡើងដោយមេរោគ ហ្គោណូកូកនិងមេរោគក្លាមីឌីយ៉ា (ចង្កោមរោគសញ្ញាការហូរខ្ទុះតាមទ្វារមាស) ។

*  **គុណសម្បត្តិនៃប្រព័ន្ធ** horizontal

- *ការផ្តល់សេវាតាមបែបប្រព័ន្ធ Horizontale នេះអាចផ្តល់ភាពងាយស្រួលដល់អ្នកជំងឺកាមរោគក្នុងការមកទទួលសេវាថែទាំ ហើយបុគ្គលិកសុខាភិបាលត្រូវបានអ្នកជំងឺស្គាល់ និងទទួលបានទំនុកទុកចិត្តពីសហគមន៍ ។ ដូច្នេះជំងឺកាមរោគ ត្រូវបានការរកឃើញនិងព្យាបាលបានយ៉ាងឆាប់រហ័សធ្វើឱ្យគេអាចកាត់បន្ថយការចំលងជំងឺបានថែមទៀត ។*
- សេវានេះលើកទឹកចិត្តអ្នកជំងឺឱ្យហ៊ានប្រាប់ដៃគូរួមភេទរបស់គេថា ដៃគូនោះអាចឆ្លងជំងឺកាមរោគ ហើយសុំឱ្យដៃគូរបស់ពួកគេមកទទួលការព្យាបាល ។
- សេវានេះ ក៏អាចស្វែងរកឃើញជំងឺកាមរោគលើស្រ្តីដែលគ្មានរោគសញ្ញាដែរ ។

- សេវានេះ អាចជាប្រភពផ្តល់ពត៌មាននិងអប់រំអំពីជំងឺកាមរោគ ហើយអាចផ្សព្វផ្សាយពត៌មានអំពីសុខភាពផ្លូវភេទ និង លើកទឹកចិត្តអោយមានការស្វែងរកការព្យាបាល ។
- សេវានេះ អាចជំរុញការប្រើប្រាស់ស្រោមអនាម័យ និងជាប្រភពផ្តល់ស្រោមអនាម័យដែលមានតំលៃថោកសមរម្យ និងមានគុណភាពល្អ ។

* **គុណវិបត្តិនៃប្រព័ន្ធ** Horizontal

- អ្នកដែលយល់ថា ខ្លួនអាចកើតជំងឺកាមរោគអាចស្ទាក់ស្ទើរក្នុងចិត្តដើម្បីទៅពិនិត្យជំងឺ នៅពេលដែលគាត់ឃើញនរណាម្នាក់ដែលគាត់បានស្គាល់ ជាអ្នកជម្ងឺ ឬជាបុគ្គលិកសុខាភិបាលនៅទីនោះ។

  ដើម្បីជំនះលើបញ្ហានេះ បុគ្គលិកសុខាភិបាលត្រូវតែបង្ហាញអ្នកជំងឺដែលរស់នៅក្នុងមូលដ្ឋាន ខ្លួនថាពួកគេអាចពិភាក្សាពីបញ្ហាផ្លូវភេទ និងសុខភាពផ្លូវភេទ បានដោយសុវត្ថិភាពនិង គ្មាន ការវិនិច្ឆ័យ (jugment) ហើយអាចធានាបាននូវភាពស្ងាត់កំបាំង (privacy) និងការរក្សាការសំងាត់ (confidentiality)។

- បុគ្គលិកសុខាភិបាលអាចខ្វះការបណ្តុះបណ្តាលស្តីពីការគ្រប់គ្រងនិងថែទាំជំងឺកាមរោគត្រឹមត្រូវ ។
- បុគ្គលិកសុខាភិបាលអាចគ្មានពេលវេលាគ្រប់គ្រាន់សំរាប់អប់រំដល់អ្នកជំងឺកាមរោគ ។

* **សេវាថែទាំផ្សេងៗទៀត**

មុនពេលជួបពិគ្រោះជាមួយបុគ្គលិកថែទាំសុខភាព អ្នកជំងឺជាច្រើនដែលគិតថាពួកគេអាចកើតជំងឺកាមរោគ បានស្វែងរកការណែនាំនិងការព្យាបាលពីអ្នក *លក់ឱសថ* ឬ *គ្រូឱសថបុរាណ* ហើយអ្នកជំងឺជាច្រើនទៀត បានជួបពិគ្រោះជាមួយ *គ្រូពេទ្យឯកជន* ។ ប្រការដែលសំខាន់ គឺត្រូវទទួលស្គាល់ថា កន្លែងទាំងនោះបានផ្តល់ការព្យាបាលជម្ងឺកាមរោគដល់អ្នកជំងឺ ដូច្នេះសេវាទាំងនោះគួរត្រូវបានពង្រីក និងធ្វើអោយកាន់តែប្រសើរនៅពេលណាដែលមានលទ្ធភាព ។

ស្តង់ដារនៃការថែទាំដែលផ្តល់ជូនដោយគ្រូពេទ្យឯកជនមានភាពប្រែប្រួល ។ គ្រូពេទ្យខ្លះអាចជាអ្នកឯកទេសដែលធ្វើការនៅក្នុងគ្លីនិកឯកទេសសាធារណ: ប៉ុន្តែគ្រូពេទ្យខ្លះទៀតអាចមិនមែនជាគ្រូពេទ្យឯកទេស ហើយពុំដែលបានទទួលការបណ្តុះបណ្តាលពីការគ្រប់គ្រងថែទាំជំងឺកាមរោគទេ ឬក៏បានទទួល

ការបណ្តុះបណ្តាលតិចតួចប៉ុណ្ណោះ ។ គ្រូពេទ្យខ្លះអាចផ្ញើរតែវត្ថុវិភាគ (specimens) ទៅមន្ទីរពិសោធន៍ ក៏ប៉ុន្តែគ្រូពេទ្យភាគច្រើនពុំបានធ្វើបែបនេះទេ ហើយពឹងផ្អែកទៅលើការធ្វើរោគវិនិច្ឆ័យបែបគ្លីនិកទៅវិញ ។

អ្នកលក់ឱសថភាគច្រើន និងគ្រូឱសថបុរាណខ្លះក៏ឱ្យ ឱសថអង់ទីប៊ីយូទិកដែរ ប៉ុន្តែភាគច្រើន ឱសថទាំងនោះមិនមានលក្ខណៈសមស្របទេ ហើយកំរិតថ្នាំក៏ពុំគ្រប់គ្រាន់ដែរ ។

ការប្រើថ្នាំមិនត្រឹមត្រូវនេះ ជាមូលហេតុចំបងដែលធ្វើឱ្យ មេរោគហ្គោណូកូក ស៊ាំនឹងឱសថអង់ទីប៊ីយោទិក ។ ក៏ប៉ុន្តែអ្នកជំងឺកាមរោគជាច្រើន បានស្វែងរកជំនួយពីអ្នកថែទាំព្យាបាលក្រៅផ្លូវការមុនពេលពួកគេទៅកាន់គ្លីនិកថែទាំសុខភាពសាធារណៈ ។ បទពិសោធន៍នៃប្រទេសមួយចំនួនបានបង្ហាញ ថាដោយមានការគាំទ្រ និងមានការបណ្តុះបណ្តាលអ្នកប្រកបអាជីពក្រៅផ្លូវការអ្នកទាំងនោះត្រូវបានបញ្ចូលក្នុងកម្មវិធីពង្រីកសេវាថែទាំកាមរោគ ហើយពួកគេបានរៀនសូត្រអំពីរបៀបព្យាបាលដែលត្រឹមត្រូវនិងអំពីការផ្តល់ដំបូន្មានដល់អ្នកជំងឺកាមរោគ ដើម្បីឱ្យស្វែងរកការថែទាំព្យាបាលពីគ្លីនិកថែទាំសុខភាព ។

## ២.១.២ សេវាសំរាប់អ្នកជំងឺ ដែលមិនបានគិតថា ខ្លួនកើតជំងឺកាមរោគ

មកទល់ពេលនេះ យើងបានពិភាក្សាពីវត្តមាននៃសេវាសំរាប់ថែទាំអ្នកជំងឺដែលបានដឹងថាខ្លួនកើតជំងឺកាមរោគ ។ មានមនុស្សជាច្រើន ទាំងបុរស ទាំងស្ត្រី អាចមិនដឹងខ្លួនថាពួកគេកើតជំងឺកាមរោគទេ ។ គេអាចរកឃើញអ្នកជំងឺទាំងនោះតាមរយៈការគ្រប់គ្រងដៃគូរួមភេទ ដែលប្រកបដោយប្រសិទ្ធិភាព ។ ហេតុដូច្នេះ ការគ្រប់គ្រងដៃគូរួមភេទមានសារៈសំខាន់ណាស់ ។

មធ្យោបាយផ្សេងៗទៀត ដើម្បីកំណត់រកជំងឺកាមរោគដែលគ្មានរោគសញ្ញា គឺការស្វែងរកតាមរយៈការធ្វើតេស្តរកមេរោគដោយមន្ទីរពិសោធន៍ (case finding and screening) ។

* ស្វែងរកអ្នកកើតជំងឺកាមរោគ (Case finding) : មានន័យថាពេលដែលបុគ្គលិកថែទាំសុខភាពជួបអ្នកជំងឺក្នុងគ្លីនិក ពួកគេឆ្លៀតឱកាសនេះដើម្បីសាកសួរអ្នកជំងឺអំពីការប្រឈមមុខនៃការឆ្លងជំងឺកាមរោគ និងស្វែងរកវត្តមានរោគសញ្ញានៃជំងឺនេះ ។ ឧទាហរណ៍: នៅពេលពិនិត្យទ្វារមាសដោយចំពុះទា (speculums) ប្រសិនបើគេមានសេវាមន្ទីរពិសោធន៍សំរាប់ ប្រើប្រាស់គេអាចយក "ស" (sample) ទៅពិនិត្យនៅមន្ទីរពិសោធន៍បាន ។

* ការធ្វើតេស្តរកមេរោគ (screening ) មានន័យថា គេត្រូវស្រាវជ្រាវរកវត្តមាននៃជំងឺកាមរោគនៅក្នុងចំណោមប្រជាជនជាច្រើន ។

ឧទាហរណ៍:

- ការធ្វើតេស្តរកមេរោគស្វាយលើស្ត្រីទាំងអស់ដែលមកពិនិត្យផ្ទៃពោះមុនពេលសំរាល ។
- ការធ្វើតេស្តដោយទៀងទាត់ដើម្បីរកវត្តមានមេរោគកាមរោគ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ ។

ការធ្វើ case finding និង screening ដោយប្រើជំនួយពីមន្ទីរពិសោធន៍ មានតំលៃថ្លៃ ប៉ុន្តែវាជាការសមរម្យ បើសិនជាអត្រាអាំងស៊ីដង់នៃជំងឺកាមរោគ ក្នុងចំណោមប្រជាជនណាមួយមានកំរិតខ្ពស់ (ឧទាហរណ៍: ស្ត្រីរកស៊ីផ្លូវភេទ) ឬ បើសិនជា ផលវិបាកនៃជំងឺកាមរោគដែលគេអាចបង្ការបាន ប៉ះពាល់ធ្ងន់ធ្ងរទៅលើសុខភាពសាធារណៈ(ឧទាហរណ៍: ជំងឺស្វាយពីកំណើត) ។

**លំហាត់ ២.១**

- ការពិភាក្សាតាមក្រុម:

ក្នុងក្រុមរបស់អ្នក ចូរពិភាក្សាអំពីសេវាទាំងឡាយដែលអាចផ្តល់ ការថែទាំនិងព្យាបាលជំងឺកាមរោគ នៅខេត្តរបស់អ្នក នាពេលបច្ចុប្បន្ននេះបាន ។ សូមបញ្ជាក់អំពី :

- ចំណុចខ្លាំង និង
- ចំណុចខ្សោយរបស់សេវានិមួយៗ

បន្ទាប់មកសូមកំណត់រកកន្លែងផ្សេងៗទៀត ដែលអ្នកគិតថា : គួរតែមានការផ្តល់សេវាថែទាំជំងឺកាមរោគដែរ ។

## ២.២ នរណាជាអ្នកប្រើប្រាស់សេវាថែទាំជំងឺកាមរោគ ?

* ក្រុមមនុស្សដែលប្រឈមមុខខ្ពស់នឹងការឆ្លងជំងឺកាមរោគ

- ស្ត្រីរកស៊ីផ្លូវភេទដែលមានដៃគូរួមភេទច្រើន និង/ ឬ ដែលមិនអាចសុំឱ្យភ្ញៀវរួមភេទដោយប្រើស្រោមអនាម័យបាន
- អ្នកដែលរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទដោយមិនប្រើស្រោមអនាម័យ

* <u>ក្រុមមនុស្សដែលមិនសូវប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ</u>

- យុវជនដែលមិនសូវផ្លាស់ប្តូរដៃគូរួមភេទច្រើន
- គូស្វាមីភរិយាដែលស្មោះត្រង់នឹងគ្នា

ការគិតគូ បែងចែកប្រភេទក្រុមមនុស្សដែលប្រឈមមុខនឹងគ្រោះថ្នាក់ នៃការឆ្លងជម្ងឺកាមរោគ មានសារៈសំខាន់ណាស់ក្នុងការរៀបចំបង្កើតកម្មវិធីបង្ការនិងទប់ស្កាត់ជម្ងឺនេះ ។ ប្រការដែលសំខាន់ នោះគឺ កម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ មិនត្រូវចោទប្រកាន់ថាអ្នកទាំងនោះជាអ្នកទទួលខុសត្រូវក្នុងការចំលងជំងឺទេ។ ជារឿយៗ សង្គមតែងតែស្តីបន្ទោសនិងមាក់ងាយក្រុមមនុស្សមួយចំនួន ដូចជា ស្ត្រីរកស៊ីផ្លូវភេទ បុរសដែលរួមភេទជាមួយបុរសដូចគ្នា អ្នកបើកបរ អ្នកនេសាទ ។ល។ ថាជាក្រុមមនុស្សដែលបង្កការចំលងជំងឺកាមរោគនិងមេរោគអេដស៍ដែលជាហេតុធ្វើឱ្យមានការលំបាកក្នុងការស្វែងរកអ្នកទាំងនោះ ដើម្បីអនុវត្តយុទ្ធសាស្រ្តបង្ការ និងថែទាំជំងឺ ។

ក្នុងវគ្គនេះ យើងពិចារណាអំពី ក្រុមមនុស្សដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងកាមរោគ ដែលជារឿយៗគេហៅថា "ក្រុមដែលងាយទទួលរងការឆ្លងកាមរោគ " (Vulnerable Groups) និង ជាក្រុមដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់ និងមានការផ្លាស់ប្តូរដៃគូរួមភេទញឹកញាប់ ហើយងាយចំលងទៅអ្នកដទៃ ឬ ក្រុមស្នូល (core groups) ។

* **ក្រុមដែលងាយរងការឆ្លង និងក្រុមដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់ហើយងាយចំលងទៅអ្នកដទៃ** (Vulnerable groups and core groups)

| **ក្រុមដែលងាយទទួលរងការឆ្លងកាមរោគ** (Vulnerable groups) |
| --- |
| អ្នកដែលមានការប្រឈមមុខខ្ពស់នឹងការឆ្លងជំងឺកាមរោគ គួរតែត្រូវបានលើកទឹកចិត្ត ឱ្យជ្រើសរើស ការប្រព្រឹត្តដែលមិនសូវប្រឈមមុខនឹងការឆ្លង និងការស្វែងរកការថែទាំ ព្យាបាល នៅពេលដែលពួកគេយល់ឃើញថា ខ្លួនអាចកើតជំងឺកាមរោគ ។<br><br><u>ឧទាហរណ៍:</u> ពលទាហានដែលទើបជ្រើសរើសថ្មី ហើយដែលចាកចេញឆ្ងាយពីផ្ទះលើកដំបូងអាចប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ ។ គេហៅក្រុមនេះថាជាក្រុមងាយទទួលរងការឆ្លងកាមរោគ ។ |

**ក្រុមដែលមានអត្រាប្រេវ៉ាឡង់ខ្ពស់ចំលងទៅអ្នកដទៃ** (core groups)

- ការចំលងនៃជំងឺកាមរោគ (រួមទាំងមេរោគអេដស៍) ក្នុងខេត្តឬប្រទេសរបស់អ្នកកំពុងកើតឡើងជាបន្តទៀតដោយសារតែការប្រព្រឹត្តផ្លូវភេទរបស់ក្រុមតូចនានាក្នុងចំណោមប្រជាជន ។
- មនុស្សទាំងអស់នោះជាអ្នកដែលផ្លាស់ប្តូរដៃគូរួមភេទញឹកញាប់ នឹងមានជំងឺកាមរោគក្នុងអត្រាមួយដែលមានកំរិតខ្ពស់ ។
- ជាធម្មតា មនុស្សដែលស្ថិតនៅក្នុងក្រុមនេះ ងាយប្រឈមមុខនឹងការឆ្លងជំងឺកាមរោគណាស់ យោលទៅតាមស្ថាន ភាពសង្គម សេដ្ឋកិច្ច ឬរបៀបរស់នៅរបស់ពួកគេ ។
- ក្រុមមនុស្សខាងលើនេះ គឺជាប្រជាជនចំណុច (Target groups) យ៉ាងសំខាន់ណាស់ សំរាប់ការធ្វើសកម្មភាពបង្ការ និងធ្វើអន្តរាគមន៍ ផ្នែកវេជ្ជសាស្ត្រ ។
  ឧទាហរណ៍ : ស្ត្រីរកស៊ីផ្លូវភេទគឺជា core group ពីព្រោះអត្រាអាំងស៊ីដង់ និងប្រេវ៉ាឡង់នៃជំងឺកាមរោគក្នុងចំណោមក្រុមនេះមានកំរិតខ្ពស់ ។

គេបានប៉ាន់ប្រមាណថា តាមរយៈកម្មវិធីបង្ការនិងទប់ស្កាត់ជំងឺកាមរោគ ដែលអនុវត្តលើក្រុមមនុស្សដែលមានចំនួនដូចគ្នា គេអាចបង្ការជំងឺនេះលើ core groups បាន ១០ ដងច្រើនជាងការបង្ការការចំលងកាមរោគចំពោះក្រុមដទៃៗទៀត។

សង្គមមនុស្សរួមផ្សំឡើងដោយក្រុមមនុស្សខុសៗគ្នាជាច្រើន :

- ក្រុមខ្លះប្រឈមមុខខ្ពស់នឹងការឆ្លងជំងឺកាមរោគ
- ក្រុមខ្លះប្រឈមមុខនឹងការឆ្លងទាប
- ក្រុមខ្លះងាយធ្វើសកម្មភាពការបង្ការ និងថែទាំ
- ក្រុមខ្លះមានការលំបាកក្នុងធ្វើសកម្មភាពការបង្ការនិងថែទាំ ។

## គ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ និងលទ្ធភាពក្នុងការទាក់ទងដើម្បីធ្វើសកម្មភាព ក្រុមមនុស្សនានា

| | **ការប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ មានកំរិតខ្ពស់** | **ការប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ មានកំរិតទាប** |
|---|---|---|
| ងាយទាក់ទងធ្វើសកម្មភាព | ♦ អ្នកបើកបររថយន្តធំ<br>♦ ទាហាន<br>♦ ប៉ូលីស<br>♦ ក្រុមដោះមីន<br>♦ ស្ត្រីដែលមានដៃគូរួមភេទប្រឈមមុខខ្ពស់នឹងការឆ្លងជំងឺកាមរោគ<br>♦ ស្ត្រីវ័យជំទង់ | ♦ ស្ត្រីមានផ្ទៃពោះ<br>♦ ស្ត្រីដែលទទួលសេវាពន្យាកំណើត<br>♦ សិស្សសាលា |
| ពិបាកទាក់ទងដើម្បីធ្វើសកម្មភាព | ♦ ស្ត្រីរកស៊ីផ្លូវភេទ<br>♦ បុរសដែលមានដៃគូរួមភេទជាបុរសដូចគ្នា<br>♦ អ្នកចាក់គ្រឿងញៀន<br>♦ បុរសដែលមានដៃគូរួមភេទជាស្ត្រីប្រឈមមុខនឹងការឆ្លងជំងឺកាមរោគ<br>♦ ក្រុមចល័ត (កម្មករសំណង់អ្នកនេសាទ) | ♦ បុរស ស្ត្រីដែលរស់នៅជនបទ |

### លំហាត់ ២.២

ការពិភាក្សាតាមក្រុម:

- សូមកំណត់រកក្រុមមនុស្សដែលងាយទទួលរងនឹងការឆ្លងកាមរោគ នៅក្នុងមូលដ្ឋានរបស់អ្នក ។
- ចូរបញ្ជាក់ថាតើក្រុមណាដែលងាយស្រួល ឬក៏លំបាកទាក់ទងដើម្បីធ្វើសកម្មភាព
- តើពួកគេជា ឬអាចជាក្រុម core groups ដែរឬទេ?

# ឧបសម្ព័ន្ធ

<u>ការធ្វើឱ្យប្រសើរឡើងនូវការផ្តល់សេវាថែទាំជំងឺកាមរោគនៅក្នុងទីក្រុងហាឡុងប្រទេសវៀតណាម</u>

នៅក្នុងឆ្នាំ ១៩៩៧ ទីក្រុងហាឡុង បានអនុវត្តគំរោងសាកល្បងរយ:ពេល ៥ ខែ ដែលផ្តោតទៅលើការកែលំអការធ្វើរោគវិនិច្ឆ័យ និងការថែទាំព្យាបាលជំងឺកាមរោគ ។

សកម្មភាពទាំងអស់នេះរួមមានការធ្វើសកម្មភាពលើ : គ្រូពេទ្យឯកជន ឱសថស្ថាន និង គ្រឹះស្ថានបំរើសេវាផ្លូវភេទមិនផ្ទាល់ (Indirect sex work establishment) ។

សម្មភាពទាំងនេះរួមមាន ការបណ្តុះបណ្តាលវេជ្ជបណ្ឌិតអំពីការធ្វើរោគវិនិច្ឆ័យ និងការព្យាបាលជំងឺកាមរោគ ព្រមទាំងការជួបប្រជុំជារៀងរាល់ខែ រវាងគ្រូពេទ្យឯកជន និងសេវាសុខាភិបាលរបស់រដ្ឋាភិបាល ។ គំរោងនេះទទួលបានជោគជ័យ ក្នុងការបង្កើនកិច្ចសហការរវាង សេវាសុខាភិបាលរបស់រដ្ឋាភិបាល និង គ្រូពេទ្យឯកជន រួមទាំងការរាយការណ៍ស្តីពីករណីជំងឺកាមរោគដោយគ្រូពេទ្យឯកជនផង ។

គំរោងសាកល្បងនេះក៏បាន បណ្តុះបណ្តាលដល់ឱសថការី ស្តីពីបញ្ហាជំងឺកាមរោគនេះដែរ ។ ជាមួយគ្នានោះ មជ្ឈមណ្ឌល សើស្បែក កាមរោគខេត្ត បានបន្តសហការជាមួយឱសថស្ថាន ៥ ក្នុងចំណោមឱសថស្ថានទាំង ១៥ ក្នុងក្រុង ។

គំរោងសាកល្បងក៏បានធ្វើតេស្តរកមេរោគកាមរោគ និងមេរោគអេដស៍ ផងដែរនៅលើអ្នករកស៊ីផ្លូវភេទមិនផ្ទាល់ និង អ្នកធ្វើការនៅកន្លែងគ្រឹះស្ថានកំសាន្ត (ម៉ាសា ការ៉ាអូខេ បារ សណ្ឋាគារ កន្លែងសំរាប់ងូតទឹកចំហុយ ។ល។ គ្រឹះស្ថានកំសាន្តចំនួន មួយភាគបីបានចូលរួមសហការធ្វើការដោយស្ម័គ្រចិត្តជាមួយគំរោងសាកល្បងនេះ ដើម្បីធ្វើការពិនិត្យសុខភាពយ៉ាងទៀងទាត់លើស្ត្រីដែលកំពុងធ្វើការក្នុងគ្រឹះស្ថានទាំងនោះ ។

## សកម្មភាពការបង្ការការចំលងនៃមេរោគអេដស៍

គឺមានការយល់ដឹងនិងប្តេជ្ញាចិត្តចូលរួមខ្ពស់ក្នុងការប្រយុទ្ធនឹងជំងឺអេដស៍ និងការបង្ការជំងឺកាមរោគក្នុងចំណោមមេដឹកនាំខេត្ត-ក្រុង ។ សេវាថែទាំសុខភាពបានយល់ យ៉ាងច្បាស់ពីទំនាក់ទំនងរវាងមេរោគអេដស៍ និងការបង្ការការចំលងនៃជំងឺកាមរោគ ។

នៅពេលថ្មីៗនេះ ខេត្តបានចេញបទបញ្ជាតំរូវឱ្យគ្រឹះស្ថានកំសាន្តទាំងនោះ សហការក្នុងការត្រួតពិនិត្យជំងឺកាមរោគឱ្យបានទៀងទាត់ចំពោះអ្នករកស៊ីផ្លូវភេទទាំងនោះ ដោយមានការផ្តល់ប័ណ្ណត្រួតពិនិត្យសុខភាពពីមជ្ឈមណ្ឌលសើស្បែកនិងកាមរោគខេត្ត ។ អាជ្ញាធរសុខាភិបាលខេត្តបានប្រកាសថា នឹងបិទជាបន្ទាន់នូវគ្រឹះស្ថានណាដែលបដិសេធមិនសហការជាមួយមជ្ឈមណ្ឌល សើស្បែក និងកាមរោគខេត្ត ។

អង្គការមហាជនរួមទាំង កាកបាទក្រហម សមាគមយុវជន សមាគមនារី និងសហជីព កម្មករកំពុងធ្វើការយ៉ាងសកម្មក្នុងការអប់រំជំងឺអេដស៍ និងកាមរោគ ។ សកម្មភាពនៃការអប់រំ ផ្សព្វផ្សាយរបស់គណៈកម្មការអេដស៍ខេត្ត សេវាថែទាំសុខភាពនិងអង្គការមហាជននានារួមមាន :

- ការផ្សព្វផ្សាយទៀងទាត់នូវស្ថានីយវិទ្យុ ទូរទស្សន៍
- ផ្ទាំងរូបភាព ខិតប័ណ្ណ (billboards)
- ការរៀបចំសិក្ខាសាលា ការប្រជុំ
- និងការប្រលងផ្សេងៗ ។

ម៉ូឌុលទី ៣

# ការអង្កេតតាមដាន
# និងការត្រួតពិនិត្យតាមដាន
# អត្រាកើករាលដាលនៃ ជំងឺកាមរោគ

**ការអង្កេតតាមដាន (surveillance) និង ការតាមដានត្រួតពិនិត្យ (monitoring) ការរីករាលដាលនៃមេរោគអេដស៍-កាមរោគ និង ការប្រព្រឹត្តដែលនាំឱ្យមានការឆ្លងរោគ**

" **ការចំលងនៃជំងឺកាមរោគ** "

បែបផែន (pattern) នៃជំងឺកាមរោគនៅក្នុងប្រជាជនណាមួយអាស្រ័យទៅតាមកត្តាមួយចំនួន :

- វិសាលភាពនៃការឆ្លងមេរោគនៅក្នុងចំណោមប្រជាជន
- ដំណាក់កាលនៃជំងឺ-ឬភាពអាចចំលងបានរបស់អ្នកកើតជំងឺ
- ភាពស៊ាំ (immunity) របស់អ្នកដែលមិនទាន់ឆ្លងជំងឺ
- វត្តមាននៃកត្តាគួបផ្សំផ្សេងៗ
- បែបផែននៃសកម្មភាពផ្លូវភេទដែលមនុស្សកំពុងប្រព្រឹត្ត
- ភាពញឹកញាប់ និងបែបផែនក្នុងការផ្លាស់ប្តូរដៃគូរួមភេទ

***ចំណាំ*** : ជំងឺកាមរោគខ្លះអាចឆ្លងតាមរយៈបែបផែនផ្សេងពីការរួមភេទ

- មេរោគអេដស៍ (HIV)
- មេរោគជំងឺរលាកថ្លើមប្រភេទ B (HBV)

| **កត្តានានាដែលពាក់ព័ន្ធក្នុងការចំលងជំងឺ** | **និសដៅនៃការធ្វើអន្តរាគមន៍** |
|---|---|
| ***ភាពឆ្លង*** **(Infectiousness)**<br>• ដំណាក់កាលនៃជំងឺ<br>• វត្តមាននៃដំបៅរលាក (lesions) | <br>កាត់បន្ថយអត្រាជំងឺ<br>ព្យាបាលជំងឺ ឬ រោគសញ្ញារបស់វា |
| ***ភាពងាយទទួលជំងឺ*** **(Susceptibility)**<br>• ភាពស៊ាំ<br>• ការចាក់ថ្នាំបង្ការ<br>• កត្តាហ្សេណេទិក | <br>-កម្មវិធីចាក់ថ្នាំបង្ការ |
| ***កត្តាគួបផ្សំ*** **(Co-factors)**<br>• សុខភាពផ្លូវភេទ<br>• ការប៉ះពាល់ឈាមនៅពេលរួមភេទ<br>• ការកាត់ស្បែកស្រោបក្បាលលិង្គ (circumcision) | <br>- លើកកំពស់សុខភាពផ្លូវភេទ<br>- ជំរុញការប្រព្រឹត្តផ្លូវភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ |

| | |
|---|---|
| ***សកម្មភាពផ្លូវភេទ***<br>• បង្ការខ្លួន<br>• រួមភេទតាមមាត់ ឬ តាមទ្វារមាស ឬ តាមរន្ធគូថ | - ជំរុញការប្រើប្រាស់ស្រោមអនាម័យ<br>- ជំរុញការប្រព្រឹត្តផ្លូវភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ |
| ***ការផ្លាស់ប្តូរដៃគូរួមភេទ***<br>• អត្រានៃការផ្លាស់ប្តូរ<br>• បែបផែននៃការផ្លាស់ប្តូរដៃគូរួមភេទ : ចំពោះ បុរស ឬ ស្ត្រី | - ជំរុញការប្រព្រឹត្តផ្លូវភេទដែលមិនសូវប្រឈមមុខនឹងគ្រោះថ្នាក់ |

**គោលការណ៍ទូទៅស្តីអំពីការអង្កេតតាមដានជំងឺ (General Principles of disease surveillance)**

**ការអង្កេតតាមដានជំងឺ** មានន័យថា ជាការប្រមូល (collection) វិភាគ (analysis) បកស្រាយ (interpretation) និងផ្សព្វផ្សាយ (dissemination) ពត៌មានដែលទាក់ទងនឹងស្ថានភាពសុខភាព (health status) របស់ក្រុមប្រជាជនណាមួយ (population) ដែលមានលក្ខណៈជាប់ជាប្រចាំ (ongoing) និងមានលក្ខណៈជាប្រព័ន្ធ (systematic) ។

និយមន័យនេះ ផ្តោតលើចំណុចសំខាន់ដូចខាងក្រោមនេះ :

- ***ក្រុមប្រជាជន*** **(Population)** : ការអង្កេតតាមដានជំងឺ ជានិច្ចកាលតែងតែមានទំនាក់ទំនងនឹងក្រុមប្រជាជនណាមួយជាក់លាក់ គឺ មិនមែនទាក់ទងទៅនឹងបុគ្គលទេ ។
- ***ស្ថានភាពសុខភាព*** **(Health status)** : មានន័យថា អាចជាជំងឺ - កត្តានានាដែលនាំឱ្យកើតជំងឺ
- ***ការប្រមូល*** **(collection)** : ពត៌មានត្រូវបានប្រមូលយកមកពីទីកន្លែងនានាដោយស្ថាប័នកណ្តាលណាមួយ ។
- ***ការបកស្រាយ*** **(Interpretation)** : មានន័យថា ជាការពិនិត្យពិចារណាលើអត្ថន័យនៃពត៌មានដែលប្រមូលបាន ។
- ***ការផ្សព្វផ្សាយ*** **(Dissemination) :** លទ្ធផលត្រូវបានផ្ញើជូនដល់អ្នកដែលត្រូវការពត៌មានទាំងនេះ ដើម្បីធ្វើសកម្មភាពផ្នែកសុខាភិបាលសាធារណៈ ។

- ***ជាប់ជាប្រចាំ និងជាប្រព័ន្ធ (Ongoing and systematic)*** : ការប្រមូលពត៌មានត្រូវបានអនុវត្តទៅតាមបែបបទគំរូ (standard) ដែលមានលក្ខណៈទៀងទាត់ (consistent) គ្រប់ពេលវេលា និងគ្រប់ទីកន្លែងទាំងអស់ ។

**គម្មវត្ថុនៃការអង្កេតតាមដានជំងឺ**

| **គម្មវត្ថុ** | **ការអនុវត្ត** |
|---|---|
| - បង្កើតការយល់ដឹងរបស់ប្រជាជនលើបញ្ហាសុខភាព | ការជំរុញ ឱ្យមានការចូលរួម (mobilization) |
| - បង្ហាញឱ្យឃើញអំពីវិសាលភាពនៃជំងឺណាមួយនៅក្នុងចំណោមក្រុមប្រជាជន | ការធ្វើផែនការ (planning) |
| - កំណត់រកឃើញអំពីក្រុមប្រជាជន (Population subgroup) ដែលមានការប្រឈមមុខនឹងគ្រោះថ្នាក់នៃការកើតជំងឺជាក់លាក់ណាមួយ | ការផ្តោតអន្តរាគមន៍លើក្រុមដែលកំណត់រកឃើញ (targeting) |
| - ស្រាវជ្រាវរក (detect) ការផ្លាស់ប្តូរស្ថានភាពសុខភាពតាមពេលវេលា | ការវាយតំលៃ (evaluation) |
| - កំណត់រកឃើញបែបផែនមិនប្រក្រតី (unusual patterns) | ការអង្កេតរក (investigation) |
| - ផ្តល់នូវចំណេះដឹងថ្មីៗស្តីអំពីសុខភាព និងការធ្វើអន្តរាគមន៍លើកកំពស់សុខភាព | ការស្រាវជ្រាវ (research) |

**អ្វីដែលការអង្កេតតាមដានមិនអាចជួយយើងបាន**

- មិនអាចតាមដានត្រួតពិនិត្យសុខភាពនៃបុគ្គលម្នាក់ៗបានទេ
- មិនអាចបង្ហាញភស្តុតាងថា តើការធ្វើអន្តរាគមន៍ទៅលើបញ្ហាសុខភាពណាមួយ អាចនឹងមាន ឬគ្មានប្រសិទ្ធិភាព ឬទេ ។

**តើអ្នកណាជាអ្នកទទួលខុសត្រូវក្នុងការអង្កេតតាមដានជំងឺ ?**

- ក្រសួងសុខាភិបាល : ថ្នាក់ជាតិ ខេត្ត
- ការិយាល័យសុខាភិបាលសាធារណៈ : ថ្នាក់ស្រុក
- មណ្ឌលសុខភាព ឬ គ្លីនិកកាមរោគ
- ស្ថាប័នបណ្តុះបណ្តាល ឬ ស្ថាប័នពិសេសៗផ្សេងៗទៀត : ជួសមុខឱ្យអាជ្ញាធរសុខាភិបាល

**តើគួរធ្វើការអង្កេតតាមដានជំងឺប៉ុន្មានដង ?**

- អាចធ្វើជាប់ជាប្រចាំ (continuous)
- តាមកាលកំណត់ទៀងទាត់ (regular)
- ឬ ធ្វើយូរៗម្តង (occasional)

**តើការអង្កេតតាមដានជំងឺវាស់ស្ទង់អ្វីខ្លះ ?**

- **អត្រាប្រេវ៉ាឡង់** : គឺសមាមាត្រនៃមនុស្សនៅក្នុងក្រុមប្រជាជនណាមួយដែលកើតជំងឺពិសេសមួយ ក្នុងរយៈពេលជាក់លាក់ណាមួយ ។ ឧទាហរណ៍ : "នៅចុងឆ្នាំ ១៩៩៦ អត្រាប្រេវ៉ាឡង់នៃជំងឺទឹកនោមផ្អែមមាន 5% " មានន័យថា មានប្រជាជនចំនួន 5% កើតជំងឺទឹកនោមផ្អែមនៅចុង ឆ្នាំ ១៩៩៦ ។

- **អត្រាអាំងស៊ីដង់** (Incidence) : គឺជាសមាមាត្រនៃចំនួនមនុស្សដែលមានជំងឺណាមួយក្នុងកំឡុងពេលណាមួយជាក់លាក់ ធៀបទៅនឹងចំនួនមនុស្សដែលមិនកើតជំងឺនេះចាប់តាំងពីពេលចាប់ផ្តើមនៃរយៈពេលនេះ ។ ឧទាហរណ៍ : " អត្រាអាំងស៊ីដង់នៃជំងឺរបេងនៅឆ្នាំ ១៩៩៦ មាន 0.01% " មានន័យថា មានមនុស្ស 0.01% កើតជំងឺរបេងនៅចុងឆ្នាំ ១៩៩៦ ក្នុងចំណោមចំនួនមនុស្សដែលមិនកើតរបេង ។

**កំណត់សំគាល់អំពីអាំងស៊ីដង់ និងប្រេវ៉ាឡង់**

- និយមន័យនៃអត្រាប្រេវ៉ាឡង់ណែនាំឱ្យមានការវាយតំលៃបញ្ហាសុខភាពនៃក្រុមប្រជាជនណាមួយក្នុងចំណុចណាមួយនៃពេលវេលា ក៏ប៉ុន្តែជាក់ស្តែងការវាយតំលៃនេះប្រព្រឹត្តទៅក្នុងរយៈពេលជាច្រើនសប្តាហ៍ ឬ ខែ ។

- និយមន័យនៃអាំងស៊ីដង់ណែនាំឱ្យមានការវាយតំលៃស្ថានភាពសុខភាពរបស់ក្រុមប្រជាជនពីរដង គឺត្រូវកំណត់រកអ្នកដែលពុំមានបញ្ហាសុខភាពនៅពេលចាប់ផ្តើមនៃកំឡុងពេលណាមួយ និងកំណត់រកឃើញអ្នកដែលកើតជំងឺនៅពេលចុងបញ្ចប់នៃកំឡុងពេលនោះ ។

យោលទៅតាមប្រភេទនៃបញ្ហាសុខភាព គេអាចវាស់នូវអត្រាប្រេវ៉ាឡង់ និងអាំងស៊ីដង់បានតាមរយៈ

- ការវាយតំលៃផ្នែកគ្លីនិក
- ការធ្វើតេស្តឈាម ឬ តេស្តមន្ទីរពិសោធន៍ផ្សេងៗទៀត
- ការថតឆ្លុះដោយប្រើកាំរស្មី X ឬ បច្ចេកទេសស្រាវជ្រាវផ្សេងៗទៀតដែលប្រហាក់ប្រហែលគ្នា
- ការប្រើកំរងសំណួរ (Questionnaire)

**ការប្រើប្រាស់អត្រាប្រេវ៉ាឡង់ និងអាំងស៊ីដង់**

**ប្រេវ៉ាឡង់** បញ្ជាក់អំពីវិសាលភាព (extent) នៃបញ្ហាសុខភាពណាមួយដែលកំពុងមាននៅក្នុងក្រុមប្រជាជនណាមួយ ។ វាមានសារៈប្រយោជន៍សំរាប់សេវានានា ដែលមានភារកិច្ចលើកគំរោងផែនការថែទាំបញ្ហាសុខភាពរ៉ាំរ៉ៃ និងសំរាប់វាយតំលៃ pool នៃជំងឺឆ្លង ។

**អាំងស៊ីដង់** បង្ហាញអំពីអត្រា (Rate) នៃករណីជំងឺថ្មីដែលកំពុងកើតមានឡើង ។ វាមានប្រយោជន៍សំរាប់ការធ្វើផែនការ និងវាយតំលៃសេវាបង្ការជំងឺ ។

**លក្ខណៈសំគាល់របស់បុគ្គលដែលត្រូវបានយកមកប្រើប្រាស់ជាញឹកញាប់ក្នុងការអង្កេតតាមដាន**

- រោគវិនិច្ឆ័យ
- អាយុ
- ភេទ
- កាលបរិច្ឆេទ
- ទីតាំងភូមិសាស្ត្រ
- (ទីកន្លែងកំណើត)
- (ឋានៈក្នុងសង្គម)
- (ជនជាតិ)
- (មុខរបរ)

## គោលការណ៍នៃការធ្វើអង្កេតតាមដាន

- **ភាពងាយស្រួល** (simplicity) ប្រព័ន្ធអង្កេតតាមដានមួយដែលមានលក្ខណៈស៊ាំញ៉ាំពេក នឹងពុំអាចសំរេចតាមគោលដៅវាបានទេ ។ **សូមកុំច្រឡំ** ការអង្កេតតាមដាន (surveillance) ជាមួយនឹងការស្រាវជ្រាវ (research) ។

- **ភាពអាចទទួលយកបាន** (Acceptability)
- ពីសំណាក់ក្រុមប្រជាជន
- ពីសំណាក់បុគ្គលិកសុខាភិបាល
- ពីសំណាក់អ្នកទទួលខុសត្រូវក្នុងប្រព័ន្ធពត៌មានសុខាភិបាល

- **ការគ្របដណ្តប់** (Coverage) : ប្រព័ន្ធអង្កេតតាមដានត្រូវផ្តល់ពត៌មានដែលទាក់ទងទៅនឹងក្រុមប្រជាជនទាំងមូលដែលស្ថិតនៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងផ្នែកសុខាភិបាល (health jurisdiction)

- **ភាពត្រឹមត្រូវ** (accuracy) : ពត៌មានដែលប្រមូលយកបានត្រូវតែមានលក្ខណៈអាចយកជាការបាន (valid) និងត្រូវបានបញ្ជាក់ថាពិត (validated) ។

- **ភាពទាន់ពេលវេលា** (Timeliness): រយៈពេល (timeframe) សំរាប់ការរាយការណ៍អំពីការវិភាគ និងការផ្សព្វផ្សាយត្រូវឆ្លើយតបទៅនឹងតំរូវការរបស់ប្រព័ន្ធសុខាភិបាលដែលមានការវិវត្តជាប្រចាំ ។

- **លទ្ធផល** (outcomes) : ការប្រមូលពត៌មានត្រូវមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយការធ្វើសកម្មភាពនៃប្រព័ន្ធសុខាភិបាល ។
- **ការរក្សាការសំងាត់** (Confidentiality / Privacy) : ពត៌មានដែលប្រមូលបានត្រូវរក្សាទុកដោយមានការលាក់ការសំងាត់ ។ បើពុំដូច្នោះទេ វានឹងធ្វើអោយមានការប៉ះពាល់ដល់ទំនុកចិត្តលើប្រព័ន្ធសុខាភិបាល ។

## ប្រភេទផ្សេងៗនៃការធ្វើអង្កេតតាមដាន

1. **ការរាយការណ៍ជាប្រចាំនូវករណីជំងឺមកកាន់ស្ថាប័នកណ្តាល (Routine Centralized Case Reporting) អាចហៅម្យ៉ាងទៀតថាជាការអង្កេតតាមដានក្នុងលក្ខណៈអកម្ម (Passive surveillance) :**

<u>ករណីនៃបញ្ហាសុខភាពដែលបានធ្វើរោគវិនិច្ឆ័យហើយ ត្រូវបានរាយការណ៍មកកាន់ផ្នែកអង្កេតតាមដាន ។ ការរាយការណ៍អាចធ្វើទៅដោយការស្ម័គ្រចិត្ត ឬ តាមផ្លូវច្បាប់ ។</u>

**<u>គុណសម្បត្តិ</u>**

- ងាយអនុវត្ត - មានតំលៃថោក
- គ្របដណ្តប់បានក្រុមប្រជាជនទាំងអស់

**<u>គុណវិបត្តិ</u> :** ការរាយការណ៍ទាបជាងការពិត (under reporting) បណ្តាលមកពី

- ការធ្វើរោគវិនិច្ឆ័យទាបជាងការពិត
- ធ្វើរោគវិនិច្ឆ័យរួច ប៉ុន្តែមិនបានរាយការណ៍ (ដោយសារជាប់រវល់ពេក ឬ មិនអើពើចំពោះការរាយការណ៍)
- ធ្វើការរាយការណ៍ ប៉ុន្តែមិនមានការបញ្ជាក់ឱ្យបានច្បាស់លាស់
- ជំងឺដែលគ្មានបង្ហាញរោគសញ្ញា អាចមិនត្រូវបានធ្វើរោគវិនិច្ឆ័យ
- អ្នកជំងឺមិនទៅទទួលយកសេវាថែទាំ

**2. ការតាមដានត្រួតពិនិត្យអត្រាកាមរោគក្នុងចំណោមក្រុមប្រជាជន ឬ កន្លែងផ្តល់សេវាគ្លីនិកមួយចំនួន (Monitoring in selected population groups or clinical sites)**

ការប្រមូលយកពត៌មាន និងការវិភាគដោយទៀងទាត់នូវទិន្នន័យ ត្រូវបានបង្កើតឡើងក្នុងចំណោមក្រុមប្រជាជន ឬទីកន្លែងផ្តល់សេវាថែទាំគ្លីនិកនានា ដែលមានរួចជាស្រេចនូវបែបបទសំរាប់ធ្វើការវាយតំលៃ ។ ឧទាហរណ៍ :

- មន្ទីរពេទ្យ
- គ្លីនិកឯកទេស
- មជ្ឈមណ្ឌលផ្តល់ឈាម

**<u>គុណសម្បត្តិ</u>**

- មានការរាយការណ៍ពេញលេញពីកន្លែងដែលបានជ្រើសរើស
- ពត៌មានមានលក្ខណ:ត្រឹមត្រូវ
- មិនសូវចំណាយថវិកាច្រើន

**<u>គុណវិបត្តិ</u>**

- ការគ្របដណ្តប់ត្រឹមកន្លែងមួយចំនួនប៉ុណ្ណោះ

3. **ការធ្វើអង្កេតពិសេសនានាក្នុងចំណោមប្រជាជនជាក់លាក់ណាមួយ (Special surveys of a selected population)**

ការអង្កេត (survey) ត្រូវបានរៀបចំឡើងក្នុងបំណងជាក់លាក់ដើម្បីវាស់ស្ទង់នូវប្រេវ៉ាឡង់ ឬ អាំងស៊ីដង់នៃបញ្ហាសុខភាពណាមួយ ។ ក្រុមប្រជាជនដែលជាកម្មវត្ថុនៃការអង្កេតអាចជា :

- អ្នកដែលធ្លាប់មានទំនាក់ទំនងជាមួយប្រព័ន្ធសុខាភិបាលរួចមកហើយ ។ ឧទាហរណ៍ : ស្ត្រីមានផ្ទៃពោះ

- អ្នកដែលត្រូវបានចាត់ទុកថា ជាអ្នកមានការប្រឈមមុខនឹងគ្រោះថ្នាក់នៃការកើតជំងឺ ដែលរកឃើញដោយការអង្កេតតាមដាន (surveillance) ឬ ការសិក្សាស្រាវជ្រាវនានា (study) ឧទាហរណ៍ : ស្ត្រីរកស៊ីផ្លូវភេទ

- អ្នកដែលអាចជួបទាក់ទងបានតាមមធ្យាបាយណាមួយ ដូចជា : ស្ថាប័ននានា (សាលារៀនយោធាជាដើម) ។

**<u>គុណសម្បត្តិ</u>**

- មានភាពត្រឹមត្រូវ
- មានការគ្របដណ្តប់បានទូលំទូលាយ
- មានការត្រួតពិនិត្យគុណភាពបានល្អ

**<u>គុណវិបត្តិ</u>**

- មានតំលៃថ្លៃ
- ប្រជាជនដែលបានជ្រើសរើសចូលរួមក្នុងការធ្វើអង្កេត ពុំអាចតំណាងឱ្យប្រជាជនទូទៅបាន

**ការអង្កេតតាមដានជំងឺកាមរោគ (STD Surveillance)**

**ហេតុអ្វីបានជាយើងត្រូវការនូវ គោលការណ៍ណែនាំពិសេស ស្តីអំពីការអង្កេតតាមដានជំងឺកាមរោគ ?**

ការអង្កេតតាមដានជំងឺកាមរោគពុំមានអ្វីប្លែកពីការអង្កេតតាមដានជំងឺដទៃៗទៀតទេ ។ គេធ្វើវាក្នុងបំណងដូចគ្នា ហើយវិធីអនុវត្តក៏ប្រហាក់ប្រហែលគ្នានឹងការអង្កេតតាមដានជំងឺឆ្លងដទៃៗទៀតដែរ ។ ក៏ប៉ុន្តែយើងត្រូវតែពិចារណាទៅលើទិដ្ឋភាពជាច្រើននៃជំងឺកាមរោគ ដើម្បីរៀបចំបង្កើតនិងគ្រប់គ្រងសកម្មភាពការអង្កេតតាមដាននេះ ។

- ចំពោះមនុស្សភាគច្រើន ការកើតជំងឺកាមរោគបង្កឱ្យមានការអៀនខ្មាស ។ ប្រសិនបើការធ្វើអង្កេតតាមដានជំងឺកាមរោគមានលក្ខណៈជាសាធារណៈ ឬ ពុំមានការរក្សាការសំងាត់ទេនោះ អ្នកជំងឺកាមរោគនឹងគេចវេះមិនទៅទទួលសេវាថែទាំនៅកន្លែងដែលចូលរួមក្នុងការធ្វើអង្កេតនោះទេ ។ ដូច្នេះគេមិនអាចធ្វើរោគវិនិច្ឆ័យនិងព្យាបាលអ្នកទាំងនោះបានទេ ជាហេតុនាំឱ្យទិន្នន័យដែលប្រមូលបាននោះមានលក្ខណៈមិនត្រឹមត្រូវ ។

- មនុស្សមួយចំនួន ដែលមានការប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់នៃការកើតជំងឺកាមរោគ ស្ថិតនៅក្នុងក្រុមដែលមិនសូវមានការយកចិត្តទុកដាក់ពីសង្គម (marginalised) ឬទទួលការមាក់ងាយ ពីអ្នកដទៃ (stigmatised) ។ ប្រសិនបើការធ្វើអង្កេតតាមដានប្រព្រឹត្តទៅដោយមិនមានការប្រុងប្រយ័ត្នទេនោះក្រុមមនុស្សទាំងនោះអាចត្រូវបានគេចោទថា ជាប្រភពចំលងកាមរោគ និងមេរោគអេដស៍ ។ លើសពីនេះទៅទៀត ប្រសិនបើមានរឿងបែបនេះកើតឡើងមែន អ្នកទាំងនោះនឹងគេចវេះមិនទៅទទួលសេវាថែទាំកាមរោគទេ ។

- ការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគជាច្រើន ទាមទារអោយមានការពិនិត្យប្រដាប់បន្តពូជដែលទាមទារនូវជំនាញឯកទេសក្នុងការពិនិត្យ ហើយដែលធ្វើឱ្យអ្នកជំងឺអៀនខ្មាស ។

- ការបកស្រាយពត៌មានដែលបានមកពីការធ្វើអង្កេតតាមដានជំងឺកាមរោគ ទាមទារឱ្យមានការយល់ដឹងអំពីពត៌មានដែលទាក់ទងនឹងការប្រព្រឹត្តផ្លូវភេទ ដែលពុំទាន់មាននៅឡើយ ហើយត្រូវចំណាយថវិកាយ៉ាងច្រើនក្នុងការប្រមូលយក ។

- នៅក្នុងបណ្តាប្រទេសជាច្រើន ប្រព័ន្ធសុខាភិបាល បានផ្តល់អាទិភាពតិចតួចដល់ការប្រយុទ្ធនឹងជំងឺកាមរោគ ជាហេតុធ្វើអោយអ្នកគ្រប់គ្រងកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគជួបប្រទះនឹងការលំបាកក្នុងការរកថវិកាសំរាប់កម្មវិធីធ្វើការអង្កេតតាមដាននេះ ។ ការអនុម័តលើគោលការណ៍ណែនាំរួម ស្តីអំពីការអង្កេតតាមដានអាចនាំឱ្យមន្ត្រីសុខាភិបាលដែលបំរើការងារនៅតាមបណ្តាប្រទេសនានា ចែករំលែកបទពិសោធន៍គ្នាទៅវិញទៅមកស្តីអំពីបញ្ហាកាមរោគនិងអំពីជោគជ័យឬការលំបាកក្នុងការបង្ការនិងព្យាបាលកាមរោគ ។

### តើការអង្កេតតាមដានអាចឆ្លើយតបចំពោះបញ្ហាសុខាភិបាលសាធារណៈអ្វីខ្លះ ?

នៅពេលរៀបចំបង្កើតកម្មវិធីបង្ការទប់ស្កាត់ជំងឺកាមរោគមានបញ្ហាមួយចំនួនដែលអាចឆ្លើយតបបាន ដោយការអង្កេតតាមដានតែប៉ុណ្ណោះ ។ បញ្ហាសំខាន់ទាំងនោះមាន :

1. តើជំងឺកាមរោគប្រភេទណាខ្លះដែលកើតលើប្រជាជន ហើយមានមនុស្សប៉ុន្មាននាក់កើតជំងឺទាំង នេះ ? តើអត្រាផ្ទុកមេរោគទាំងនេះ មានភាពខុសៗគ្នាទៅតាមក្រុមប្រជាជនផ្សេងៗពីគ្នាដែរឬទេ ?
2. តើក្នុងចំណោមអ្នកកើតជំងឺកាមរោគ មានមនុស្សប៉ុន្មាននាក់ មានរោគសញ្ញា ?
3. តើក្នុងចំណោមអ្នកកើតជំងឺកាមរោគដែលមានរោគសញ្ញាមានចំនួនប៉ុន្មាននាក់ ដែលបានស្វែងរកការព្យាបាល ? តើការស្វែងរកការថែទាំព្យាបាល ប្រែប្រួលទៅតាមក្រុមមនុស្សដែរឬទេ ?
4. ប្រសិនបើមានកើតជំងឺប្រមេះទឹកបាយ (gonorrhea) និងជំងឺ Chancriod កើតឡើង តើថ្នាំដែលប្រើប្រាស់សំរាប់ព្យាបាលជំងឺទាំងអស់នេះមានប្រសិទ្ធិភាពដល់កំរិតណាដែរ ?

គេត្រូវការនូវធនធានមនុស្ស និងថវិកាច្រើនសន្ធឹកសន្ធាប់ណាស់ដើម្បីឆ្លើយតបបាននឹងបញ្ហានិមួយៗខាងលើនេះឱ្យបានត្រឹមត្រូវ ។ ធនធានទាំងនេះទំនងជាពុំអាចរកបានទាំងអស់ ក្នុងពេលជាមួយគ្នា នោះទេ ហើយក្នុងការអនុវត្តជាក់ស្តែង គេចាំបាច់ត្រូវធ្វើសំរេចយកបញ្ហាណាមួយក្នុងចំណោមបញ្ហាទាំងនេះ មកដោះស្រាយជាបន្ទាន់ ។ ផ្នែកបន្ទាប់ទៅនេះនឹងពិពណ៌នាអំពីវិធីនានាដែលត្រូវបានយកមកប្រើប្រាស់ជាញឹកញាប់ដើម្បីឆ្លើយតបនឹងបញ្ហាទាំងនោះ ។

**វិធីនានាដែលប្រើប្រាស់ក្នុងការអង្កេតតាមដានអត្រាជំងឺកាមរោគ (Methods for STD surveillance)**

**1. ការរាយការណ៍ជាប្រចាំនូវករណីជំងឺកាមរោគដែលបានធ្វើរោគវិនិច្ឆ័យមកកាន់ស្ថាប័នកណ្តាល**

**<u>គោលការណ៍</u>** :

នៅក្នុងទីតាំងភូមិសាស្ត្រ ឬ រដ្ឋបាលកំណត់មួយ រាល់រោគវិនិច្ឆ័យនៃជំងឺកាមរោគត្រូវរាយការណ៍ ទៅកាន់ផ្នែក / អង្គភាពមជ្ឈឹម ដែលមានទីស្នាក់ការស្ថិតនៅក្នុងក្រសួងសុខាភិបាល ។ ជួនកាលគេហៅគោលការណ៍ត្រួតពិនិត្យតាមដានបែបនេះ ថាជាការអង្កេតតាមដានអកម្ម (passive surveillance) ។

ឧទាហរណ៍ : ការរាយការណ៍អំពីរោគវិនិច្ឆ័យជំងឺប្រមេះទឹកបាយថ្មីៗ ដោយបុគ្គលិកសុខាភិបាលទៅកាន់ក្រសួងសុខាភិបាល ។

**<u>លក្ខណៈនៃការជ្រើសរើសវិធីអង្កេតតាមដាន</u> (Optional feature)**

- របាយការណ៍អាចធ្វើជូនដោយបុគ្គលិកសុខាភិបាល ឬ មន្ទីរពិសោធន៍
- របាយការណ៍អាចធ្វើជូនតាមផ្លូវច្បាប់ ឬ តាមគោលការណ៍សហប្រតិបត្តិការ (ស្ម័គ្រចិត្ត)
- របាយការណ៍អាចធ្វើជូនស្ថាប័នកណ្តាលក្នុងចន្លោះពេលមួយទៀងទាត់ ឧទាហរណ៍រៀងរាល់ខែ ។

## លទ្ធផលសំខាន់ៗដែលរំពឹងចង់បាន

- ចំនួន និងលក្ខណៈសំគាល់នៃអ្នកកើតជំងឺកាមរោគជាក់លាក់ណាមួយក្នុងកំឡុងពេលកំណត់និមួយៗ

## គុណសម្បត្តិ

- អាចគ្របដណ្តប់លើប្រជាជនទូទាំងប្រទេស
- អាចប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលដែលមានស្រាប់ (បុគ្គលិកសុខាភិបាល,មន្ទីរពិសោធន៍) ឱ្យធ្វើរបាយការណ៍

## គុណវិបត្តិ

- មិនបានរាយការណ៍ អ្នកជំងឺកាមរោគដែលមិនបានមកស្វែងរកការព្យាបាលថែទាំ
- ទោះបីជាបុគ្គលិកសុខាភិបាលជាច្រើនបានចូលរួមក្នុងការធ្វើរោគវិនិច្ឆ័យក៏ដោយ ក៏ពុំមែនអ្នកទាំងអស់នោះ ផ្តល់អាទិភាពខ្ពស់ដល់ការរាយការណ៍ករណីជំងឺកាមរោគនោះទេ ដូច្នេះអាចនឹងមានការរាយការណ៍ទាបជាងការពិត ។

## តើការរាយការណ៍ជាប្រចាំអាចឆ្លើយតបនឹងសំនួរគន្លឹះនៃការធ្វើអង្កេតតាមដានបានល្អដល់កំរិតណា ?

1. ការរាយការណ៍ជាប្រចាំអាចផ្តល់នូវពត៌មាន ដែលមានប្រយោជន៍ស្តីអំពីបែបផែននៃជំងឺកាមរោគនៅក្នុងចំណោមប្រជាជន ក៏ប៉ុន្តែវាមានការលំបាកក្នុងការបកស្រាយដោយសារការធ្វើរោគវិនិច្ឆ័យនិងការរាយការណ៍មានកំរិតទាបជាងការពិត ។

2. ការរាយការណ៍ជាប្រចាំប្រាប់យើងឱ្យដឹងអំពីករណីជំងឺដែលមិនលេចចេញជារោគសញ្ញាបានតិចតួចណាស់ លើកលែងតែយើងស្រាវជ្រាវរកជំងឺនោះក្នុងចំណោមអ្នកដែលមកពិគ្រោះ ដោយសារមូលហេតុផ្សេងៗពីនេះ ឧទាហរណ៍ : ការស្រាវជ្រាវរកមេរោគស្វាយលើស្ត្រីមានផ្ទៃពោះជាដើម ។

3. ការរាយការណ៍ជាប្រចាំពុំបានផ្តល់ពត៌មានបានច្រើនស្តីអំពីករណីជំងឺកាមរោគលើអ្នកជំងឺដែលពុំបានស្វែងរកការព្យាបាលទេ ។

4. ការរាយការណ៍ជាប្រចាំពុំអាចយកទៅប្រើប្រាស់ដើម្បីដឹងអំពីប្រសិទ្ធិភាពនៃថ្នាំអង់ទីប៊ីយោទិកដោយផ្ទាល់បានទេ លើកលែងតែវាត្រូវធ្វើឡើងអមជាមួយការបញ្ជូនវត្ថុវិភាគ (specimens) ទៅកាន់មន្ទីរពិសោធន៍ដើម្បីធ្វើការបណ្តុះ និងធ្វើតេស្តរកមេរោគ ។

## តើយើងត្រូវប្រើការធ្វើរបាយការណ៍ជាប្រចាំនៅពេលណា ?

- ប្រសិនបើបុគ្គលិកសុខាភិបាលមានចំនួនតិចតួច ដើម្បីបំរើសេវាជូនប្រជាជន ដូចជានៅក្នុងកោះតូចមួយក្នុង ឬ សហគមន៍តូចមួយ ឬ នៅតំបន់ដែលមានសេវាថែទាំសុខភាពបឋមសាធារណៈប្រមូលផ្តុំ (centralised) និង

- ប្រសិនបើអ្នកផ្តល់សេវាថែទាំសុខភាពភាគច្រើនមានសមត្ថភាព និងឆន្ទៈដើម្បីធ្វើការកត់ត្រា និងរាយការណ៍ពត៌មាន ស្តីអំពីជំងឺកាមរោគដែលខ្លួនបានធ្វើរោគវិនិច្ឆ័យរួច ។

## ពេលណាដែលយើងពុំគួរប្រើប្រព័ន្ធរាយការណ៍ជាប្រចាំ ?

- ប្រសិនបើមានអ្នកផ្តល់សេវាថែទាំជាច្រើនបំរើសេវាជូនប្រជាជន ឧទាហរណ៍ ដូចជានៅក្នុងទីក្រុងដ៏ធំមួយជាដើម ។

- ប្រសិនបើអ្នកផ្តល់សេវាថែទាំទំនងជាគ្មានចិត្តសហប្រតិបត្តិការក្នុងការកត់ត្រា និងរាយការណ៍នូវការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគទេនោះ ។

2. **ការតាមដានត្រួតពិនិត្យជាប្រចាំដោយការធ្វើតេស្តរកជំងឺកាមរោគក្នុងចំណោមប្រជាជន ឬក្នុងចំណោមកន្លែងផ្តល់សេវាថែទាំនានាដែលបានជ្រើសរើស (Monitoring routine STD Testing in selected population groups or clinical sites)**

<u>គោលការណ៍</u>

ការធ្វើរោគវិនិច្ឆ័យ និងការធ្វើតេស្តមន្ទីរពិសោធន៍រកជំងឺកាមរោគនៅលើក្រុមប្រជាជន និងកន្លែងផ្តល់សេវាមួយចំនួនកំពុងតែមានដំណើរការជាប្រចាំ ។ គោលការណ៍នៃការធ្វើអង្កេតតាមដានបែបនេះគឺត្រូវប្រមូលនូវពត៌មានស្តីអំពីរាល់អ្នកជំងឺដែលបានទទួលការធ្វើតេស្ត និងចងក្រង និងវិភាគពត៌មានទាំងនោះយ៉ាងទៀងទាត់ ។

ឧទាហរណ៍ :

1. អ្នកផ្តល់ឈាម ឬស្ត្រីមានផ្ទៃពោះត្រូវទទួលការធ្វើតេស្តឈាមរកមេរោគស្វាយ
2. ស្ត្រីរកស៊ីផ្លូវភេទដែលមកកាន់គ្លីនិកកាមរោគដើម្បីទទួលនូវការធ្វើតេស្តស្រាវជ្រាវរកវត្តមានជំងឺកាមរោគ

## លក្ខណៈនៃការជ្រើសរើសវិធីអង្កេតតាមដាន

- ការត្រួតពិនិត្យតាមដានអាចធ្វើនៅតាមកន្លែងផ្តល់សេវាតែមួយ ឬ ក៏កន្លែងផ្តល់សេវាទាំងនោះអាចប្រមូលផ្តុំគ្នាដើម្បីសហការអនុវត្តការប្រមូលយកពត៌មានតាមបែបបទតែមួយរួមគ្នា
- ការចងក្រង និងវាយតំលៃទិន្នន័យស្តីអំពីការធ្វើតេស្តរកកាមរោគអាចប្រព្រឹត្តទៅជាប់ជាប្រចាំ ឬ ក្នុងចន្លោះពេលជាក់លាក់ណាមួយ (ឧទាហរណ៍ រយៈពេលមួយខែជារៀងរាល់ឆ្នាំ) ។

## លទ្ធផលសំខាន់ៗដែលរំពឹងចង់បាន

- សមាមាត្រនៃអ្នកជំងឺ ដែលបានទទួលការធ្វើតេស្តឃើញថាមានជំងឺកាមរោគជាក់លាក់ណាមួយ
- ប្រសិនបើមានការស្រង់ប្រវត្តិជំងឺ, វិធីអង្កេតតាមដាននេះអាចប្រាប់អំពីសមាមាត្រ នៃអ្នកជំងឺកាមរោគជាក់លាក់ណាមួយដែលមានរោគសញ្ញាហើយ ប្រសិនបើមានការពិនិត្យអ្នកជំងឺទៀតនោះ (ទោះបីជាអ្នកជំងឺនោះមាន ឬ គ្មានរោគសញ្ញាក៏ដោយ) នោះវិធីនេះអាចបង្ហាញអំពីសមាមាត្រនៃអ្នកជំងឺកាមរោគដែលគ្រូពេទ្យបានរកឃើញថាមានរោគសញ្ញា ។

## គុណសម្បត្តិ

- រកឃើញករណីជំងឺទាំងអស់នៅក្នុងចំណោមប្រជាជនដែលយើងធ្វើអង្កេត ទោះបីជាគេមាន ឬគ្មានរោគសញ្ញាក៏ដោយ
- ប្រើប្រាស់នូវហេដ្ឋារចនាសម្ព័ន្ធសុខាភិបាលដែលមានស្រាប់ (បុគ្គលិកសុខាភិបាល មន្ទីរពិសោធន៍) ក្នុងការធ្វើតេស្តរកវត្តមាននៃជំងឺ

## គុណវិបត្តិ

- មានការលំបាកដើម្បីឱ្យដឹងថា តើលទ្ធផលដែលបានមកពីកន្លែងដែលបានជ្រើសរើសនោះ អាចតំណាងបាននូវប្រជាជនចំណុចទាំងមូលបានល្អដល់កំរិតណា ។ ឧទាហរណ៍ : ឧបមាថាស្ត្រីដែលទៅពិគ្រោះជំងឺនៅគ្លីនិកថែទាំសុខភាពមុនពេលសំរាលចំនួន 1% មានផ្ទុកជំងឺស្វាយ ។ តើយើងអាចស្មានបានថា តួលេខនេះតំណាងឱ្យស្ត្រីមានផ្ទៃពោះដែលជាប្រជាជនចំណុចទាំងមូលបានដែរឬទេ ? តើយើងអាចស្មានបានថា តើវាតំណាងឱ្យអត្រានៃជំងឺក្នុងចំណោមស្ត្រីដែលស្ថិតនៅអាយុអាចមានគភ៌បានដែរឬទេ? គ្មាននរណាម្នាក់អាចអះអាងអំពីបញ្ហានេះបានច្បាស់លាស់ទេ។

- ប្រសិនបើ បុគ្គលិកសុខាភិបាលជាច្រើនបានចូលរួមក្នុងការងារផ្តល់សេវាធ្វើតេស្តរកវត្តមាននៃជំងឺកាមរោគនេះក៏ដោយ ក៏ពុំមែនអ្នកទាំងអស់នោះធ្វើការងារនេះទៅតាមស្តង់ដារតែមួយគ្រប់ពេលនោះទេ។

**តើការតាមដានត្រួតពិនិត្យជាប្រចាំនៃអត្រាជំងឺកាមរោគ តាមរយៈការធ្វើតេស្តរកវត្តមានមេរោគកាមរោគ ក្នុងចំណោមក្រុមប្រជាជនចំណុច ឬ កន្លែងផ្តល់សេវាដែលបានជ្រើសរើសអាចឆ្លើយតបទៅនឹងសំណួរគន្លឹះស្តីពីការធ្វើអង្កេតតាមដានបានល្អដល់កំរិតណា ?**

1. ការតាមដានត្រួតពិនិត្យជាប្រចាំដោយការធ្វើតេស្តរកវត្តមានមេរោគកាមរោគ អាចផ្តល់ពត៌មានបានយ៉ាងល្អ ស្តីពីសមាមាត្រនៃអ្នកជំងឺកាមរោគដែលបានស្វែងរកសេវាថែទាំ និងអ្នកបានទទួលការធ្វើតេស្ត ។ លទ្ធផលទាំងនេះអាចយកលទ្ធផលទៅអនុវត្តចំពោះក្រុមប្រជាជនចំណុចទាំងមូលបាន (ដោយប្រុងប្រយ័ត្នពីព្រោះយើងពុំដឹងថា តើវាអាចតំណាងឱ្យក្រុមប្រជាជនចំណុចនេះបានដល់កំរិតណាទេ) ។

2. ការតាមដានត្រួតពិនិត្យជាប្រចាំដោយការធ្វើតេស្តរកវត្តមានមេរោគកាមរោគ អាចផ្តល់ពត៌មានអំពីសមាមាត្រនៃករណី អ្នកជំងឺដែលមានរោគសញ្ញាបានលុះត្រាតែការស្រង់ប្រវត្តិជំងឺត្រូវបានធ្វើជា ប្រចាំក្នុងការងារអនុវត្តប្រចាំថ្ងៃ ។ ការពិនិត្យអ្នកជំងឺត្រូវធ្វើជាចាំបាច់ ប្រសិនបើគេកំណត់រកសមាមាត្រ នៃអ្នកជំងឺដែលបានរកឃើញថាមានរោគសញ្ញា ។

3. ការតាមដានត្រួតពិនិត្យជាប្រចាំដោយការធ្វើតេស្តនឹងផ្តល់នូវពត៌មាន ស្តីពីការស្វែងរកការព្យាបាលរបស់អ្នកជំងឺកាមរោគ លុះណាតែការស្រង់ប្រវត្តិ និងការពិនិត្យអ្នកជំងឺត្រូវបានធ្វើជាប្រចាំតែ ប៉ុណ្ណោះដែលការនេះហាក់ដូចជាពុំអាចធ្វើទៅបានគ្រប់ពេលវេលានោះទេ ។

4. ការតាមដានត្រួតពិនិត្យជាប្រចាំដោយសារការធ្វើតេស្តអាចប្រើប្រាស់ក្នុង ការធ្វើតេស្តដើម្បីអោយដឹងពីប្រសិទ្ធិភាពនៃថ្នាំអង់ទីប៊ីយូទិក ប្រសិនបើការបញ្ជូន Specimens ទៅកាន់មន្ទីរពិសោធន៍ដើម្បីធ្វើការបណ្តុះ និងធ្វើតេស្តរកមេរោគត្រូវបានធ្វើក្នុងពេលជាមួយគ្នា ។

**តើនៅពេលណាត្រូវប្រើការតាមដានត្រួតពិនិត្យជាប្រចាំដោយការធ្វើតេស្តរកជំងឺកាមរោគ នៅក្នុងចំណោមប្រជាជន ឬ កន្លែងផ្តល់សេវានានាដែលបានជ្រើសរើស ?**

- ប្រសិនបើការធ្វើតេស្តនិងធ្វើរោគវិនិច្ឆ័យជំងឺកាមរោគនៅក្នុងចំណោមក្រុមប្រជាជន ឬ កន្លែងផ្តល់សេវាពិសេសណាមួយត្រូវបានដាក់អោយដំណើរការរួចស្រេចហើយ ។

***និង***

- ការប្រមូលយកទិន្នន័យអាចធ្វើបានជាប្រចាំដោយគ្មានការប៉ះពាល់ទៅដល់សកម្មភាពផ្តល់សេវាថែទាំដែលកំពុងដំណើរការ ការធ្វើតេស្តនោះទេ ។

**តើពេលណាដែលយើងមិនត្រូវប្រើការតាមដានត្រួតពិនិត្យជាប្រចាំដោយការធ្វើតេស្តរកជំងឺកាមរោគនៅក្នុងចំណោមប្រជាជន ឬ កន្លែងផ្តល់សេវានានា ដែលបានជ្រើសរើស ?**

- ប្រសិនបើការអនុវត្តការធ្វើតេស្តរកជំងឺកាមរោគពុំអាចធ្វើបាននៅក្នុងចំណោមប្រជាជន ឬ កន្លែងផ្តល់សេវាទេ ។

***ឬ***

- ប្រសិនបើ ការប្រមូលទិន្នន័យទំនងជាអាចធ្វើឱ្យមានការរអាក់រអួលខ្លាំងដល់ដំណើរការផ្តល់សេវាថែទាំ។

**ការអង្កេតពិសេសៗអំពីអត្រាផ្ទុកជំងឺកាមរោគក្នុងចំណោមក្រុមប្រជាជន ឬ តាមកន្លែងដែលបានជ្រើសរើស (Special surveys of STDs in selected population groups or clinical sites)**

**គោលការណ៍**

ការពិនិត្យ និងធ្វើតេស្តរកវត្តមាននៃជំងឺកាមរោគត្រូវបានធ្វើឡើងលើក្រុមប្រជាជនណាមួយដែលអាចមិនបានទទួលនូវការវាយតំលៃនេះ

***ឧទាហរណ៍***

១ - ការពិនិត្យគ្លីនិករកវត្តមានជំងឺកាមរោគ ត្រូវបានធ្វើក្នុងរយៈពេលមួយជាក់លាក់លើស្ត្រីដែលមកទទួលសេវាពិនិត្យសុខភាពមុនសំរាលនៅក្នុងត្រីមាសទី១ នៃគភ៌ ។

២ - ការធ្វើតេស្តលើទឹកនោមរកវត្តមាននៃជំងឺប្រមេះទឹកបាយ (gonorrhea) ត្រូវធ្វើឡើងលើក្រុមយោធាដែលទើបជ្រើសរើសថ្មីក្នុងកំឡុងពេលមួយខែជារៀងរាល់ឆ្នាំ ។

លក្ខណៈជ្រើសរើស

- ក្រុមមនុស្សដែលត្រូវបានជ្រើសរើសក្នុងអង្កេត អាចមានទំនាក់ទំនងរួចជាស្រេចជាមួយសេវាគ្លីនិក (ឧទាហរណ៍ ស្ត្រីដែលមកពិនិត្យសុខភាពមុនសំរាល) ឬ អាចជាក្រុមដែលត្រូវបានអញ្ជើញឱ្យចូលរួមក្នុងការអង្កេត ដូច្នេះគឺក្រុមដែលត្រូវទទួលនូវទំនាក់ទំនងផ្តល់សេវាគ្លីនិកតាមបែបណាមួយ (ឧទាហរណ៍ ពលទាហានដែលទើបជ្រើសរើសថ្មី) ។

- ការធ្វើអង្កេតអាចធ្វើឡើងសារជាថ្មីក្នុងចន្លោះពេលមួយទៀងទាត់នៅលើក្រុមប្រជាជនដដែល ឬ ត្រូវធ្វើឡើងលើក្រុមប្រជាជនខុសៗគ្នាក្នុងពេលណាមួយ ។

## លទ្ធផលសំខាន់ៗដែលរំពឹងចង់បាន

- សមាមាត្រនៃអ្នកដែលទទួលការពិនិត្យ ឬ ការធ្វើតេស្តដែលកើតជំងឺកាមរោគជាក់លាក់ណា ដែលគេត្រូវការប្រមូលយកទិន្នន័យ ។

- ប្រសិនបើមានការប្រើប្រាស់ទាំងការវាយតំលៃគ្លីនិក និងការធ្វើតេស្តមន្ទីរពិសោធន៍ វិធីធ្វើអង្កេតតាមដាននេះ អាចផ្តល់នូវសមាមាត្រនៃអ្នកដែលកើតជំងឺកាមរោគជាក់លាក់ហើយមានសញ្ញា និងរោគសញ្ញាជំងឺ (signs and symptoms) ។

<u>គុណសម្បត្តិ</u>

- ដោយហេតុថា ការធ្វើអង្កេតត្រូវបានរៀបចំឡើងជាពិសេសដោយប្រើប្រាស់នូវថវិកា និងប្រភពធនធានផ្ទាល់ គេអាចប្រមូលយកពត៌មានមួយចំនួនធំ រួមបញ្ចូលទាំងការធ្វើតេស្តឈាម និងតេស្តមន្ទីរពិសោធន៍ និងការត្រួតពិនិត្យគ្លីនិក ក៏ដូចជាពត៌មានស្តីអំពីប្រភេទនៃអ្នកដែលឆ្លងជំងឺ និងការប្រព្រឹត្តរបស់ពួកគេ ដោយសារមូលហេតុដូចគ្នាដែរ គេអាចសំរេចបាននូវការប្រមូលយកនូវទិន្នន័យដែលមានលក្ខណៈល្អជាងគេ ។

- គេអាចសំរេចបាននូវការប្រមូលយកទិន្នន័យបានល្អ

<u>គុណវិបត្តិ</u>

- មានការលំបាកក្នុងការកំណត់ថា តើលទ្ធផលដែលបានទទួលពីការធ្វើអង្កេតអាចតំណាងឱ្យប្រជាជនចំណុចទាំងមូលបានដល់កំរិតណានោះ ?

- ទាមទារឱ្យមានការផ្តល់នូវធនធានពិសេសសំរាប់រៀបចំ និងធ្វើអង្កេត ។ គេមិនអាចសំរបសំរួលអង្កេតនេះឱ្យសមស្របទៅតាមហេដ្ឋារចនាសម្ពន្ធ័ដែលមានស្រាប់បានទេ ។

<u>តើការធ្វើអង្កេតពិសេសអំពីជំងឺកាមរោគអាចឆ្លើយតបបានទៅនឹងបញ្ហាគន្លឹះនានានៃការធ្វើអង្កេតតាមដានបានល្អដល់កំរិតណា ?</u>

1. ការធ្វើអង្កេតពិសេសអំពីជំងឺកាមរោគផ្តល់នូវពត៌មានល្អៗ ស្តីអំពីសមាមាត្រនៃក្រុមប្រជាជនដែលត្រូវបានជ្រើសរើសក្នុងអង្កេត ហើយដែលកើតជំងឺកាមរោគ ។ លទ្ធផលអាចយកទៅអនុវត្តចំពោះប្រជាជនទូទៅបានដោយប្រុងប្រយ័ត្ន ពីព្រោះគេពុំដឹងថា វាអាចតំណាងឱ្យប្រជាជនចំណុចទាំងមូលបានក៏រិតណានោះទេ ។

2. ការធ្វើអង្កេតពិសេសៗ អាចផ្តល់នូវសមាមាត្រនៃករណីជំងឺដែលមានរោគសញ្ញា ប្រសិនបើការវាយតំលៃគ្លីនិក និងការធ្វើតេស្តរកវត្តមាននៃជំងឺត្រូវបានជ្រើសរើសជាផ្នែកមួយនៃជំងឺ ។

3. ការធ្វើអង្កេតពិសេសៗ ផ្តល់ពត៌មានស្តីអំពីការស្វែងរកការព្យាបាល ប្រសិនបើមានការបញ្ចូលការស្រង់ប្រវត្តិជំងឺជាផ្នែកមួយនៃការធ្វើអង្កេត ។ ក្រុមមនុស្សដែលយល់ព្រមចូលរួមក្នុងការធ្វើអង្កេតអាចមិនតំណាងឱ្យប្រជាជនចំណុចទាំងមូលទេ ។ ឧទាហរណ៍ : អ្នកចូលរួមអាចជាអ្នកដែលរាយការណ៍ប្រាប់អំពីបញ្ហាសុខភាពរបស់ខ្លួនទៅបុគ្គលិកសុខាភិបាលបានញឹកញាប់ជាងអ្នកដែលមិនចូលរួម ។

4. ការធ្វើអង្កេតពិសេសៗជាវិធីល្អបំផុតសំរាប់ការធ្វើតេស្តរកភាពស៊ាំនៃមេរោគទៅនឹងថ្នាំអង់ទីប៊ីយោទិច

<u>តើនៅពេលណាយើងត្រូវពិចារណា យកការធ្វើអង្កេតពិសេសៗ អំពីកាមរោគមកប្រើប្រាស់ ?</u>

- ប្រសិនបើវិធីប្រមូលយកពត៌មានដែលមានស្រាប់ផ្តល់ពត៌មានពុំបានគ្រប់គ្រាន់ ដើម្បីឆ្លើយតបអោយបានសមស្របទៅនឹងបញ្ហាដែលចោទឡើងដោយការធ្វើអង្កេតតាមដាន

***និង***

- ប្រសិនបើមាន ឬ អាចរកបានមូលនិធិពិសេសសំរាប់ប្រើប្រាស់សំរាប់សកម្មភាពអង្កេតតាមដាន ។

<u>តើនៅពេលណាដែលយើងពុំត្រូវយកការអង្កេតពិសេសអំពីជំងឺកាមរោគមកប្រើប្រាស់</u>

- ប្រសិនបើមូលនិធិពិសេសទំនងជាពុំអាចរកបានសំរាប់ការធ្វើសកម្មភាពអង្កេតតាមដាននេះទេ

***ឬ***

- វិធីធ្វើអង្កេតតាមដានផ្សេងៗទៀត អាចផ្តល់នូវពត៌មានសមស្របសំរាប់ឆ្លើយតបទៅនឹងបញ្ហានានាដែលចោទឡើងដោយការធ្វើអង្កេតតាមដាន ។

**បញ្ហាពិសេសនានាទាក់ទងនឹងការអង្កេតតាមដានជំងឺកាមរោគ**

- <u>**ការធ្វើអង្កេតតាមដានដែលមានលក្ខណៈអនាមិក និង Unlinked**</u>

  - ប្រើប្រាស់ specimens ដែលបានមកអំពីការអង្កេតក្នុងបំណងផ្សេងៗទៀត
  - ធ្វើចំពោះក្រុមប្រជាជនដែលមានអត្រាប្រេវ៉ាឡង់ទាប
  - នៅតាមកន្លែងដែលមានធនធានតិចតួច
  - ដាច់ខាតត្រូវធ្វើឱ្យមានភាពមិនទាក់ទងគ្នា (unlinked)

- <u>**ការវាយតំលៃអំពីការប្រព្រឹត្តនានា**</u>

**វិធីអង្កេតតាមដានជំងឺកាមរោគ (STD Surveillance Methods)**

| Index | ការរាយការណ៍ករណីជំងឺកាមរោគ | ការតាមដានការវិវត្តនៅតាមកន្លែងមួយចំនួនដែលបានជ្រើសរើស | ការអង្កេតពិសេសៗ |
|---|---|---|---|
| *អាំងស៊ីដង់* | | | |
| មេរោគអេដស៍ | ការស្រង់ប្រវត្តិ និងការធ្វើតេស្តដោយប្រើតេស្តពីរបែបផ្សេងគ្នា | គ្លីនិកកាមរោគ<br>ការផ្តល់ឈាម | -ការសិក្សា Cohort<br>-ការធ្វើតេស្តសាជាថ្មី ជាច្រើនដង<br>-ការធ្វើតេស្តជាថ្មីច្រើនដង |
| ជំងឺស្វាយ | ការស្រង់ប្រវត្តិ និងការធ្វើតេស្តដោយប្រើតេស្តពីរផ្សេងគ្នា | គ្លីនិកកាមរោគ<br>ការផ្តល់ឈាម | -ការសិក្សា Cohort<br>-ការពិនិត្យប្រដាប់បន្តពូជ |
| ជំងឺប្រមេះទឹកបាយ | ការស្រង់ប្រវត្តិ និងការធ្វើតេស្តដោយប្រើតេស្តពីរផ្សេងគ្នា | | |

| | | | |
|---|---|---|---|
| *ប្រេវ៉ាឡង់* | | | |
| មេរោគអេដស៍ | ការធ្វើតេស្ត | គ្លីនិកកាមរោគ ការផ្តល់ឈាម សេវាធ្វើតេស្តជាប្រចាំនានា | ការធ្វើអង្កេត Cross Sectional (អនាមិក និង មិនទាក់ទងគ្នា) លើស្ត្រីមានផ្ទៃពោះ អ្នកជំងឺកាមរោគ យោធា អ្នករកស៊ីផ្លូវភេទ អ្នកប្រើគ្រឿងញៀន |
| ជំងឺប្រមេះទឹកបាយ និងក្លាមីឌីយ៉ា | ការធ្វើតេស្តដោយបច្ចេក-ទេស PCR លើទឹកនោម | គ្លីនិកកាមរោគ | ការពិនិត្យប្រដាប់បន្តពូជ-ទឹកនោម ការធ្វើតេស្ត-តេស្តឈាម |
| *ជំងឺក្នុងដំណាក់កាលចុងក្រោយ* | | | |
| មេរោគអេដស៍ | អេដស៍ | មន្ទីរពេទ្យនានា | មានធនធានតិចតួច កន្លែងដែលមានអត្រាអាំងស៊ីដង់ខ្ពស់ |

**ការអង្កេតតាមដានការប្រព្រឹត្ត (Behavioral Surveillance)**

<u>**ការសិក្សាអំពីប្រភពដែលនាំរកការចំលង**</u> **(Causal pathway)**

- ចំណេះដឹង
- អាកប្បកិរិយា
- ភាពអាចទទួលបាននូវសេវាបង្ការ
- ការប្រព្រឹត្តដែលនាំឱ្យឆ្លងកាមរោគ
- កត្តាសង្គម និងទំនាមទំលាប់
- លទ្ធភាពអាចប្រើប្រាស់បានសេវាថែទាំសុខភាព

**វិធីសំរាប់តាមដានការប្រព្រឹត្ត (Methods for Monitoring Behavior)**

- ការប្រើប្រាស់បញ្ជីសំនួរដែលត្រូវឆ្លើយដោយខ្លួនឯង (self-reporting questionnaires)
- លក្ខណៈសំគាល់ផ្នែកជីវសាស្ត្រ (biological marker)

- ការរាយការណ៍បែប Proxy
- ការតាមដានត្រួតពិនិត្យការប្រើប្រាស់សេវា (consumption reporting)
- ការចុះបញ្ជីដែលមានស្រាប់

ចំពោះការធ្វើអង្កេតអំពីការប្រព្រឹត្តផ្លូវភេទ ជាទូទៅមានតែការរាយការណ៍ដោយខ្លួនឯងមួយមុខប៉ុណ្ណោះដែលអាចធ្វើទៅបាន ។

**ភាពលំអៀងនៃការរាយការណ៍ដោយខ្លួនឯង**

- ❖ គ្មានឆន្ទះក្នុងការចូលរួមធ្វើសហប្រតិបត្តិការ ឬ ប្រាប់ការពិត
- ❖ យល់ខុសសំនួរ (misunderstanding questions)
- ❖ បដិសេធដោយខ្លួនឯង (self denial)
- ❖ កង្វះខាតក្នុងការរំលឹកឡើងវិញ ឬ កង្វះចំណេះដឹងអំពីការប្រព្រឹត្ត

**តើត្រូវប្រមូលយកពត៌មានស្តីអំពីការប្រព្រឹត្តតាមរយៈការរាយការណ៍ដោយខ្លួនឯងឱ្យបានល្អយ៉ាងដូចម្តេច?**

- ការសំភាសន៍ទល់មុខគ្នារវាងមនុស្ស ២នាក់ : ការប្រាស្រ័យទាក់ទងមានលក្ខណៈច្បាស់ល្អ ក៏ប៉ុន្តែមានតំលៃថ្លៃ
- ការប្រើបញ្ជីសំនួរដែលបំពេញដោយខ្លួនឯង : រក្សាការសំងាត់បាន ហើយមានតំលៃថោកជាងវិធី មុន ក៏ប៉ុន្តែអាចមានបញ្ហាបកស្រាយសំនួរខុស ឬ មិនយល់សំនួរ
- ការធ្វើសំភាសន៍តាមរយៈទូរស័ព្ទ

***ត្រូវចងចាំ : ត្រូវរក្សាការសំងាត់ជានិច្ច ។***

**តើត្រូវធ្វើការអង្កេតលើអ្នកណាខ្លះ ?**

**១ - <u>ការជ្រើស sample ក្នុងលក្ខណៈ random ក្នុងចំណោមប្រជាជនទាំងមូល</u>**

<u>គុណសម្បត្តិ</u>

- ផ្តល់ពត៌មានពេញលេញស្តីពីការប្រព្រឹត្តប្រសិនបើ :
  - ♦ ជ្រើសរើស sample frame (cluster) បានល្អ

- ♦ មានអត្រាឆ្លើយតបល្អ
- ♦ ការឆ្លើយតបនឹងសំនួរអាចយកជាការបាន

គុណវិបត្តិ

- ថ្លៃ
- ផ្តល់ពត៌មានបានតិចតួចអំពីក្រុមប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ដែលមានចំនួនតិចជាងក្រុមដទៃៗទៀត

## ២ - ក្រុមប្រជាជនចំណុចដែលបំរើការងារតាមគ្រឹះស្ថាននានា (Institution based population)

- គ្រឹះស្ថានសិក្សា
- កន្លែងធ្វើការងារ
- យោធា

គុណសម្បត្តិ

- ងាយទាក់ទង (good access)
- មានតំលៃថោក
- ងាយទទួលបានការឆ្លើយតបបានច្រើន

គុណវិបត្តិ

- ពុំមានលក្ខណៈ random
- មិនអាចក្តោបយកក្រុមប្រជាជនទាំងអស់បាន ជាពិសេសចំពោះក្រុមដែលស្ថិតនៅក្រៅសង្គម (marginalised groups)

## ៣ - ក្រុមដែលមានការប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់

- តាមរយៈការចុះអប់រំផ្ទាល់
- ទាក់ទងតាមរយៈការផ្តល់សេវាថែទាំ

**លំហាត់ទី ៣.១**

- សូមធ្វើការរៀបរៀងប្រព័ន្ធអង្កេតតាមដានជំងឺកាមរោគមួយបែបសំរាប់ប្រទេសកម្ពុជាយើង ។ សូមបញ្ជាក់នូវលកណ្ខៈសំគាល់សំខាន់ៗដូចខាងក្រោមនេះ
  - ក្រុមប្រជាជនគោលដៅ
  - សន្ទស្សន៍ (indices) សំរាប់ធ្វើការវាស់ស្ទង់
  - អង្គការ ឬ ស្ថាប័នដែលទទួលខុសត្រូវចំពោះការអង្កេតតាមដាន
  - វិធីរៀបចំការប្រមូលយកទិន្នន័យ
    - ❖ ប្រធានបទនៃការអង្កេតតាមដាន
    - ❖ អ្នកដែលត្រូវប្រមូលយកទិន្នន័យ
    - ❖ វិធីប្រមូលយកទិន្នន័យ
    - ❖ ប្រភេទទិន្នន័យដែលត្រូវប្រមូលយកសំរាប់បុគ្គលម្នាក់ៗ
    - ❖ វិធីធ្វើទិន្នន័យទៅកាន់អង្គការ ឬ ស្ថាប័នដែលទទួលខុសត្រូវក្នុងការធ្វើអង្កេតតាមដាន
  - តំរូវការនូវប្រភពធនធានបន្ថែម
  - ការធ្វើរបាយការណ៍ និងការផ្សព្វផ្សាយទិន្នន័យ

**លំហាត់ទី ៣_២**

សូមរៀបចំបង្កើតប្រព័ន្ធអង្កេតតាមដានការប្រព្រឹត្តមួយសំរាប់ប្រទេសកម្ពុជាយើង ។ សូមបញ្ជាក់អំពីលក្ខណ:សំគាល់សំខាន់ដូចក្នុងលំហាត់ទី១ ដែរ ។

## ការអង្កេតស្រាវជ្រាវ ad hoc អំពីអត្រានៃជំងឺកាមរោគនៅប្រទេសកម្ពុជា

នៅឆ្នាំ ១៩៩៦ ការអង្កេតស្រាវជ្រាវអំពីអត្រាផ្ទុកមេរោគអេដស៍ (HIV-1) និងជំងឺកាមរោគដទៃៗទៀត និងការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ ត្រូវបានធ្វើឡើងចំពោះស្រ្តី ៣១៤នាក់ ដែលស្វែងរកសេវាសុខភាពបន្តពូជ (ការពិនិត្យសុខភាពមុនសំរាល ការពន្យាកំណើត និងផ្នែករោគស្រ្តី)

- ប៉ូលីស និងយោធាចំនួន ៣៣២នាក់
- ស្រ្តីរកស៊ីផ្លូវភេទតាមបន ចំនួន ៤៣៧នាក់

ការស្រាវជ្រាវបានធ្វើទៅនៅភ្នំពេញ តំបន់ស្វាយប៉ាក ក្រុងព្រះសីហនុ ខេត្តបាត់ដំបង និងស៊ីសុផុន ។ អ្នកចូលរួមក្នុងការអង្កេតបានទទួលនូវការសំភាសន៍ ការពិនិត្យ និងធ្វើតេស្តទឹកនោមរកវត្តមាននៃ chlamydia trachomatis និង Neisserial gonorhoea ដោយប្រើបច្ចេកទេស ligase chain reaction (Abbot Diagnostics) ការពិនិត្យស៊េរ៉ូមរកស្រាវជ្រាវរកជំងឺស្វាយដោយបច្ចេកទេស RPR និងត្រូវបញ្ជាក់ដោយតេស្ត TPHA និងការធ្វើតេស្តស៊េរ៉ូមរកវត្តមាននៃមេរោគអេដស៍ប្រភេទទី១ (HIV-1) ដោយបច្ចេកទេស ELISA និងបញ្ជាក់ដោយតេស្ត ELISA ថ្មីមួយទៀត ។ ការកំណត់ ប្រភេទ (Sub type) នៃមេរោគអេដស៍ត្រូវបានធ្វើឡើងដោយប្រើបច្ចេកទេស hetero duplex mobility assays (HMA) ។ ជាលិកាផ្នែកខាងក្នុងមាត់ស្បូន និងបង្ហូរនោមត្រូវបានយកទៅបណ្ដុះដើម្បីបញ្ជាក់ កំណត់អំពីវត្តមាននៃ N. gonorrheal ដោយប្រើមជ្ឈដ្ឋានបណ្ដុះមេរោគ Thayer-Martin ហើយ មេរោគដែលបណ្ដុះបាន (isolates) ត្រូវយកមកធ្វើតេស្តរកភាពស៊ាំរបស់វាទៅនឹងថ្នាំអង់ទីប៊ីយោទិក ដោយប្រើបច្ចេកទេស agar dilution ។

ស្រ្តីរកស៊ីផ្លូវភេទ 38.7% កើតជំងឺដែលបង្កឡើងដោយក្លាមីឌីយ៉ា និង/ឬ ឆ្លងប្រមេះទឹកបាយ ហើយ 13.8% ផ្ទុកមេរោគស្វាយ ។ អត្រាប្រេវ៉ាឡង់នៃជំងឺប្រមេះទឹកបាយប្រែប្រួលពី 10% នៅខេត្តបាត់ដំបង ទៅ 39% នៅស៊ីសុផុន ហើយអត្រាប្រេវ៉ាឡង់នៃជំងឺស្វាយប្រែប្រួលពី 4% នៅភ្នំពេញទៅ 25% នៅ ស៊ីសុផុន ។ ហើយអត្រាប្រេវ៉ាឡង់នៃជំងឺស្វាយមាន 4% នៅភ្នំពេញ និង 25% នៅស៊ីសុផុន ។

បុរសចំនួន 6.2% មានកើតជំងឺរលាកបង្ហូរនោម (2.1% កើតជំងឺដែលបង្កដោយមេរោគក្លាមីឌីយ៉ា 5.0% កើតជំងឺប្រមេះទឹកបាយ) ។ 6.6% នៃបុរសកើតជំងឺស្វាយ ។ ស្រ្តីដែលស្វែងរកការថែទាំផ្នែកសុខភាពបន្តពូជចំនួន 5.3% កើតជំងឺដែលបង្កដោយមេរោគក្លាមីឌីយ៉ា និងមេរោគហ្គោណូកូក ហើយ 4% មានផ្ទុកមេរោគស្វាយ (3% នៅភ្នំពេញ 7% នៅខេត្តបាត់ដំបង) ។ អត្រាប្រេវ៉ាឡង់នៃមេរោគ អេដស៍ (HIV-1) មាន 40.6% ក្នុងចំណោមស្រ្តីរកស៊ីផ្លូវភេទ (19% នៅស្វាយប៉ោ 51% នៅក្រុងព្រះ សីហនុ) ។ បុរសចំនួន 12.5% (6% នៅបាត់ដំបង 16% នៅក្រុងព្រះសីហនុ) មានផ្ទុកមេរោគ អេដស៍ ។

ចំពោះស្ត្រីដែលស្វែងរកការថែទាំផ្នែកសុខភាពបន្តពូជវិញ អត្រានេះមាន 4.5% (3% នៅ ភ្នំពេញ និង 7% នៅក្រុងព្រះសីហនុ) ។

ក្នុងចំណោម isolates នៃមេរោគហ្គោណូកូកដែលគេបានធ្វើតេស្ត 79% ជា isolate ដែលបង្កើតជាតិ beta-lactamase, 99% ស៊ាំទៅនឹងឱសថ tetracycline (MIC ≥ 4/76μg/ml) ហើយ 39% ស៊ាំទៅនឹងថ្នាំ Kanamycin (MIC ≥ 32μg/ml) ។

Isolate មេរោគចំនួន 54% អាចខ្លាចថ្នាំ ciprofloxacin (MIC 0.125-0.5 μg/ml) ហើយ isolate ចំនួន 10% ស៊ាំទៅនឹងថ្នាំនេះក្នុង MIC ≥ 10 μg/ml ។ Isolates ទាំងអស់នៅខ្លាចថ្នាំ ceftriaxone, cefixime និង spectinomycine ។

ការធ្វើតេស្តប្រភេទ HMA លើឈាមនៃអ្នកផ្ទុកមេរោគអេដស៍ប្រភេទទី ១ (HIV) បានបង្ហាញថា មេរោគនេះស្ថិតនៅក្នុង subtype E ។ ការវិភាគដើមកំណើតមេរោគ (phylogenic tree analysis) បានបង្ហាញអំពីទំនាក់ទំនងយ៉ាងជិតស្និទនៃមេរោគទៅនឹង prototype E ដែលមានដើមកំណើតនៅប្រទេសថៃ ដែលជាហេតុនាំយើងអាចទាញសេចក្តីសន្និដ្ឋានបានថា មេរោគអេដស៍បានធ្វើការរាលដាលនៅក្នុងតំបន់ចូលទៅប្រទេសកម្ពុជា ផ្ទុយពីពាក្យចចាមអារាមដែលនិយាយថា មេរោគនេះត្រូវនាំចូលមកប្រទេសនេះតាមរយៈកងកំលាំងរក្សាសន្តិសុខរបស់អង្គការសហប្រជាជាតិនោះ ។

បុរសចំនួន 56% បានទទួលស្គាល់ថា ពួកគេរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទកាលពីខែកន្លងទៅហើយ 85% បានរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទកាលពី១ឆ្នាំ កន្លងទៅ ។ មានបុរសចំនួន 38% តែប៉ុណ្ណោះដែលបានផ្តល់ព័តមានខ្លួនបានប្រើប្រាស់ស្រោមអនាម័យ បានទៀងទាត់នៅពេលរួមភេទជាមួយស្ត្រីរកស៊ីផ្លូវភេទ។ បែបផែននៃការប្រព្រឹត្តផ្លូវភេទ និងអត្រាប្រេវ៉ាឡង់ខ្ពស់នៃមេរោគអេដស៍ និងកាមរោគនៅក្នុងចំណោមក្រុមប្រជាជនទាំងនេះ ជាការមួយគួរឱ្យយើងភ័យបារម្ភយ៉ាងខ្លាំង ហើយតំរូវឱ្យមានការធ្វើអន្តរាគមន៍ជាបន្ទាន់ ជាពិសេស គឺត្រូវផ្តោតលើស្ត្រីរកស៊ីផ្លូវភេទ ។

## ភាគរយនៃបុរសដែលបានរួមភេទជាមួយនារីរកស៊ីផ្លូវភេទ ក្នុងរយៈពេល ១ខែកន្លងមក នៅប្រទេសកម្ពុជា




## ការប្រើប្រាស់ស្រោមអនាម័យជានិច្ចជាមួយនារីរកស៊ីផ្លូវភេទ ក្នុងរយៈពេល ៣ ខែ កន្លងមក (នៅប្រទេសកម្ពុជា)



## អត្រាប្រេវ៉ាឡង់នៃជំងឺកាមរោគ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ នៅប្រទេសកម្ពុជា ឆ្នាំ ១៩៩៦-២០០១




| | Gonorrhea | Chlamydia | Syphilis RPR | Trichomonas |
|---|---|---|---|---|
| Sex worker 96 | 23.2% | 22.5% | 13.8% | 5.4% |
| Sex worker 01 | 14.2% | 12.1% | 2.8% | 2.1% |

## អត្រាប្រេវ៉ាឡង់នៃជំងឺកាមរោគ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ នៅតាមបណ្តាខេត្តមួយចំនួន ឆ្នាំ ២០០១



### អត្រាប្រេវ៉ាឡង់ជំងឺកាមរោគ ក្នុងចំណោមស្ត្រីរកស៊ីផ្លូវភេទ នៃប្រទេសនានានៅក្នុងតំបន់




| | Gonorrhea | Chlamydia | Syphilis |
|---|---|---|---|
| Laos | 13.6 | 34.8 | 0.4 |
| Philippines | 25.0 | 36.0 | 12.0 |
| Indonesia | 30.9 | 23.9 | 12.9 |
| Bangladesh | 25.0 | 35.0 | 32.0 |
| Kerala, India | 9.2 | 15.8 | 16.7 |
| Cambodia 96 | 23.2 | 22.5 | 13.8 |
| Cambodia 01 | 14.2 | 12.1 | 2.8 |

Sources: Lao NCCA 2001, FHI/Philippines 1999, Otto B et al, AusAID Project, 1999
Bangladesh National AIDS/STD Program, 2001, FHI/DFID partners India 2000

## កម្មវិធីអង្កេតអេពីដេមីសាស្ត្ររកអត្រាអ្នកផ្ទុកមេរោគអេដស៍នៅកម្ពុជា
## វិធីសាស្ត្រ និង បទពិសោធន៍ មួយចំនួន

របាយការណ៍ស្តីអំពីករណីអ្នកផ្ទុកមេរោគអេដស៍ អ្នកជំងឺអេដស៍ និង អ្នកស្លាប់ដោយសារជំងឺអេដស៍មានសារៈសំខាន់ខ្លាំងណាស់ សំរាប់យល់ដឹងអោយបានពីដំបូងនូវការរាលដាលនៃមេរោគ នេះ។ ប៉ុន្តែការទទួលនូវទិន្នន័យទាំងឡាយនេះតែងតែមានកំរិត។ ទាំងនេះក៏មកតែពីបញ្ហារាយការណ៍ មិនបានគ្រប់ករណីដូចដែលមានក្នុងការពិតជាក់ស្តែង។ឧទាហរណ៍ដូចជាគេប៉ាន់ស្មានថានៅក្នុងតំបន់ អាស៊ីប៉ាស៊ីភិច យើងបច្ចុប្បន្ននេះមានអ្នកផ្ទុកមេរោគអេដស៍តិចជាង ២០ ភាគរយ នៃការពិតជាក់ស្តែង ដែលបានរាយការណ៍ទៅទៀត ។

នៅឆ្នាំ ១៩៩៤ ក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានចាប់ផ្តើមកម្មវិធីអង្កេតឃ្លាំមើលរកអត្រាអ្នកផ្ទុកមេរោគអេដស៍ដោយមានការគាំទ្រពីអង្គការសុខភាពពិភពលោក។ នៅពេលនោះគោលបំណងសំខាន់ពីរនៃការអង្កេតនេះគឺៈ

- ដើម្បីប្រមូលនិងវិភាគលើពត៌មានអេពីដេមីសាស្ត្រនៃអ្នកជំងឺអេដស៍និងអ្នកផ្ទុកមេរោគអេដស៍។
- ពន្យល់ឱ្យកាន់តែច្បាស់អំពីទំហំនៃការរាលដាលជំងឺអេដស៍នៅក្នុងតំបន់ និង ក្រុមប្រជាជនចំនុចដែលបានជ្រើសរើសយកមកធ្វើការអង្កេត ។

## វិធីសាស្ត្រ

យុទ្ធសាស្ត្រជាចំបងក្នុងកម្មវិធីអង្កេតអេពីដេមីសាស្ត្ររកអត្រាផ្ទុកមេរោគអេដស៍នៅកម្ពុជា គឺ ធ្វើការអង្កេតរកអត្រាអ្នកផ្ទុកមេរោគអេដស៍ (អត្រាប្រេវ៉ាឡង់) ក្នុងចំនោមប្រជាជនចំនុចដែលបាន ជ្រើសរើសក្នុងពេលកំនត់ណាមួយ។ការធ្វើបែបនេះយើងបានដាក់ឈ្មោះថាជា កម្មវិធីអង្កេតឃ្លាំមើលរក អត្រាអ្នកផ្ទុកមេរោគអេដស៍។ ការងារអង្កេតនេះត្រូវបានរៀបចំចាត់ចែងដោយកម្មវិធីជាតិប្រយុទ្ធនឹង ជំងឺអេដស៍នៃក្រសួងសុខាភិបាលដោយទទួលការឧបត្ថម្ភ ថវិការ និង បច្ចេកទេសពីអង្គការសុខភាព ពិភពលោក និង អង្គការអន្តរជាតិនានា។ ជារួមនៅពេលបច្ចុប្បន្ននេះយើងត្រូវចំនាយប្រហែលជា ៥ ម៉ឺនដុល្លាក្នុងមួយឆ្នាំសំរាប់កម្មវិធីនេះ ។

កម្មវិធីអង្កេតឃ្លាំមើលបានចាប់ផ្តើមតាំងពីឆ្នាំ ១៩៩៣ មកម្លេះ ប៉ុន្តែដោយសារមានការលំបាកផ្នែកបច្ចេកទេសមន្ទីរពិសោធន៍មួយចំនួនបានធ្វើអោយមាន កម្មវិធីអង្កេតឃ្លាំមើលរកអត្រាផ្ទុក មេរោគអេដស៍ជុំទី ១ ធ្វើឡើងនៅឆ្នាំ ១៩៩៤ វិញ ។ នៅជុំទីមួយនោះយើងបានធ្វើការអង្កេត នៅក្នុងខេត្តក្រុង ចំនួន ៥ និង ក្នុងចំនោមប្រជាជនចំនុច ៥ ក្រុមខុសៗគ្នា (សូមមើលនូវ តារាងលេខ ២ និង ផែនទី ទី ១ ដែលមានភ្ជាប់មកជាមួយ) ។

នៅជុំទីមួយនោះយើងធ្វើការប្រមូលបាន ៣៥០០ នាក់ ហើយបានយកមកធ្វើតេស្តរកមេរោគអេដស៍ដោយប្រើតេស្តរហ័ស (Rapid test) ។ ចំពោះអ្នកដែលមានលទ្ធផលវិជ្ជមានយើងបានធ្វើតេស្តបញ្ជាក់ដោយធ្វើតេស្ត Elisa ពីរខុសគ្នាថែមទៀត ។ ការងារអង្កេតនោះត្រូវបានអនុវត្តដោយមន្ត្រីការិយាល័យអេដស៍ថ្នាក់ខេត្ត ដោយមានការដឹកនាំបច្ចេកទេសពីមន្ត្រីថ្នាក់ជាតិ ។ ប៉ុន្តែ ដោយសារការទុកដាក់សេរ៉ូមមិនបានល្អនៅជុំទីមួយនោះមានតែ ៤៦៤ សេរ៉ូម ប៉ុណ្ណោះដែលអាចយកជាការបាន។

**តារាងលេខ២: តារាងសង្ខេបពីការផ្លាស់ប្តូរការរៀបចំកម្មវិធីអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍នៅកម្ពុជា ពីឆ្នាំ ១៩៩៤ ដល់ ១៩៩៦**

| **ឆ្នាំ** | **១៩៩៤** | **១៩៩៥** | **១៩៩៦** |
|---|---|---|---|
| **ទីកន្លែង** | -ភ្នំពេញ<br>-បន្ទាយមាន ជ័យ<br>-បាត់ដំបង<br>-ក្រុងព្រះសីហនុ<br>-សៀមរាប | -ភ្នំពេញ<br>-បន្ទាយមាន ជ័យ<br>-បាត់ដំបង<br>-ក្រុងព្រះសីហនុ<br>-សៀមរាប<br>-កណ្តាល<br>-កោះកុង<br>-ពោធិសាត់<br>-រតនះគីរី | -ភ្នំពេញ<br>-បន្ទាយមានជ័យ<br>-បាត់ដំបង<br>-ក្រុងព្រះសីហនុ<br>-សៀមរាប<br>-កណ្តាល<br>-កោះកុង<br>-ពោធិសាត់<br>-រតនះគីរី<br>-កំពង់ចាម<br>-កំពង់ឆ្នាំង<br>-កំពត<br>-ក្រចេះ<br>-កំពង់ស្ពឺ<br>-ព្រៃវែង<br>-ស្ទឹងត្រែង<br>-ស្វាយរៀង<br>-តាកែវ |
| **ក្រុមប្រជាជន គោលដៅ** | -ស្រីរកស៊ីផ្លូវភេទ<br>-អ្នកជំងឺរបេង<br>-ប៉ូលីស<br>-ទាហាន<br>-ស្រីមានផ្ទៃពោះ | -ស្រីរកស៊ីផ្លូវភេទ<br>-អ្នកជំងឺរបេង<br>-ប៉ូលីស<br>- អ្នកដោះមីន<br>-ទាហាន<br>-ស្រីមានផ្ទៃពោះ<br>-ស្រីរកស៊ីផ្លូវភេទមិនផ្ទាល់ | -ស្រីរកស៊ីផ្លូវភេទ<br>-អ្នកជំងឺរបេង<br>-ប៉ូលីស<br>-ទាហាន<br>-ស្រីមានផ្ទៃពោះ |

នៅឆ្នាំ ១៩៩៥ កម្មវិធីអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍បានពង្រីកដល់ ៩ ខេត្តក្រុង។ ខេត្តក្រុងចំនួន ៨ ក្នុងចំនោមខេត្តក្រុងទាំង ៩ ដែលបានរើសមកនេះ ដោយសំអាងថាខេត្តទាំងនោះជាផ្លូវនៃការចលនាប្រជាជន រវាងប្រទេស កម្ពុជា វៀតណាម និង ថៃ។ ទីនោះហើយដែលយើងគិតថាមានអត្រាផ្ទុកមេរោគអេដស៍ ខ្ពស់ ។ ចំពោះខេត្តទី ៩ គឺខេត្ត រតនះគីរី គឺយើងជ្រើសរើសសំរាប់ប្រៀបធៀប ព្រោះខេត្តនេះជាខេត្ត ដែលស្ថិតនៅដាច់ស្រយាល ពីផ្លូវដឹកជញ្ជូនផ្សេងៗ។ នៅជុំទីពីនេះយើងបានធ្វើការអង្កេតលើក្រុមប្រជាជនចំនុចចំនួន ៧ ក្រុមផ្សេងៗគ្នា (មើលតារាង

លេខ ២) ។ គួរបញ្ជាក់ថានៅគ្រប់ខេត្តទាំងអស់ដែលចូលរួមក្នុងកម្មវិធីអង្កេតនេះ ក្រុមប្រជាជនដែលចូលរួមក្នុងការអង្កេតសុទ្ធតែរស់នៅតំបន់ទីក្រុង ។

នៅពេលរៀបចំការអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍ជុំទី២នៅឆ្នាំ ១៩៩៥ កម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍បានបើកវគ្គបណ្តុះបណ្តាលដល់បុគ្គលិកមន្ទីរពិសោធន៍ថ្នាក់ខេត្ត ។ ក្រោយមក វគ្គបណ្តុះបណ្តាលនេះ បានធ្វើឡើងជារៀងរាល់ ៦ ខែ នៅតាមបណ្តាខេត្ត។ នៅក្នុងខេត្តនិមួយៗ គ្រប់មនុស្សក្នុងប្រជាជនចំនុចដែលកម្មវិធីបានជួបត្រូវបានចូលរួមធ្វើតេស្តទាំងអស់ ប៉ុន្តែកម្មវិធីមិនបានប្រើវិធីជ្រើសរើសអ្នកចូលរួមទេ (Sampling) ។ ក្នុងការអង្កេតនេះកម្មវិធីបានប្រមូល ព័តមានប្រជាសាស្រ្តរួមមានទាំង ភេទ អាយុ ស្រុកកំណើត និង ខេត្តដែលបុគ្គលកំពុងរស់នៅ ។

នៅឆ្នាំ ១៩៩៦ កម្មវិធីអង្កេតឈាមបានកែលំអបន្ថែមទៀត ។ នៅជុំទីបីនេះកម្មវិធីធ្វើការអង្កេតលើក្រុមប្រជាជនចំនុចចំនួន ៥ ក្រុមប៉ុណ្ណោះ (មើលតារាងទី ២) ។ ប៉ុន្តែយើងបានពង្រីកដល់ ១៨ខេត្ត-ក្រុង តាមសំនូមពររបស់រដ្ឋអំណាចមូលដ្ឋាន ។ នៅពេលនោះមន្ត្រីថ្នាក់ខេត្ត ជាអ្នកចាត់ចែងការអង្កេតស្ទើរតែទាំងអស់ ។ នៅជុំនោះដែរ ការអង្កេតបានកាន់តែឈានដល់ជនបទទៀតផង។ វិធីសាស្រ្តនៃការធ្វើអង្កេតក៏កាន់តែមានភាពប្រសើរឡើងដើម្បីធ្វើយ៉ាងណាការពារ ការសំងាត់ដល់អ្នកដែលចូលរួមក្នុងការអង្កេត ។

បន្ថែមពីលើការអង្កេតឈាមរកអត្រាអ្នកផ្ទុកមេរោគអេដស៍ ការតាមដានមើលពីការវិវត្តន៍នៃអត្រាផ្ទុកមេរោគអេដស៍ក្នុងចំនោម អ្នកផ្តល់ឈាម និង ជនអន្តោរប្រវេសន៍ ក៏ត្រូវបានកម្មវិធីជាតិប្រយុទ្ធនឹងជំងឺអេដស៍ក្រសួងសុខាភិបាលយកមកវិភាគផងដែរ ។ ប៉ុន្តែភាពលំអៀងផ្សេងៗដែលអាចប៉ះពាល់ដល់លទ្ធផលទាំងនេះក៏ត្រូវបានយើងលើកយកមកគិតគូរផងដែរ ។ ចាប់តាំងពីឆ្នាំ ១៩៩០ មកមជ្ឈមណ្ឌលជាតិផ្តល់ឈាមគ្រប់ជាន់ថ្នាក់ បានចាប់ផ្តើមធ្វើតេស្តឈាមរកមេរោគអេដស៍ ។ មជ្ឈមណ្ឌលជាតិផ្តល់ឈាមបានប្រឹងប្រែងរក្សាការសំងាត់នៃលទ្ធផលនៃការពិនិត្យឈាមតាមរយៈការដាក់លេខកូដ ។ ចាប់តាំងពីឆ្នាំ ១៩៩៦ មកគ្រប់អ្នកផ្តល់ឈាមបានទទួលការប្រឹក្សាពីលទ្ធផលនៃតេស្តឈាមរបស់ខ្លួន។ បញ្ជីអ្នកផ្តល់ឈាមនិមួយៗ ត្រូវបានចំណាំដោយឈ្មោះ និង លេខកូដរបស់ឈាម ។

រហូតមកដល់ពេលបច្ចុប្បន្ននេះ នៅកម្ពុជាមានមជ្ឈមណ្ឌលផ្តល់ឈាមចំនួន ១៥ ហើយ។ មជ្ឈមណ្ឌលទាំងនេះបានរាយការណ៍ ពីលទ្ធផលនៃការធ្វើតេស្តឈាមរកមេរោគអេដស៍ជូនក្រសួងសុខាភិបាលជារៀងរាល់ខែ ។ ចាប់ពី ឆ្នាំ ១៩៩១ ដល់ ១៩៩៥ យើងសង្កេតឃើញថាមានការវិវត្តកើនឡើងនូវអត្រាអ្នកផ្ទុកមេរោគអេដស៍ ។ នៅឆ្នាំ ១៩៩៦ អត្រាផ្ទុកមេរោគអេដស៍ក្នុងចំនោមអ្នកផ្តល់ឈាមមានការថយចុះ ។ ការថយចុះនោះប្រហែលបណ្តាលមកពីកម្មវិធីជុំរុះ (Screening) ដែលបានចាប់ផ្តើមពីឆ្នាំ ១៩៩៦ ដោយជុំរុះចោលនូវអ្នកលក់ឈាម និង ក្រុមអ្នកប្រឈមមុខខ្ពស់ នឹងគ្រោះថ្នាក់នៃ

ការចំលងមេរោគអេដស៍ (ជាពិសេសអ្នកដែលរស់នៅក្នុងតំបន់ ដែលមានអត្រាផ្ទុកមេរោគអេដស៍ខ្ពស់ ឬអ្នកដែលរាយការណ៍ថាខ្លួនមានការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់) ។

ចាប់តាំងពីឆ្នាំ ១៩៩៣ អង្គការអន្តរជាតិសំរាប់ជនអន្តោប្រវេសន៍ (International Organization for Migration) បានធ្វើការស្រាវជ្រាវរកអត្រាអ្នកផ្ទុកមេរោគអេដស៍ក្នុងចំនោមជនអន្តោប្រវេសន៍ និង ជនភៀសខ្លួន ។ ទោះបីជាព័តមានដែលបានមកនោះមានសារៈសំខាន់សំរាប់តាមដានមើលពីការរាល ដាលនៅក្នុងក្រុមប្រជាជននោះក៏ដោយ ក៏ព័តមាននេះមិនអាចឆ្លុះបញ្ចាំង ពីការរាលដាលនៃមេរោគអេដស៍ នៅកម្ពុជាបានដែរ ។ ហេតុនេះហើយបានជាគេមិនចាត់ទុកព័តមាន នេះជាព័តមានសំខាន់ក្នុងការសិក្សាអោយបានស៊ីជំរៅពីការរាលដាលមេរោគអេដស៍នៅកម្ពុជា។

## បទពិសោធន៍កន្លងមក

កម្មវិធីអង្កេតឈាមនៅកម្ពុជាបានប្រើប្រាស់ពេលវេលាអស់បីឆ្នាំមុននឹងអាចដំណើរការ ទៅបានដោយជោគជ័យ។ ពេលនេះការងារតាមដាន មើលទំហំ និង ការរាលដាលនៃមេរោគអេដស៍នៅកម្ពុជាមានសារៈសំខាន់ខ្លាំងណាស់ ។

បទពិសោធន៍ក្នុងការរៀបចំនិងអនុវត្តការងារអង្កេតឈាមបានលើកឡើងនូវចំនុចមួយចំនួន រួមមានៈ

- សេចក្តីត្រូវការនូវការវាយតំលៃនិងកែសំរួលជាប្រចាំ នូវគោលបំនងរបស់ការងារអង្កេត
- បញ្ហា ផ្សេងៗក្នុងការសំរបសំរួលការងារអង្កេតទូទាំងប្រទេសទាំងមូលនៅតាមថ្នាក់ខេត្ត
- វិធីសាស្ត្រក្នុង ការជ្រើសរើស (Sampling) និង ការយល់ព្រមដោយស្ម័គ្រចិត្ត (Informed consent)

លទ្ធផលនៃការងារអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍បានបង្ហាញថា កម្ពុជាជាប្រទេសមួយដែលរងការរាលដាលមេរោគអេដស៍ធ្ងន់ធ្ងរជាងគេ បើធៀបនឹងបណ្តាប្រទេសនៅអាស៊ីអាគ្នេយ៍ ។ ប្រជាជនពេញវ័យប្រហែលជា ២ ភាគរយ មានផ្ទុកមេរោគអេដស៍ ។ យើងក៏បានដឹងផងដែរថា ការរាលដាលមេរោគអេដស៍នៅកម្ពុជា ភាគច្រើនធ្វើឡើងតាមរយៈការរួមភេទរវាងបុរស និង ស្ត្រី ។ ការរាលដាលធ្វើឡើងនៅក្នុងក្រុមស្ត្រីរកស៊ីផ្លូវភេទនិងភ្ញៀវរបស់គេ ហើយថ្មីៗនេះទៀតមានការរាលដាលក្នុងចំនោមប្រជាជនទូទៅ ។

ព័តមានអេពីដេមីសាស្ត្រ ត្រូវបានគេយកមកប្រើប្រាស់ជាមូលដ្ឋានសំរាប់ធ្វើការប៉ាន់ស្មាន និងទាយទុកនូវករណីចំលងមេរោគអេដស៍នៅថ្ងៃអនាគត ។ ការប៉ាន់ស្មានចុងក្រោយបង្អស់បានអះអាងថានៅចុងឆ្នាំ ២០០០ មានប្រជាជនកម្ពុជាប្រមាណ ១៥៥ ០០០ នាក់ នឹងមានផ្ទុកមេរោគ អេដស៍ហើយ

ដោយគិតចាប់តាំងពីមានចាប់ផ្តើមមានការរាលដាលនៅកម្ពុជាទៅដល់ពេលនោះនឹង មានអ្នកជំងឺអេដស៍សរុបប្រមាណ ៣១០០០ នាក់ ។

លទ្ធផលនៃការធ្វើអង្កេតក៏ត្រូវបានគេយកមកប្រើប្រាស់សំរាប់ :

- ទទួលបាននូវការគាំទ្រ
- បង្កើនចំណេះដឹង ជាតិ និង អន្តរជាតិ ស្តីពីការរាលដាលមេរោគអេដស៍នៅកម្ពុជា
- ការរៀបចំអន្តរាគមន៍
- ការរៀបចំផែនការធនធានសំរាប់ថែទាំសុខភាពអ្នកជំងឺអេដស៍

**លទ្ធផលនៃកម្មវិធីអង្កេតឈាមក្នុងក្រុមប្រជាជនចំនុចចំនួន ៤ នៅកម្ពុជា ពីឆ្នាំ ១៩៩០ ដល់ ១៩៩៥**

លទ្ធផលនៃកម្មវិធីអង្កេតឈាមរកអត្រាផ្ទុកមេរោគអេដស៍ ចាប់ពីឆ្នាំ ១៩៩០ ដល់ ១៩៩៥ ក្នុងចំនោមក្រុមប្រជាជនចំនុចបួនក្រុមៈ អ្នកផ្តល់ឈាម ស្ត្រីមាន ផ្ទៃពោះ ស្ត្រីរកស៊ីផ្លូវភេទ និងអ្នកជំងឺកាមរោគ ។ អត្រាផ្ទុកមេរោគអេដស៍ក្នុងចំនោមស្ត្រីរកស៊ីផ្លូវភេទ បានកើនឡើងពី ៩.៥៤% ពីឆ្នាំ ១៩៩២ ដល់ ៣០% ក្នុងឆ្នាំ ១៩៩៥។ ការកើនឡើងនេះគឺជាសញ្ញា បង្ហាញអំពីលទ្ធភាពក្នុងការរាលដាលយ៉ាងរហ័សនៃមេរោគអេដស៍ក្នុងចំនោម ក្រុមប្រជាជនដែល មានការប្រព្រឹត្តប្រឈមមុខខ្ពស់នឹងគ្រោះថ្នាក់ក្នុងការចំលង និង ចំលងមេរោគអេដស៍។

ជាការមួយសំខាន់ណាស់ដែលត្រូវគូសបញ្ជាក់ថា តែកាលណាមានការចំលងយ៉ាងរហ័ស នៅ ក្នុងក្រុមប្រជាជនចំនុចទាំងឡាយជាពិសេស ក្រុមស្ត្រីរកស៊ីផ្លូវភេទ ឬ ក្រុមអ្នកជំងឺកាមរោគ បន្ទាប់ពីនោះគឺពិតជាមានការកើនឡើងនូវករណីនៃការចំលង ក្នុងចំនោមប្រជាជនទូទៅហើយ ។ នៅឆ្នាំ ១៩៩២ គ្មានស្ត្រីមានផ្ទៃពោះដែលបានមកពិនិត្យនៅគ្លីនិកគាំពារមាតានិងទារកមានផ្ទុកមេរោគអេដស៍ទេ ប៉ុន្តែ នៅឆ្នាំ ១៩៩៥ អត្រានេះបានកើនឡើង ដល់ ទៅ ៣.៣% ។

កម្មវិធីអង្កេតធ្វើឡើងនៅលើក្រុមប្រជាជនផ្សេងទៀតគឺក្រុមអ្នកផ្តល់ឈាមដោយស្ម័គ្រចិត្ត នៅតាមបណ្តាខេត្តផ្សេងៗ ។ ព័តមានបែបនេះជួយអោយយើងយល់ពីការរាលដាលនៃមេរោគអេដស៍នៅតាមស្ថានភាពភូមិសាស្ត្រ ។ កម្មវិធីអង្កេតឈាមបែបសង់ទីណែល (sentinel surveillance) អាចយកមកប្រើប្រាស់ជាប្រព័ន្ធ ប្រកាសអាសន្នពីដំបូងមួយសំរាប់ប្រកាសអាសន្នដល់អ្នកដឹកនាំនយោបាយ និង មន្ត្រីសុខភាពសាធារណៈ អំពីតំរូវការនូវអន្តរាគមន៍ពិសេសៗដើម្បីបន្ថយការរាលដាលនៃជំងឺ បន្តទៅទៀត។ កម្មវិធីអង្កេតបែបនេះ អាចជួយបង្ហាញអំពីផលប៉ះពាល់នៃអន្តរាគមន៍ដែលមានប្រសិទ្ធិភាពដូចដែលមាន

ឧទាហរណ៍នៅប្រទេសអូស្ត្រាលីស្រាប់។ កម្មវិធីអង្កេតសង់ទីណែលក៏អាចប្រើប្រាស់ជាមូលដ្ឋានសំរាប់រៀបចំផែនការអន្តរាគមន៍មួយដែលសមស្រប។ បើសិនជាគ្មានកម្មវិធីអង្កេតបែបនេះទេការរាលដាលមេរោគអេដស៍អាចធ្វើទៅយ៉ាងឆាប់រហ័សដោយយើងមិនបានរកឃើញថា មានការរាលដាលឡើយ ។

ការធ្វើតេស្តដែលធ្វើឡើង ដោយមិនអនាមិក (linked and anonymous) អាចនាំអោយមានការលំអៀងក្នុងការចូលរួមប៉ុន្តែអាចជួយអោយយើងរកឃើញនូវអ្នកដែលធ្វើតេស្តរកឃើញថា មានផ្ទុកមេរោគអេដស៍។ ក្នុងករណីនេះ គេត្រូវផ្តល់នូវសេវាបំរើ និង សេវាផ្តល់ប្រឹក្សាមួយដែលសមស្របដល់អ្នកដែលមានផ្ទុកមេរោគអេដស៍ ។

**ការប្រើប្រាស់ស្រោមអនាម័យ អត្រាប្រេវ៉ាឡង់មេរោគអេដស៍ និង ជំងឺកាមរោគ**
**ក្នុងចំណោមនារីរកស៊ីផ្លូវភេទនៅក្នុងប្រទេសកម្ពុជា ១៩៩៦-២០០១**



ម៉ូឌុលទី ៤

# ការធ្វើអោយប្រសើរឡើង
# ការពង្រីក និង ការជំរុញអោយមាន
# ការប្រើប្រាស់សេវាថែទាំជំងឺកាមរោគ

នៅក្នុងម៉ូឌុលនេះ យើងនឹងពិភាក្សាចំណុចដូចខាងក្រោមនេះ

- វិធីធ្វើឱ្យសេវាថែទាំដែលមានស្រាប់កាន់តែមានលក្ខណៈល្អប្រសើរ
- វិធីផ្តល់សេវាថែទាំកាមរោគនៅតាមកន្លែងដែលពុំមែនជាគ្លីនិកឯកទេសព្យាបាលជំងឺកាមរោគ
- ការពង្រីកសេវាថែទាំកាមរោគតាមរយៈសមាហរណកម្មសេវាថែទាំកាមរោគនៅក្នុងសេវាទាំងឡាយដែលមានស្រាប់ ។

## ៤.១ ការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាថែទាំកាមរោគដែលមានស្រាប់

ការថែទាំកាមរោគដែលផ្តល់ឱ្យនៅតាមសេវាថែទាំនានាដែលមានស្រាប់ មានការប្រែប្រួលទៅ តាមទីកន្លែង។ ជាពិសេសនៅតាមគ្លីនិកឯកទេសព្យាបាលជំងឺកាមរោគ ការថែទាំមានកំរិត ល្អប្រសើរបំផុត ក៏ប៉ុន្តែជារឿយៗ គេក៏ត្រូវការកែលំអសេវាទាំងនេះ ឱ្យកាន់តែប្រសើរ ថែមទៀតដែរ។ នៅកន្លែងដែលមានការជួយគាំទ្រផ្នែកមន្ទីរពិសោធន៍តិចតួច ឬគ្មានសេវាទាំងនេះសោះតែម្តង ការធ្វើរោគវិនិច្ឆ័យនិងការព្យាបាលត្រូវបានកែលំអឱ្យកាន់តែប្រសើរឡើងបាន ដោយការបញ្ចូលនូវវិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា (Syndromic approach)។

លើសពីនេះទៅទៀត សេវាថែទាំដែលមានស្រាប់ភាគច្រើនរួមទាំងគ្លីនិកឯកទេសខាងជំងឺកាមរោគផងដែរ មានតួនាទីតិចតួចណាស់ក្នុងកំរិតការរាលដាលនៃកាមរោគ ។ ការសំខាន់នោះគឺអ្នកដែលមានភារកិច្ចថែទាំជំងឺកាមរោគត្រូវទទួលស្គាល់ថាការថែទាំត្រូវជាប់ទាក់ទងនឹងបញ្ហាផ្សេងទៀតជាច្រើន ដើម្បីធ្វើឱ្យការផ្តល់ការថែទាំមានលក្ខណៈល្អគ្រប់ជ្រុងជ្រោយជូនដល់អ្នកជំងឺកាមរោគ ។ ទិដ្ឋភាពទាំងនេះរួមមានការជួយឱ្យអ្នកជំងឺកាមរោគចេះបង្ការខ្លួនកុំឱ្យឆ្លងជំងឺទៅអ្នកដ៏ទៃទៀត ការជួយឱ្យអ្នកទាំងនេះបង្ការការឆ្លងជំងឺទៅអនាគត និងការថែទាំដៃគូរួមភេទ ។ ជាញឹកញាប់ណាស់ ទិដ្ឋភាពនៃការថែទាំកាមរោគទាំងនេះ ពុំត្រូវបានគេយកចិត្តទុកដាក់ទេ ទោះបីជាគ្លីនិកទាំងនេះដឹងថាអ្នកជំងឺ ជាច្រើនរបស់គេបានវិលត្រលប់មកវិញសារជាថ្មីដោយសារកើតជំងឺកាមរោគឡើងវិញក៏ដោយ។

នៅទីបញ្ចប់មានបញ្ហាមួយទៀតដែលទាក់ទងនឹងវិធីកែលំអសេវា ដែលផ្តល់ដោយសេវាមិនមែន ផ្លូវការនានា ដូចជាអ្នកលក់ថ្នាំ និងគ្រូឱសថបុរាណជាដើម។

## ៤.២ ការពង្រីក និងការធ្វើសមាហរណកម្មនៃសេវាថែទាំកាមរោគ (Expanding and Integrating STD service)

ការប៉ុនប៉ងផ្តល់សេវាថែទាំកាមរោគដល់រាល់អ្នកដែលកើតជំងឺកាមរោគតាមរយៈគ្លីនិកឯកទេសកាមរោគ មិនមែនជាបញ្ហាអាចយកមកអនុវត្តក្នុងការងារជាក់ស្តែង និងមិនត្រូវបានគេរំពឹងថាធ្វើទៅបានទេ ។ ដើម្បីធានាឱ្យអ្នកជំងឺទាំងឡាយ ដែលយល់ឃើញថាខ្លួនអាចកើតជំងឺកាមរោគណាមួយ ទៅទទួលនូវការថែទាំនៅតាមគ្លីនិកដែលផ្តល់សេវាកាមរោគ ចាំបាច់គេត្រូវពង្រីកសេវាថែទាំទៅដល់គ្លីនិកមិនមែនឯកទេសនានានៅកំរិតថែទាំសុខភាពបឋម ។ សេវាទាំងនេះត្រូវពឹងផ្អែកលើវិធីថែទាំ កាមរោគដោយពឹងលើចង្កោមរោគសញ្ញា ។

**លំហាត់ ៤.១**

**ការពិភាក្សាជាក្រុម**

**សូមពិភាក្សាអំពីបញ្ហានានាដែលអ្នកយល់ថា អាចកើតឡើងនៅពេលធ្វើសមាហរណកម្មនៃសេវាថែទាំជំងឺកាមរោគ ។**

**បន្ទាប់មកកត់ត្រានូវវិធីដោះស្រាយបញ្ហាទាំងនោះ ។**

**សូមកត់ត្រាចុះនូវចំលើយរបស់អ្នកលើក្រដាស់ប្លាស្ទិកថ្លា ។**

ការពង្រីកនិងការធ្វើសមាហរណកម្មនៃសេវាថែទាំកាមរោគ ពុំមែនជាភារកិច្ចមួយងាយស្រួលទេ ។ គោលបំណងរបស់អ្នកគឺត្រូវរៀបចំសេវានេះដោយប្រើប្រាស់នូវចំណុចខ្លាំងនៃគ្លីនិកឯកទេសខាងកាមរោគ និងគ្លីនិកដែលស្ថិតនៅថ្នាក់ថែទាំសុខភាពបឋម ។

ជារឿយៗគេត្រូវធ្វើឱ្យមានការផ្លាស់ប្តូរជាសន្សឹមៗដោយលើកជាគំរោងមួយដែលមានទំហំតូច ដើម្បីបង្ហាញឱ្យឃើញថា វិធីថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមានដំណើរការប្រព្រឹត្តទៅបានល្អជាមុនសិន ។

ភារៈកិច្ចសំខាន់របស់អ្នកគ្រប់គ្រងកម្មវិធី គឺមិនកំរិតត្រឹមតែការធានា យ៉ាងណាឱ្យសេវាថែទាំកាមរោគមានលក្ខណៈកាន់តែប្រសើរប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺថែមទាំងបានធានាឱ្យមានការសំរបសំរួល ដល់ភារៈកិច្ចរបស់ដៃគូរួមការងារផ្សេងៗ ដែលពាក់ព័ន្ធក្នុងកម្មវិធីទៀតផង ។

តារាងទី ៤.១ ពិពណ៌នាអំពីតួនាទីបច្ចុប្បន្នរបស់សេវាទាំងនេះ និងតួនាទីអនាគតរបស់ពួកវា នៅក្នុងការពង្រីកនិងការធ្វើសមាហរណកម្ម នៃសេវាថែទាំ និងវិធីដែលធ្វើឱ្យមានការផ្លាស់ប្តូរនេះ ។

គេត្រូវបញ្ចុះបញ្ចូលអ្នកនយោបាយ អ្នកគ្រប់គ្រងកម្មវិធី និងបុគ្គលិកសុខាភិបាល នៅគ្រប់ជាន់ថ្នាក់ ឱ្យយល់ពីសារៈសំខាន់នៃកម្មវិធីពង្រីកនិងធ្វើសមាហរណកម្មនៃសេវាថែទាំកាមរោគ ហើយត្រូវធ្វើឱ្យអ្នកទាំងនោះ ចូលរួមក្នុងការរៀបចំ និងអនុវត្តផែនការផងដែរ។ តារាងទី៤.២ ពិពណ៌នា អំពីបញ្ហានានា ដែលអាចជួបប្រទះ និងណែនាំអំពីដំណោះស្រាយ ខ្លះៗចំពោះបញ្ហាទាំងនេះ ។

# តារាងទី ៤.១

| ប្រភេទនៃសេវា | តួនាទីបច្ចុប្បន្ន | តួនាទីអនាគត |
|---|---|---|
| គ្លីនិកឯកទេស | ♦ ផ្តល់សេវាធ្វើរោគវិនិច្ឆ័យរកមូលហេតុ សំរាប់អ្នកជំងឺ ដែលមកពិគ្រោះដោយខ្លួនឯង ។<br>♦ មានតួនាទីតិចតួចក្នុងការអប់រំ និងបណ្តុះបណ្តាល<br>♦ ពុំសូវមានទំនាក់ទំនង ជាមួយសេវាថែទាំផ្សេងទៀតទេ<br>♦ ជួនកាលអាចធ្វើការស្រាវជ្រាវនិងរៀបចំបង្កើតនូវគោលការណ៍ណែនាំ ផ្នែកបច្ចេកទេស | ជាមជ្ឈមណ្ឌលបង្អែកដែលផ្តល់ :<br>♦ យោបល់ឯកទេសស្តីពីជំងឺកាមរោគ<br>♦ មានមន្ទីរពិសោធន៏ផ្នែកជំងឺកាមរោគ<br>♦ ថែទាំអ្នកជំងឺដែលបញ្ជូនមកពីកន្លែង មិនមែនឯកទេស<br>♦ ជាមជ្ឈមណ្ឌលសំរាប់អប់រំបណ្តុះបណ្តាលឯកទេសសំរាប់បុគ្គលិកសុខាភិបាល<br>♦ ផ្តល់សេវាថែទាំប្រចាំថ្ងៃជូនដល់អ្នកជំងឺ<br>♦ ធ្វើការស្រាវជ្រាវ<br>♦ រៀបរៀងគោលការណ៏ណែនាំផ្នែកបច្ចេកទេស |
| គ្លីនិកមិនមែនឯកទេស ឧទាហរណ៏ មណ្ឌលសុខភាព គ្លីនិកផែនការគ្រួសារ ។ល ។ | សេវាស្ទើរតែទាំងអស់គ្មានផ្តល់សេវាថែទាំជំងឺកាមរោគទេ | ♦ ផ្តល់ការណែនាំដំបូងគេដល់អ្នកជំងឺ កាមរោគ ដោយប្រើប្រាស់នូវវិធីថែទាំ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញាដែលរួមបញ្ចូលទាំងការថែទាំដៃគូរួមភេទ និង ជំរុញការប្រើប្រាស់ស្រោមអនាម័យ ផងដែរ ។<br>♦ ស្រាវជ្រាវរកអ្នកជំងឺ ដែលពុំមានរោគសញ្ញា ឧទាហរណ៏:<br>ធ្វើតេស្តរកមេរោគស្វាយ លើស្រ្តីមានផ្ទៃពោះ<br>♦ ជាប្រភពនៃការផ្តល់ពតិមាន និងអប់រំអំពីកាមរោគសំរាប់សហគមន៏ |
| គ្រូពេទ្យឯកជន | ♦ ផ្តល់សេវា ថែទាំជំងឺកាមរោគ | ♦ ជាផ្នែកមួយនៃការធ្វើសមាហរណកម្ម នៃសេវាថែទាំកាមរោគ<br>♦ ប្រើវិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ចំពោះកន្លែងដែលគ្មានមន្ទីរពិសោធន៏ជួយគាំទ្រ<br>♦ យកចិត្តទុកដាក់កាន់តែខ្លាំងថែមទៀត លើការអប់រំ និងការជំរុញការប្រើប្រាស់ ស្រោមអនាម័យ ។ |
| អង្គការមិនមែនរដ្ឋាភិបាល | ♦ ផ្តល់សេវា ថែទាំជំងឺកាមរោគ | ♦ ដូចគ្នានឹងគ្រូពេទ្យឯកជនដែរ |

| | | |
|---|---|---|
| ផ្នែកផ្តល់សេវាក្រៅផ្លូវការ ( ឱសថការី អ្នកលក់ថ្នាំ ពេទ្យ គ្រូឱសថបុរាណ) | ♦ ជារឿយៗ ឱសថការី អ្នកលក់ថ្នាំ ពេទ្យ និង គ្រូឱសថ បុរាណផ្តល់ថ្នាំ អង់ទីប៊ីយ៉ូទិកឱ្យ អ្នកជំងឺពុំបានសម ស្របទេ<br>♦ គ្រូឱសថបុរាណផ្តល់ការថែទាំព្យាបាលតាមបែប បុរាណ | ♦ ផ្តល់ពត៌មាននិងដំបូន្មានស្តីអំពីកាមរោគ និងវិធី បង្ការជំងឺទាំងនេះ<br>♦ ជំរុញនិងលក់ស្រោមអនាម័យដែលមាន គុណភាពល្អ<br>♦ គ្រូឱសថបុរាណអាចផ្តល់ការព្យាបាលតាមបែបបុរាណ បាន ប៉ុន្តែមិនត្រូវពន្យាពេល ដែលត្រូវបញ្ជូន អ្នកជំងឺ ទៅសេវាបង្អែកទេ។ ត្រូវស្វែងយល់អំពី សារៈសំខាន់នៃការផ្តល់ដំបូន្មាន ដល់អ្នកជំងឺ កាមរោគឱ្យទៅទទួលការថែទាំ តាមបែប វេជ្ជសាស្ត្រ ទំនើបនៅក្នុងមូលដ្ឋាន។ |

## តារាងទី ៤.២

| ប្រភេទនៃអ្នកដែលពាក់ព័ន្ធ នឹងការប្រយុទ្ធនឹងជំងឺកាមរោគ | ការលំបាក | ដំណោះស្រាយ |
|---|---|---|
| ថ្នាក់ចាត់ចែងការងារថ្នាក់ជាតិ អ្នកនយោបាយ | ♦ កាមរោគទទួលបានអទិភាពទាប<br>♦ កាមរោគជាបញ្ហាដែលពិបាកលើកយកមកនិយាយក្នុងបញ្ហានយោបាយ<br>♦ ទទួលឥទ្ធិពលពីអ្នកឯកទេសកាមរោគដែលបំរើការងារ ក្នុងរយៈពេលយូរ | ជួបផ្ទាល់ដើម្បីពន្យល់អំពីៈ<br>♦ វិសាលភាពនៃការរាតត្បាត<br>♦ ផលវិបាកយូរអង្វែងរបស់វា<br>♦ ទំនាក់ទំនងជាមួយមេរោគអេដស៍<br>♦ វិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ជាវិធីល្អហើយសមស្របតាមសំរាប់កន្លែងព្យាបាលជាច្រើន ។ ដើម្បីពង្រឹងសារទាំងនេះ គេត្រូវរៀបចំកិច្ចប្រជុំមួយៈ<br>-អ្នកឯកទេសកាមរោគថ្នាក់ជាតិ( ជាពិសេសអ្នកណាដែល យល់ព្រមប្រើ វិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញានៅតាមគ្លីនិកដែលមិនមែនឯកទេស)<br>-អ្នកឯកទេសកាមរោគអន្តរជាតិ<br>-តំណាងអង្គការ WHO,UNICEF,UNFPA |
| អ្នកគ្រប់គ្រងកម្មវិធីថ្នាក់ខេត្ត -ស្រុក | ♦ កាមរោគទទួលបានអទិភាព ទាប<br>♦ កាមរោគពិបាកលើកយកមកនិយាយក្នុង បញ្ហានយោបាយ<br>♦ ទទួលឥទ្ធិពលពីអ្នកឯកទេសកាមរោគដែលបំរើការងារយូរ<br>♦ ជឿថា ការព្យាបាលកាមរោគនៅមណ្ឌលសុខភាព ពុំសមស្របទេ<br>♦ ដឹងថាបុគ្គលិកមណ្ឌលសុខភាព មានភាពស្ទាត់ជំនាញតិចណាស់ក្នុងការថែទាំកាមរោគ | ដំបូងធ្វើការទាក់ទងផ្ទាល់តែជាមួយខេត្ត-ស្រុក ដែលគួរនឹងធ្វើគំរោងសាកល្បង ។ នៅកន្លែងទាំងនេះ សូមបង្កើតឡើងនូវគំរោងសាកល្បង ។ ពង្រីកកម្មវិធីនេះនៅពេលដែលទទួលជោគជ័យ ។<br>ជួបប្រជុំផ្ទាល់ ដូចខាងលើដែរ។ រៀបកិច្ចប្រជុំជាមួយអ្នកឯកទេសកាមរោគជើងចាស់។ ធ្វើឱ្យមានការចូលរួមរបស់អ្នកចូលរួមថ្នាក់ខេត្ត-ស្រុកក្នុងការរៀបរៀងកម្មវិធីជាតិ ឬ ខេត្តប្រយុទ្ធនឹងជំងឺកាមរោគ |

| | | |
|---|---|---|
| អ្នកឯកទេសខាងកាមរោគ | ♦ ជឿថាវិធីថែទាំដោយពឹងផ្អែក លើចង្កោមរោគសញ្ញា ជាវិធីមិនមាន លក្ខណៈវិទ្យាសាស្ត្រ<br>♦ ជឿថាគួរបណ្តុះបណ្តាលមណ្ឌលសុខភាព អំពីការផ្តល់សេវាថែទាំកាមរោគបានទេ<br>♦ បារម្ភថា នឹងមានអ្នកជំងឺកាន់តែតិចទៅៗ ពិគ្រោះជំងឺនៅគ្លីនិកឯកជន | ជួបផ្ទាល់ដើម្បីពន្យល់:<br>♦ បង្ហាញអំពីវិសាលភាពនៃការរាតត្បាតនៃជំងឺកាមរោគ និងពន្យល់ថាមានអ្នកជំងឺតែមួយភាគតូចប៉ុណ្ណោះ ដែលទៅកាន់គ្លីនិក កាមរោគ<br>♦ ពន្យល់ថាការពង្រីកសេវាថែទាំកាមរោគនៅថ្នាក់មណ្ឌលសុខភាព ពុំបានធ្វើបាត់បង់តួនាទីរបស់គ្លីនិកឯកទេសទេ។<br>♦ សង្កត់ធ្ងន់លើតួនាទីសំខាន់ នៃគ្លីនិកកាមរោគ ជាមជ្ឈមណ្ឌលបង្អែក<br>♦ កែលំអសេវាគ្លីនិក ដើម្បីធ្វើឱ្យមជ្ឈមណ្ឌលឯកទេស សំរេចបាននូវការផ្តល់សេវា អប្បរមាទាំងនេះ<br>♦ រៀបចំវគ្គបណ្តុះបណ្តាល សំរាប់អ្នកឯកទេសជើងចាស់ស្តីអំពី វិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា<br>♦ រៀបចំឱ្យអ្នកឯកទេស ជំងឺកាមរោគជើងចាស់ទៅធ្វើទស្សនៈកិច្ចសិក្សានៅប្រទេសណាមួយ ដែលទទួលបានជោគជ័យក្នុងការអនុវត្តវិធីគ្រប់គ្រងថែទាំកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។ |

| | | |
|---|---|---|
| បុគ្គលិកមណ្ឌលសុខភាព | ♦ យល់ថាពុំអាចទប់ទល់ នឹងការងារបានកាន់តែច្រើនថែមទៀត ទេ<br>♦ រារែកក្នុងការផ្តល់សេវាកាមរោគ ដោយសារមានជំនឿនិងអកប្បកិរិយាផ្ទាល់ខ្លួនចំពោះបញ្ហាភេទ និងកាមរោគ<br>♦ យល់ឃើញថាខ្លួនពុំមានភាពស្ទាត់ជំនាញ ដែលចាំបាច់សំរាប់ការផ្តល់សេវាទេ<br>♦ បុគ្គលិកនៅគ្លីនិកពន្យាកំណើត ពុំទំលាប់ក្នុងការធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺទេ | រៀបចំកិច្ចប្រជុំជាមួយអ្នកគ្រប់គ្រង និងបុគ្គលិកដើម្បីៈ<br>♦ ពន្យល់អំពីវិសាលភាព នៃការរាតត្បាត និងសារៈសំខាន់នៃការពង្រីកសេវាកាមរោគ<br>♦ សង្កត់ធ្ងន់ថាពួកគេទំនងជាធ្លាប់ជួបអ្នកជំងឺកាមរោគ ជាច្រើនដែលពុំបានទទួលការព្យាបាល ( ជាពិសេសស្ត្រីភេទ)<br>♦ ពន្យល់ពីវិធីថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ដោយសង្កត់ធ្ងន់ថាវិធីនេះត្រូវចំណាយពេលវេលាតិចតួច តែប៉ុណ្ណោះសំរាប់ពិនិត្យអ្នកជំងឺ<br>♦ ពន្យល់ថាបុគ្គលិកស្ទើរតែទាំងអស់ សុទ្ធតែមានភាពស្ទាត់ជំនាញ រួចហើយ<br>♦ ពន្យល់ថាពួកគេ នឹងទទួលការបណ្តុះបណ្តាល មុននឹងផ្តល់សេវាកាមរោគ |
| គ្រូពេទ្យកាមរោគឯកជន (ដែលមិនបំរើការងារនៅគ្លីនិកឯកទេស ខាងកាមរោគផ្នែកសាធារណៈ ផងដែរ) | ♦ មិនយកចិត្តទុកដាក់ ឬយកចិត្តទុកដាក់តិចតួច លើទិដ្ឋភាពសុខាភិបាលសាធារណៈនៃកាមរោគ<br>♦ អ្នកខ្លះពុំបានទទួលការបណ្តុះបណ្តាលត្រឹមត្រូវ ទេ<br>♦ គ្រូពេទ្យភាគច្រើនពុំមានមន្ទីរពិសោធន៍ ដើម្បីជាជំនួយក្នុងការធ្វើរោគវិនិច្ឆ័យទេ ហើយពឹងផ្អែកលើការធ្វើរោគវិនិច្ឆ័យគ្លីនិក | ♦ ខិតខំប្រឹងប្រែង ជួបទាក់ទង តាមរយៈសមាគមគ្រូពេទ្យ<br>♦ ពិចារណាលើការ ផ្តល់សេវាកាមរោគ ដោយគ្រូពេទ្យ ឬបុគ្គលិកសុខាភិបាលដែលពុំបានទទួលការបណ្តុះបណ្តាល ។ |
| ឱសថការី អ្នកលក់ថ្នាំពេទ្យ គ្រូឱសថបុរាណ | មានចំណេះដឹងតិចតួចស្តីអំពីជំងឺកាមរោគ ជារឿយៗ ការព្យាបាលពុំមានប្រសិទ្ធិភាព | ♦ ជួបទាក់ទងជាមួយផ្ទាល់ និងរៀបចំកិច្ចប្រជុំដើម្បីលើកទឹកចិត្ត ឱ្យមានការបញ្ជូនអ្នកជំងឺ ទៅកាន់សេវាសុខាភិបាលឱ្យបានទាន់ពេលវេលា<br>♦ រៀបចំកម្មវិធីបណ្តុះបណ្តាល<br>♦ ពង្រឹងបណ្តាញក្នុងការបញ្ជូនអ្នកជំងឺ ទៅកាន់សេវាវេជ្ជសាស្ត្រដែលស្ថិតនៅក្នុងសហគមន៍ |

## ៤.៣ ការផ្តល់សេវាថែទាំកាមរោគដែលមានលក្ខណះគ្រប់ជ្រុងជ្រោយ

សេវាថែទាំកាមរោគត្រូវដើរតួសំខាន់មួយទៀត ក្នុងការកាត់បន្ថយការរាលដាល នៃកាមរោគតាមរយៈ :

- ♦ **ការអប់រំអ្នកជំងឺអំពីការបង្ការ ការចំលងជំងឺបច្ចុប្បន្ន ទៅអ្នកដទៃទៀត**
- ♦ **ការជួយឱ្យអ្នកជំងឺប្រាប់ដៃគូរបស់ខ្លួន ថា ពួកគេអាចកើតកាមរោគ និងលើកទឹកចិត្ត ឱ្យដៃគូទាំងនោះ មកស្វែងរកការព្យាបាល ។**
- ♦ **ការអប់រំអ្នកជំងឺអំពីការបង្ការការចំលងជំងឺកាមរោគនាអនាគត ជាពិសេសតាមរយៈការប្រើប្រាស់ស្រោមអនាម័យ ។**

ការផ្តល់ការថែទាំកាមរោគប្រកបដោយលក្ខណះគ្រប់ជ្រុងជ្រោយមានន័យថា មុនពេលដែលអ្នកជំងឺម្នាក់ៗចេញពីគ្លីនិក ពួកគេត្រូវៈ

- ♦ **យល់អំពីសារៈសំខាន់នៃការប្រើប្រាស់ឱសថដែលផ្តល់ឱ្យ**
- ♦ **យល់អំពីសារៈសំខាន់នៃការមកកាន់គ្លីនិកសាជាថ្មី ដើម្បីធ្វើការតាមដានការវិវត្តរបស់អ្នកជំងឺ**
- ♦ **យល់អំពីសារៈសំខាន់នៃការប្រាប់ដៃគូរួមភេទ និងរបៀបដែលត្រូវប្រាប់អ្នកនោះ**
- ♦ **ដឹងពីវិធីបង្ការខ្លួនកុំឱ្យកើតកាមរោគសាជាថ្មីនាអនាគត**
- ♦ **ដឹងអំពីរបៀបប្រើប្រាស់ស្រោមអនាម័យ និងវិធីដែលត្រូវប្រើប្រាស់ស្រោមអនាម័យ ។**

ចំនុចទាំងនេះមានន័យ អ្នកជំងឺត្រូវទទួលនូវពតិមានជាច្រើននៅពេលដែលខ្លួនទៅពិគ្រោះជំងឺនៅគ្លីនិក ។ អ្នកផ្តល់ពតមាននិងពេលវេលាដែលត្រូវផ្តល់ពតមានទាំងនេះ ប្រែប្រួលពីកន្លែងមួយទៅកន្លែងមួយ ។

ក៏ប៉ុន្តែបុគ្គលិកសុខាភិបាលគ្រប់ៗរូប( ទោះជាវេជ្ជបណ្ឌិត គ្រូពេទ្យ គិលានុបដ្ឋាយិកាក្តី) ត្រូវដឹងអំពីទិដ្ឋភាពទាំងអស់នេះ ហើយត្រូវឆ្លៀតឱកាសពង្រឹងនូវសារស្តីអំពីការអប់រំអ្នកជំងឺ ។

ការគ្រប់គ្រងដៃគូរួមភេទ ការជំរុញការប្រើប្រាស់ស្រោមអនាម័យ និងការងារចុះអប់រំផ្ទាល់ដល់ក្រុម " ស្នូល " ដែលជាប្រភពនៃការចំលងកាមរោគ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

### P <u>ការគ្រប់គ្រងថែទាំដៃគូរួមភេទ</u>

រាល់បុគ្គលិកសុខាភិបាល ដែលមានភារៈកិច្ច ព្យាបាលអ្នកជំងឺកាមរោគ ត្រូវពិភាក្សាជាមួយគាត់អំពីការជួយដល់ដៃគូរួមភេទរបស់គាត់ ។ ការពិភាក្សានេះត្រូវធ្វើឡើងនូវបញ្ហាលំបាកៗជាច្រើន ។ ឧទាហរណ៍ :

- ♦ **ប្រសិនបើកាមរោគនេះឆ្លងពីដៃគូរួមភេទដោយថៃជន្យ តើយើងត្រូវគិតយ៉ាងណាចំពោះដៃគូទៀងទាត់ ?**
- ♦ **ប្រសិនបើអ្នកជំងឺមានដៃគូតែមួយគត់ តើគាត់គិតយ៉ាងណាចំពោះការប្រព្រឹត្ត ចំពោះដៃ គូរបស់គាត់ ?**

- **តើត្រូវប្រាប់ដៃគូថា គាត់ឆ្លងកាមរោគដោយវិធីណា ?**

- **តើត្រូវធ្វើយ៉ាងដូចម្តេច ចំពោះដៃគូ ជាអ្នករកស៊ីផ្លូវភេទ ?**

**វិធីបញ្ជូនអ្នកជំងឺ**

នៅពេលដែលអ្នកជំងឺប្រាប់ដៃគូរបស់ខ្លួនអំពីជំងឺកាមរោគ ***គេហៅថាការបញ្ជូនដោយអ្នកជំងឺ ។*** ប្រសិនបើគ្លីនិកប្រាប់ដៃគូរួមភេទ ( ដោយមានការយល់ព្រមពីអ្នកជំងឺ ) ***គេហៅថាការបញ្ជូន ដោយអ្នកផ្តល់សេវា ។***

ជោគជ័យដែលគ្លីនិកសំរេចបាន ក្នុងការហៅដៃគូមកទទួលការព្យាបាលតាមរយៈការបញ្ជូនដោយអ្នកជំងឺ មានការប្រែប្រួលយ៉ាងខ្លាំង ។ ជូនកាលគ្លីនិកសំរេចបានជោគជ័យតិចតួចក្នុងការគ្រប់គ្រងថៃទាំដៃគូរួមភេទរបស់អ្នកជំងឺ ( ឧទាហរណ៍ ប្រសិនបើអ្នកជំងឺភាគច្រើនជាអ្នករកស៊ីផ្លូវភេទ) ។ ជារឿយៗគ្លីនិកពុំសូវប្រឹងប្រែងលើកទឹកចិត្តអ្នកជំងឺឱ្យបញ្ជូនដៃគូរួមភេទរបស់ខ្លួនឱ្យមកទទួល ការព្យាបាលទេ ។

ភស្តុតាងមួយចំនួនបានបញ្ជាក់ឱ្យឃើញថា គេអាចធ្វើឱ្យប្រសើរឡើងនូវការបញ្ជូនដៃគូរួមភេទឱ្យមកទទួលការព្យាបាលបាន ២០%-៥០% តាមរយៈមធ្យោបាយសាមញ្ញៗ និងមិនចាំបាច់ចំណាយថវិការច្រើន ដូចជា :

- **បណ្តុះបណ្តាលបុគ្គលិកសុខាភិបាលឱ្យចេះប្រាប់អ្នកជំងឺ អំពីវិធីដែលគាត់ត្រូវនិយាយប្រាប់ដៃគូរួមភេទរបស់គាត់ថា ដៃគូនេះអាចឆ្លងកាមរោគ**

- **ប្រើប្រាស់ប័ណ្ណបញ្ជូនដែលអ្នកជំងឺ ត្រូវយកទៅឱ្យដៃគូរបស់ខ្លួន**

- **ធានាយ៉ាងណាឱ្យសេវាថៃទាំកាមរោគមានលក្ខណៈទាក់ទាញទឹកចិត្តអ្នកជំងឺ ហើយការបង់ថ្លៃព្យាបាលត្រូវមានលក្ខណៈសមស្រប ។**

- **បញ្ចូលនៅការផ្តល់ពតិមាននឹងអប់រំអំពីការបញ្ជូនអ្នកជំងឺទៅក្នុងសំភារៈអប់រំ ឬ សកម្មភាពជុំរុញលើកកំពស់សុខភាព ។**

***ការបញ្ជូនដោយអ្នកផ្តល់សេវា*** ដែលត្រូវធ្វើឡើងដោយគ្លីនិកកាមរោគដែលជាអ្នកជួបទាក់ទងផ្ទាល់ ជាមួយដៃគូជាវិធីមួយដែលតំរូវឱ្យមានការចំណាយថវិការច្រើន ហើយជារឿយៗពុំសូវមានប្រសិទ្ធភាពទេ ។ វាមានតួនាទីតិចតួចណាស់ក្នុងការកំរិតការរាលដាលនៃជំងឺកាមរោគ ។ ក៏ប៉ុន្តែ បើសិនអ្នកជំងឺប្រាប់ប្រភពចំលងនោះ ( ដូចជានៅតាមផ្ទះបន ឬកន្លែងម៉ាស្សា ជាដើម ) ពតិមាននេះអាចបង្ហាញឱ្យអ្នកគ្រប់គ្រងកម្មវិធីដឹងថាត្រូវតែធ្វើសកម្មភាពផ្តោតទៅប្រភពនៃការចំលងកាមរោគនេះ ។

P **ការជំរុញការប្រើប្រាស់និងការផ្តល់ស្រោមអនាម័យ**

ពេលដែលអ្នកជំងឺម្នាក់មកទទួលការព្យាបាលកាមរោគ គឺជាឱកាសដ៏ល្អមួយសំរាប់បុលិគ្គសុខាភិបាលក្នុងការផ្តល់ពិតមានស្តីអំពីគ្រោះថ្នាក់នៃកាមរោគ និងការបង្ការជំងឺទាំងនោះតាមរយៈការប្រើប្រាស់ស្រោមអនាម័យ ។

គេត្រូវបណ្ដុះបណ្ដាលបុគ្គលិកនៃគ្លីនិកកាមរោគ ឱ្យធ្វើសកម្មភាពលើសពីការគ្រាន់តែប្រាប់អ្នកជំងឺឱ្យប្រើប្រាស់ស្រោមអនាម័យ ។

បុគ្គលិកសុខាភិបាលត្រូវតែពន្យល់ :

- **ថាការប្រើប្រាស់ស្រោមអនាម័យបានត្រឹមត្រូវ អាចបង្ការ ការឆ្លងរោគបាន**
- **ថាការប្រើប្រាស់ស្រោមអនាម័យ បានត្រឹមត្រូវអាច មានប្រសិទ្ធិភាពក្នុងការបង្ការភាពមានគភ៌បាន**
- **ថាស្រោមអនាម័យ ទំនើប ហើយដែលមានគុណភាពល្អពុំកាត់បន្ថយនូវគុណភាពនៃការរួមភេទទេ**
- **ការបង្ហាញអំពី វិធីប្រើប្រាស់ស្រោមអនាម័យ ។**

បុគ្គលិកនៃគ្លីនិកកាមរោគត្រូវធានាថា រាល់អ្នកជំងឺដែលចាកចេញពីគ្លីនិក ទទួលបាននូវស្រោមអនាម័យ ដើម្បីឱ្យគេយកវាទៅប្រើប្រាស់។ ការប្រសើរបំផុត គឺត្រូវធានាឱ្យមានស្រោមអនាម័យគ្រប់គ្រាន់ដើម្បីឱ្យអ្នកជំងឺ អាចយកវាឱ្យបានច្រើនបំផុតសំរាប់ប្រើប្រាស់នៅពេលគេត្រូវការ។ ប្រសិនបើ ធ្វើបែបនេះពុំបានទេនោះគេត្រូវលក់ស្រោមអនាម័យក្នុងតំលៃមួយថោកបំផុតទៅតាមលទ្ធភាពដែលអាចធ្វើទៅបាន ។

ត្រូវធ្វើឱ្យគ្លីនិកកាមរោគ ក្លាយជាប្រភពនៃការផ្ដល់ស្រោមអនាម័យដែលមានគុណភាពនិងមានតំលៃថោក សំរាប់មនុស្សគ្រប់ៗរូបនៅក្នុងសហគមន៍។ ត្រូវរិះរកគ្រប់មធ្យោយដើម្បីឱ្យមនុស្សអាចទទួលយកស្រោមអនាម័យ ដោយគ្មានការអៀនខ្មាស ។

**លំហាត់ ៤.២**

**ការពិភាក្សាតាមក្រុម**

សូមពិនិត្យរកមើលបញ្ជីនៃសេវាកន្លែងដែលអាចផ្ដល់សេវាថែទាំកាមរោគនៅខេត្តរបស់អ្នក ។

សូមពិចារណាមើល:

- សេវាផ្សេងៗ ( ក្រៅអំពីការធ្វើរោគវិនិច្ឆ័យនឹងការព្យាបាល ) ដែលអាចផ្ដល់ជូននៅកន្លែងទាំងនោះ
- រៀបរាប់អំពីការលំបាកដែលអាចកើតមានឡើងនៅពេលដែលយើងបញ្ចូលសេវានេះទៅក្នុងសកម្មភាពនៃកន្លែងដែលផ្ដល់ការថែទាំកាមរោគទាំងនោះ
- ចំពោះបញ្ហានិមួយៗ សូមលើកឡើងនូវវិធីដោះស្រាយដែលអ្នកអាចយកមកប្រើប្រាស់នៅក្នុងស្ថានភាពខេត្តរបស់អ្នក។

## ៤.៤ ការជំរុញឱ្យមានការប្រើប្រាស់នូវសេវាផ្តល់ការព្យាបាលកាមរោគ

ការផ្តល់សេវាថែទាំកាមរោគនៅតាមសេវាថែទាំសុខភាពនានា ឱ្យបានច្រើនបំផុតមានសារៈសំខាន់ណាស់ ។ នេះមានន័យថា អ្នកដែលយល់ថាខ្លួនអាចកើតកាមរោគអាចទទួលនូវការផ្តល់ដំបូន្មានផ្សេងៗ និងការព្យាបាលបានយ៉ាងងាយស្រួល ។

ក៏ប៉ុន្តែមនុស្សជាច្រើនមិនព្រមទៅកាន់គ្លីនិកដើម្បីទទួលយកការព្យាបាលទេ ឬក៏ទៅទទួលការព្យាបាលក្រោយពីការខកខានអស់រយៈពេលមួយយ៉ាងយូរ ។ នេះបណ្តាលមកពីមូលហេតុមួយចំនួនដូចជា :

- ♦ ពួកគេអាចមិនដឹងថាជំងឺកាមរោគនោះទាមទារឱ្យមានការព្យាបាលនោះទេ ។
- ♦ អ្នកខ្លះយល់ថានឹងត្រូវគេមាក់ងាយ ប្រសិនបើខ្លួនទៅទទួលការថែទាំនៅគ្លីនិកកាមរោគ ឬក៏មានអារម្មណ៍ថាបុគ្គលិកសុខាភិបាលដែលធ្វើការនៅគ្លីនិកនិងប្រព្រឹត្តអំពើឆ្គាំឆ្គងមកលើខ្លួន ។
- ♦ ការផ្តល់សេវាថែទាំកាមរោគ អាចតំរូវអោយបង់ថ្លៃខ្ពស់ពេក (ជាពិសេសចំពោះអ្នកក្រីក្រ ឬ ក្រុម យុវជន) ។

មនុស្សជាច្រើនសាកល្បងព្យាបាលរោគសញ្ញារបស់ខ្លួន ដោយទិញថ្នាំនៅតាមឱសថស្ថាន ឬកន្លែងលក់ថ្នាំ ។ អ្នកខ្លះទៀតអាចទៅទទួលការព្យាបាលពីគ្រូពេទ្យបុរាណ ។

យើងអាចដោះស្រាយបញ្ហាទាំងនេះដោយ :

- ♦ បង្កើតចំណេះដឹង ស្តីអំពីកាមរោគដល់សាធារណៈជន និងក្រុមដែលងាយនឹងទទួលរងនូវគ្រោះថ្នាក់នៃជំងឺកាមរោគ
- ♦ ធានាយ៉ាងណាឱ្យសេវាកាមរោគមានប្រសិទ្ធិភាពខ្ពស់ និងស្វាគមន៍ដល់អ្នកប្រើប្រាស់

P **<u>ការបង្កើតការយល់ដឹងអំពីកាមរោគ</u>**

ប្រជាពលរដ្ឋត្រូវយល់ដឹង :

- ▪ ជាជំងឺកាមរោគកើតមានពិតប្រាកដ និងយល់ដឹងអំពីប្រភេទជំងឺនេះ
- ▪ ភាពធ្ងន់ធ្ងរដែលបណ្តាលមូលពីជំងឺកាមរោគ
- ▪ រោគសញ្ញាទាំងឡាយនៃជំងឺកាមរោគ
- ▪ ជារឿយៗជំងឺកាមរោគពុំមានបង្ហាញចេញជារោគសញ្ញាទេ
- ▪ សារៈសំខាន់នៃការឆាប់ទៅទទួលការព្យាបាលត្រឹមត្រូវ

| ការបង្កើនការយល់ដឹងអំពីកាមរោគ | |
|---|---|
| **ការផ្សព្វផ្សាយតាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មាន (mass media)** | បញ្ចូលពត៌មានស្តីអំពីកាមរោគទៅក្នុងការសំដែងផ្សេងៗក្នុងវិទ្យុនិងទូរទស្សន៍ ដែលគេនិយមស្តាប់និងទស្សនា ។ ការសំដែងរឿងត្រូវបញ្ចូលនូវខ្លឹមសារនៃតំរូវការក្នុងការស្វែងរកការព្យាបាលរាល់រោគសញ្ញាកាមរោគនានា ។ ឬការសំដែងរឿងល្ខោនដែលទាក់ទងនឹងបញ្ហាសុខភាព តំរូវអោយមានការបញ្ចូលនូវការផ្តល់ដំបូន្មានរបស់គ្រូពេទ្យ អំពីសេវាំថែទាំនៅតាមគ្លីនិកកាមរោគនានា ។ តាមរយៈការប្រគុំតន្ត្រីអ្នករៀបរៀងកម្មវិធីអាចជូនដំនឹងអំពី អាស័យដ្ឋាននៃសេវាថែទាំកាមរោគនានាសំរាប់យុវជន ។ |
| **ការផ្តល់ពត៌មានតាមរយៈកាសែត និងទស្សនាវដ្តី** | អត្ថបទស្តីអំពីកាមរោគបញ្ចូលសារអប់រំទៅក្នុងរឿងខ្លីៗ រឿងកំប្លែង ។ល។ |
| **ការធ្វើសកម្មភាពនៅ តាមសាលារៀននិងមហាវិទ្យាល័យនានា** | បន្ថែមពត៌មានស្តីអំពីកាមរោគទៅក្នុងការអប់រំស្តីអំពីជំងឺអេដស៏ ឬសកម្មភាពអប់រំសុខភាពផ្សេងៗទៀត ។ សាលារៀននិងមហាវិទ្យាល័យមួយចំនួនមានសមាគមនិសិត្ស ឬក្រុមថែទាំសុខភាពផ្សេងៗ ។ ត្រូវធានាយ៉ាងណាឱ្យក្រុមទាំងនេះយល់ដឹង អំពីជំងឺកាមរោគ និងកន្លែងដែលអាចទៅទទួលការព្យាបាលដើម្បីឱ្យក្រុមនេះអាចផ្សព្វផ្សាយ ពត៌មាននេះទៅកាន់អ្នកដទៃទៀត ។ |
| **ការជួបប្រាស្រ័យទាក់ទងជាមួយថ្នាក់ដឹកនាំនានា** | ធានាយ៉ាងណាឱ្យអ្នកដឹកនាំនយោបាយ សាសនា វិជ្ជាជីវៈផ្សេងៗទៀត យល់ដឹងអំពីសារៈសំខាន់ក្នុងការកាត់បន្ថយជំងឺកាមរោគ និងតំរូវការក្នុងការអប់រំប្រជាជនអំពីជំងឺកាមរោគ ។ |

គេត្រូវធ្វើការខិតខំប្រឹងប្រែង ជាពិសេសក្នុងការធ្វើសម្មភាពលើក្រុមជនដែលងាយទទួលរងនូវគ្រោះថ្នាក់នានា ដូចជាស្ត្រីរកស៊ីផ្លូវភេទនិងភ្ញៀវរបស់អ្នកទាំងនោះ ក្រុមយុវជន ក្រុមដែលមាន ការផ្លាស់ទីច្រើន ។ ចំពោះក្រុមទាំងនេះ ការអប់រំត្រូវផ្តោតលើការបង្កើនការយល់ដឹងស្តីអំពីជំងឺកាមរោគ និងតំរូវការក្នុងការស្វែងរកការព្យាបាលនិងដំបូន្មានផ្សេងៗ ពីសេវាថែទាំកាមរោគ ។

សកម្មភាពអប់រំពិសេសៗ អាចបញ្ចូលទៅក្នុងគំរោងផ្តល់កាអេប់រំរវាងអ្នកដែលមានអាជីពដូចគ្នា (peer education) ។ ឧទាហរណ៍:

- ♦ គេអាចបណ្តុះបណ្តាលអ្នករកស៊ីផ្លូវភេទឱ្យផ្តល់ការអប់រំអំពីកាមរោគ ដល់ស្ត្រីរកស៊ីផ្លូវភេទដទៃៗ ទៀត ឬ

- អ្នកចុះអប់រំផ្ទាល់ដែលបានទទួលការបណ្តុះបណ្តាលស្តីអំពីជំងឺកាមរោគអាចអប់រំក្រុមពិសេសៗនានា ដូចជាអ្នកបើកបររថយន្ត អ្នកនេសាទ យោធា នគបាល ។ល។

| ការចុះអប់រំផ្ទាល់ |
| --- |
| សមាជិកនៃក្រុម "ស្នូល" ដែលជាប្រភពចំលងកាមរោគ អាចភាវៃកមិនព្រមទៅទទួលការព្យាបាលនៅតាមគ្លីនិកកាមរោគ ដោយពួកគេ ខ្លាចមានការមាក់ងាយ រើសអើងមកលើពួកគេ ។ ស្ត្រីរកស៊ីផ្លូវភេទ ស្ត្រីរាំតាមរង្គសាល ស្ត្រីបំរើភេសជ្ជៈ មិនងាយទទួលស្គាល់អំពីការប្រព្រឹត្ត របស់ពួកគេនៅតាមគ្លីនិកធម្មតា ទេ ។<br><br>ដោយសារក្រុមដែលប្រឈមមុខ ជាអ្នកបណ្តាលឱ្យមានការរាតត្បាតនៃកាមរោគ (រួមបញ្ចូលទាំងមេរោគអេដស៍ផងដែរ ) នេះជាភស្តុតាងផ្នែកសុខាភិបាលសាធារណៈនិងផ្នែកសេដ្ឋកិច្ច ដែលតំរូវឱ្យមានការផ្តល់សេវាថែទាំនិងបង្ការជំងឺកាមរោគ សំរាប់ពួកគេ ទាំងនោះ ។<br><br>**ការចុះអប់រំផ្ទាល់** ត្រូវអនុវត្ត ទៅដោយការប្រុងប្រយ័ត្នជាទីបំផុត ហើយការថែទាំត្រូវតែ ប្រព្រឹត្តទៅក្នុងលក្ខណៈមិនរើសអើង និងមិនស្តីបន្ទោស ។<br><br>**អ្នក**ចុះអប់រំផ្ទាល់ ត្រូវមានគុណសម្បត្តិពិសេសៗមួយចំនួន ។អ្នកទាំងនោះត្រូវ :<br><br>♦ **ធ្វើឱ្យមានទំនុកចិត្តអំពីសំណាក់អ្នកដែលខ្លួនចុះអប់រំផ្ទាល់** ( ស្ត្រីរកស៊ីផ្លូវភេទ ស្ត្រីបំរើ ភេសជ្ជៈ ។ល។)<br>♦ **មានទំនាក់ទំនងល្អជាមួយសមាជិកនានានៃក្រុម**<br>♦ **មានការជួបទាក់ទងល្អ ជាមួយអ្នកដែលពាក់ព័ន្ធ ជាមួយក្រុមនោះ** ( ដូចជាម្ចាស់រង្គសាល ម្ចាស់បន ។ល ។ )<br>♦ **មានទំនាក់ទំនងល្អជាមួយនគរបាល និងរដ្ឋអំណាចមូលដ្ឋាន**<br>♦ **មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសេវាថែទាំកាមរោគ ដទៃៗទៀត**<br>♦ **មានចំណេះដឹងត្រឹមត្រូវ និងទាន់សភាពការណ៍ស្តីអំពីកាមរោគ មេរោគអេដស៍ នឹងជំងឺអេដស៍**<br>♦ **មានភាពស្ទាត់ជំនាញក្នុងការប្រាស្រ័យទាក់ទង** (សំរាប់ការអប់រំសមាជិកក្រុម "ស្នូល" និងអ្នកដទៃទៀត ដូចជាភ្ញៀវរបស់ស្ត្រីរកស៊ីផ្លូវភេទ និងការបណ្តុះបណ្តាល និងការតាមដានណែនាំអ្នកបង្ហាត់ដទៃៗទៀត ឧទាហរណ៍ដូចជាអ្នកអប់រំក្រុមដែលមានអាជីពដូចគ្នាជាដើម ) |

នៅបណ្តាប្រទេសមួយចំនួន មានការបណ្តុះបណ្តាលអ្នកធ្វើការងារនៅតាមឱសថស្ថាននានា ស្តីអំពីការអប់រំនិងផ្តល់ប្រឹក្សាស្តីអំពីកាមរោគនឹងការបញ្ជូនអ្នកជំងឺកាមរោគទៅកាន់គ្លីនិកដើម្បីទទួលការព្យាបាល ។

នៅកន្លែងភាគច្រើន គេត្រូវស្វែងរកមធ្យោបាយដើម្បីជួបទាក់ទងផ្ទាល់ជាមួយក្រុម " ស្នូល" និងជំរុញអោយគេប្រើប្រាស់សេវាថែទាំកាមរោគ ។

P **ធានាឱ្យសេវាផ្តល់ការថែទាំកាមរោគមានប្រសិទ្ធិភាព និងរាក់ទាក់ និងមិនមាក់ងាយ ដល់អ្នកជំងឺ**

ជាញឹកញាប់ស្ត្រីរកស៊ីផ្លូវភេទ ស្ត្រីបំរើភេជ្ជសៈនិងក្រុមផ្សេងៗទៀត ដែលជាប្រភពនាំឱ្យមានការរាតត្បាតនៃជំងឺកាមរោគ មិនព្រមប្រើប្រាស់នូវសេវាថែទាំកាមរោគទេ ។ ប្រសិនបើក្រុមទាំងនោះ ប្រើប្រាស់នៅសេវាថែទាំ ពួកគេមិនងាយប្រាប់ឱ្យដឹងអំពីការប្រព្រឹត្តរបស់គេទេ ។ បណ្តាប្រទេសមួយចំនួន មានគ្លីនិកពិសេសសំរាប់ថែទាំអ្នកទាំងនោះប្រកបដោយជោគជ័យនឹងជួបផ្ទាល់ដើម្បីផ្សព្វផ្សាយ អប់រំបង្ការជំងឺ ។ ជារឿយៗ គេបានរកឃើញថាទាំងនេះពុំអាចទទួលបាននៅការបំពេញតំរូវការក្នុងការថែទាំសុខភាពផ្សេងៗទៀតទេ ។ សំខាន់គឺត្រូវបំពេញនូវតំរូវការទាំងនេះផងដែរ ប្រសិនបើអ្នករកស៊ីផ្លូវភេទមកទទួលថែទាំនៅតាមគ្លីនិកទាំងនោះ ។

## ៤.៥ សេចក្តីសន្និដ្ឋាន

កាផ្តល់សេវាថែទាំកាមរោគ គ្រាន់តែជាផ្នែកមួយនៃកម្មវិធីបង្ការនិងថែទាំកាមរោគដែលមានលក្ខណៈពហុផ្នែកតែប៉ុណ្ណោះ ។ ក៏ប៉ុន្តែ វាមានតួនាទីដ៏សំខាន់ណាស់ដែរក្នុងការស្វែងរកឱ្យឃើញនិងព្យាបាលកាមរោគ ព្រមទាំងការបង្ការការរាលដាលកាមរោគ ។

គេត្រូវតែពង្រីកសេវាថែទាំកាមរោគឱ្យបានច្រើនបំផុតនៅកំរិតថែទាំសុខភាពបឋម ដើម្បីឱ្យអ្នកដែលយល់ថា ខ្លួនគេកើតកាមរោគអាចទៅទទួលការព្យាលបាល ។

គេត្រូវធ្វើឱ្យការផ្តល់សេវាថែទាំកាមរោគ ដែលផ្តល់ដោយសេវានានាដែលមានស្រាប់ឱ្យកាន់តែមានលក្ខណៈល្អប្រសើរឡើងថែមទៀត ។ សេវាថែទាំកាមរោគដែលមានស្រាប់នឹងសេវាថ្មីៗទៀត ត្រូវតែសហការគ្នាក្នុងការបំពេញភារៈកិច្ចរបស់ខ្លួន ។ ទិដ្ឋភាពទាំងអស់នៃការថែទាំទាំងអស់( មិនមែនកំរិតត្រឹមតែការព្យាបាលប៉ុណ្ណោះទេ ) សុទ្ធតែមានសារៈសំខាន់ជាសារវ័ន្ត ប្រសិនបើគេចង់កាត់បន្ថយការរាល ដាលនៃកាមរោគ ។

ការជំរុញឱ្យមានការប្រើប្រាស់សេវាដល់ការថែទាំកាមរោគ គឺជាផ្នែកមួយនៃការធ្វើឱ្យសេវាថែទាំកាមរោគនេះកាន់តែមាន លក្ខណៈល្អប្រសើរឡើង ។

## ឧបសម្ព័ន្ធទី ១:

### ១- *គោលការណ៍ណែនាំសំរាប់គ្រប់គ្រងកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ /អេដស៍*

### ១-១ ការបង្កើតនិងពង្រឹកផ្នែកប្រយុទ្ធនឹង ជំងឺកាមរោគ ថ្នាក់មជ្ឈឹម

- វាយតំលៃតំរូវការបុគ្គលិក
- ប្រើប្រាស់ឬបណ្តុះបណ្តាលបុគ្គលិកដែលមានស្រាប់
- រៀបចំយន្តការ សំរបសំរួល ជាមួយផ្នែកផ្សព្វផ្សាយអប់រំ

### ១-២. បង្កើត ពង្រឹងរចនាសម្ព័ន្ធគ្រប់គ្រងថ្នាក់ខេត្ត ឬស្រុក

- វាយតំលៃប្រភពធនធានដែលមាន
- រៀបចំយន្តការប្រាស្រ័យទាក់ទងជាមួយផ្នែកគ្រប់គ្រងថ្នាក់មជ្ឈឹម
- ពិនិត្យតាមដានសកម្មភាព
- លើកកំពស់គំរោងចុះត្រួតពិនិត្យណែនាំ

### ១-៣. បង្កើតគណៈកម្មការពិគ្រោះយោបល់ស្តីអំពីជំងឺកាមរោគ

- កំណត់សមាជិកនៃគណៈកម្មការឱ្យបានទៀងទាត់
- ផ្សព្វផ្សាយលទ្ធផលនៃកិច្ចប្រជុំដល់ថ្នាក់ដឹកនាំ

### ១-៤ រៀបរៀងគោលនយោបាយយុទ្ធសាស្រ្តជាតិស្តីអំពី ការប្រយុទ្ធនឹងជំងឺកាមរោគ

### ២. *ពង្រឹងការគ្រប់គ្រងព្យាបាលករណីកាមរោគ*

### ២-១. រៀបចំបង្កើតគំនូសបំព្រួញ សំរាប់ថែទាំ (Flowchart)

- រៀបចំសំភារៈកិច្ចប្រជុំថ្នាក់ជាតិ ដើម្បីរៀបរៀងតាក់តែងគោលការណ៍ណែនាំស្តីអំពីការគ្រប់គ្រងថែទាំ រួមទាំងគំនូសបំព្រួញផងដែរ ។
- ធ្វើតេស្តសាកល្បងនូវគំនូសបំព្រួញ នៅតាមកន្លែងសាកល្បង **Pilot areas**
- ធ្វើការកែលំអ ជាលើកចុងក្រោយ បោះពុម្ព បែងចែកគំនូសបំព្រួញ
- កែលំអ គំនូសបំព្រួញរៀងរាល់ ២-៣ ឆ្នាំ ម្តង។

## ២-២. ពង្រឹងការគ្រប់គ្រងថែទាំករណីកាមរោគនៅផ្នែកសាធារណៈ

- ធ្វើបញ្ជីសារពើភ័ណ្ឌនៃទីកន្លែងថែទាំ
- វាយតំលៃតំរូវការផ្នែកសំភារៈ បរិក្ខារ
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាល
- ប៉ាន់ស្មាន តំរូវការឱសថ សំរាប់ព្យាបាលជំងឺកាមរោគ និងស្រោមអនាម័យ
- រៀបរៀងនិងកែលំអកម្មវិធីសំរាប់បណ្តុះបណ្តាល
- បណ្តុះបណ្តាលគ្រូបង្គោល
- រៀបចំកាលវិភាគបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលបន្តទៀត
- ទិញនិងបែងចែកសំភារៈបរិក្ខារ
- រៀបចំភស្តុតាងឱសថ
- បណ្តុះបណ្តាលការគ្រប់គ្រងការស្តុកឱសថ
- តាមដានត្រួតពិនិត្យ ការប្រើប្រាស់សេវាគ្លីនិក និងការអនុវត្តន៏សកម្មភាពថែទាំ
- ធ្វើការបណ្តុះបណ្តាលបន្ត
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាល
- តាមដានត្រួតពិនិត្យ ការអនុវត្ត សកម្មភាព ថែទាំ
- លើកគំរោងបណ្តុះបណ្តាលបន្ត

## ២-៣. ពង្រឹង ការគ្រប់គ្រងថែទាំករណីកាមរោគនៅផ្នែកឯកជន

- ធ្វើឱ្យមានការចូលរួមពីសមាគមគ្រូពេទ្យនិងគ្រូពេទ្យឯកជន
- ធ្វើបញ្ជីសារពើភ័ណ្ឌអំពីអ្នកផ្តល់ សេវាថែទាំ និងតំរូវការក្នុងការបណ្តុះបណ្តាល
- រៀបរៀងនិងកែលំអ ម៉ូឌុលសំរាប់បណ្តុះបណ្តាល
- រៀបចំសិក្ខាសាលាបណ្តុះបណ្តាល
- តាមដានត្រួតពិនិត្យ ការអនុវត្តន៏សកម្មភាព ថែទាំ
- លើកគំរោងបណ្តុះបណ្តាលបន្ត

## ២-៤. ធ្វើការផ្តល់សេវាថែទាំកាមរោគដល់ស្ត្រីកាន់តែមានលក្ខណៈល្អប្រសើរ ឡើង

- ធ្វើការសាកល្បងគំរោងធ្វើសមាហរណកម្មសេវាថែទាំកាមរោគ នៅក្នុងគ្លីនិកគាំពារមាតា និងទារក និងពន្យាកំណើត
- វាយតំលៃលទ្ធភាព
- ពង្រីកការផ្តល់សេវាថែទាំ កាមរោគទៅកាន់កន្លែងផ្សេងៗទៀត

## ២-៥. ពង្រឹងសកម្មភាពមន្ទីរពិសោធន៍ បង្អែកជាតិ

- វាយតំលៃតំរូវការខាងសំភារៈ និងបរិក្ខារ
- វាយតំលៃតំរូវការក្នុងការបណ្តុះបណ្តាលទិញ សំភារៈ និងបរិក្ខារ
- បណ្តុះបណ្តាលអ្នកបច្ចេកទេសមន្ទីរពិសោធន៍
- តាមដានត្រួតពិនិត្យសកម្មភាព

## ២-៦. ការប្រយុទ្ធនឹងជំងឺស្វាយពីកំណើត (Control of congenital syphilis)

- ប៉ាន់ស្មានចំនួនស្ត្រី ដែលមកពិនិត្យផ្ទៃពោះ មុនពេលសំរាល
- កំនត់អំពីការគាំទ្រមន្ទីរពិសោធន៍ ( នៅក្នុង ឬ មានទំនាក់ទនង ជាមួយផ្នែកពិនិត្យផ្ទៃពោះ មុនពេលសំរាល )
- ទិញសំភារៈ និងបរិក្ខាររួមទាំងប្រតិករសំរាប់ធ្វើតេស្តរកជំងឺស្វាយ (RPR ,VDRL )
- ចាប់ផ្តើមដំណើរការធ្វើតេស្ត រកមេរោគស្វាយ ចំពោះស្ត្រី ដែលមកពិនិត្យផ្ទៃពោះ មុនពេលសំរាលនៅពេលមកពិនិត្យផ្ទៃពោះលើកដំបូង ( ប្រសិនបើមានលទ្ធភាពនៅត្រីមាសទី ៣ នៃ គិភ) ។
- ព្យាបាលស្ត្រីនិងដៃគូរបស់គាត់ ដែលមានលទ្ធផលវិជ្ជមាន
- បង្កើតយន្តការធ្វើរបាយការណ៍
- តាមដានត្រួតពិនិត្យសកម្មភាព

## ២-៧. ការបង្ការជំងឺរលាកភ្នែកលើទារកទើបនឹងកើត (Ophtalmia neonatorum)

- ធ្វើបញ្ជីសារពើភ័ណ្ឌនៃកន្លែងសម្ភព
- ប៉ាន់ស្មានចំនួននៃការសំរាលកូននៅក្នុងផ្នែកសម្ភពទាំងនោះ
- ទិញនិងបែងចែកឱសថសំរាប់បង្ការជំងឺរលាកភ្នែកលើទារកទើបនឹងកើត ។
- បណ្តុះបណ្តាលបុគ្គលិកសុខាភិបាលស្តីអំពី ការអនុវត្តវិធានការណ៍បង្ការ
- អនុវត្តវិធានការណ៍បង្ការជំងឺរលាកភ្នែកលើទារកទើបនឹងកើតលើគ្រប់ទារកទាំងអស់
- ផ្តល់ឱសថសំរាប់ សំរាប់បង្ការជំងឺនេះ ដល់ឆ្មបបុរាណ
- តាមដានត្រួតពិនិត្យ ការអនុវត្តន៍ សកម្មភាព ថែទាំ

## ៣. *ជំរុញសកម្មភាពបង្ការ និងការស្វែងរកការព្យាបាល តាមរយៈការផ្សព្វផ្សាយ អប់រំ*

## ៣-១. *ការផ្សព្វផ្សាយ អប់រំតាមរយៈប្រព័ន្ធ ផ្សព្វផ្សាយពិតមាន*

- កំណត់អំពីក្រុមដែលធ្វើសកម្មភាព ជាអាទិភាព

- កំណត់ឱ្យឃើញអ្នកដឹកនាំក្នុងសហគមន៍
- វាយតំលៃអំពីចំណេះដឹងរបស់ក្រុមជាអាទិភាព
- កំណត់អំពីមធ្យោបាយ ក្នុងការផ្សព្វផ្សាយ
- រៀបរៀងសារ និងសំភារៈអប់រំ ជាមួយសមាជិកនៃក្រុមគោលដៅ
- ធ្វើតេស្តមុនពេលផ្សព្វផ្សាយ រៀបចំ និងបោះពុម្ពឯកសារអប់រំ
- តាមដានត្រួតពិនិត្យ ការអនុវត្តន៏ សកម្មភាព ផ្សព្វផ្សាយ អប់រំ

## ៣-២. ការអប់រំផ្សព្វផ្សាយតាមរយៈអ្នកចុះអប់រំ ផ្ទាល់

- កំណត់រកឱ្យឃើញអ្នកដែលត្រូវធ្វើសកម្មភាពចុះអប់រំផ្ទាល់ជាអាទិភាព
- ធ្វើការស្រាវជ្រាវគុណភាព អំពីចំណេះដឹង និងការអនុវត្ត (ការប្រព្រឹត្ត ប្រឈមមុខនឹងគ្រោះថ្នាក់ការប្រព្រឹត្តស្វែងរក ការថែទាំផ្នែកសុខភាព)
- កំណត់រកឱ្យឃើញនូវ អ្នកអប់រំដែលមានអាជីពដូចគ្នា
- រៀបរៀងនិងកែសំរួលឯកសារឱ្យបានសមស្រប
- បណ្តុះបណ្តាលអ្នកអប់រំ
- តាមដានត្រួតពិនិត្យ ការអនុវត្តន៏សកម្មភាពអ្នកអប់រំ។

## ៣-៣. *ការផ្សព្វផ្សាយ អប់រំតាមរយៈប្រព័ន្ធ ផ្សព្វផ្សាយមានលក្ខណៈប្រពៃណី* (Traditional Media)

- កំណត់រកឱ្យឃើញនូវមធ្យោបាយផ្សព្វផ្សាយសារអប់រំសុខភាព
- រៀបរៀងសំភារៈបណ្តុះបណ្តាល
- ធ្វើការតំរង់ទិស និងបណ្តុះបណ្តាល សិល្បៈករបែបការផលិត
- ការកែលំអការផលិត
- តាមដានត្រួតពិនិត្យ ការអនុវត្តន៏សកម្មភាព។

# ៤. *បង្កើតកម្មវិធីជំរុញការប្រើប្រាស់ស្រោមអនាម័យ ដើម្បីបង្ការជំងឺកាមរោគ*

## ៤-១. បែងចែកស្រោមអនាម័យ តាមរយៈកន្លែងព្យាបាលនានា

- វាយតំលៃតំរូវការស្រោមអនាម័យ
- ទិញស្រោមអនាម័យនិងរៀបចំបង្កើតប្រព័ន្ធបែងចែក
- បណ្តុះបណ្តាលប្រព័ន្ធបុគ្គលិកសុខាភិបាល អំពីការជំរុញ និងការបង្ហាញប្រើប្រាស់ស្រោម អនាម័យ
- បញ្ចូលសកម្មភាពបែងចែកស្រោមអនាម័យ ទៅក្នុងសកម្មភាពគ្រប់គ្រងថែទាំអ្នកជំងឺកាមរោគ
- តាមដានត្រួតពិនិត្យ ការអនុវត្តន៏សកម្មភាពបែងចែក

♦ តាមដានត្រួតពិនិត្យគុណភាពស្រោមអនាម័យ

## ៤-២. *ការផ្សព្វផ្សាយអំពីស្រោមអនាម័យ*

♦ កំណត់រកឱ្យឃើញអង្គការដែលធ្វើសកម្មភាពផ្សព្វផ្សាយ និងអង្គការមិនមែនរដ្ឋាភិបាល នានា

♦ វាយតំលៃតំរូវការស្រោមអនាម័យ

♦ បង្កើតបណ្តាញបែងចែកស្រោមអនាម័យ

♦ តាមដានត្រួតពិនិត្យការលក់ស្រោមអនាម័យ

## ៥. *ការតាមដានត្រួតពិនិត្យការវិវត្តនៃកាមរោគ*

♦ រៀបចំសិក្ខាសាលាថ្នាក់ជាតិមួយ ដើម្បីរៀបចំពិធីសារស្តីអំពីការធ្វើអង្កេតសង់ទីណែល (sentinel surveillance) នៃកាមរោគ

♦ រៀបចំម៉ូឌុលបណ្តុះបណ្តាលសំរាប់ធ្វើការអង្កេតជំងឺកាមរោគ

♦ ជ្រើសរើសកន្លែងសំរាប់ធ្វើអង្កេត និងរៀបចំបណ្តុះបណ្តាល

♦ ផ្គត់ផ្គង់សំភារៈ បរិក្ខារចាំបាច់ដល់កន្លែងទាំងនេះ

♦ វិភាគទិន្នន័យ និងផ្សព្វផ្សាយអំពីលទ្ធផល

## ៦. *ដឹកនាំស្រាវជ្រាវនៅនឹងកន្លែង* (Conduct operational research)

♦ កំណត់អំពីការស្រាវជ្រាវជាអាទិភាព

♦ កំណត់រកឱ្យឃើញ នូវកន្លែងដែលត្រូវធ្វើការស្រាវជ្រាវ

♦ វាយតំលៃតំរូវការ ( សំភារៈ បរិក្ខារ ការបណ្តុះបណ្តាល )

♦ ផ្តល់នូវប្រភពធនធាននានា

♦ បណ្តុះបណ្តាលបុគ្គលិក

♦ ប្រមូលយកលទ្ធផល និងផ្សព្វផ្សាយ ជូនដល់ភាគីដែលពាក់ព័ន្ធ

♦ ធ្វើការកែប្រែកម្មវិធី យោលទៅតាមលទ្ធផល

## ៧. *ការវាយតំលៃ*

♦ ធ្វើផែនការវាយតំលៃកម្មវិធី

♦ ធ្វើការប្រមូល ចងក្រងលទ្ធផលនានា ហើយជូនដំណឹងដល់ ភាគីដែលពាក់ព័ន្ធ

♦ រៀបចំកិច្ចប្រជុំ ជាមួយអ្នកគ្រប់គ្រងកម្មវិធី

♦ រៀបចំផែនការកែលំអ និង ពង្រីកកម្មវិធី

ម៉ូឌុលទី ៥

# ការគ្រប់គ្រងថែទាំជំងឺកាមរោគ ដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

## បញ្ហាដែលកើតមានញឹកញាប់ក្នុងការថែទាំជំងឺកាមរោគ

| | |
|---|---|
| លទ្ធភាពអាចទៅទទួលយកសេវាថែទាំ (access) | ជាញឹកញាប់ សេវាថែទាំកាមរោគត្រូវផ្តល់តាមរយៈគ្លីនិកឯកទេសនានា។ អ្នកជំងឺដែលគិតថាពួកគេអាចមានជំងឺកាមរោគយល់ថា ពួកគេមានការលំបាកក្នុងការប្រើប្រាស់សេវាថែទាំទាំងនេះ ។ នេះបណ្តាលមកពីពួកគេខ្លាចត្រូវបានស្គាល់ថាជាអ្នកជំងឺកាមរោគ ឬបណ្តាលមកពីសេវា មានតំលៃថ្លៃ ពិបាកទៅទទួកយក ឬត្រូវចំណាយពេលច្រើនក្នុងការទៅទទួលសេវា ។ |
| ការព្យាបាល | ថ្នាំព្យាបាលជំងឺកាមរោគមិនអាចនឹងរកបានភ្លាមៗយកមកប្រើប្រាស់បន្ទាប់ពីមានការធ្វើរោគវិនិច្ឆ័យហើយ ។ ជួនកាលអ្នកដែលគិតថាខ្លួនអាចកើតមានជំងឺកាមរោគចូលចិត្តទទួលការព្យាបាលដោយទៅជួបឱសថការី ឬអ្នកលក់ថ្នាំផ្ទាល់ ។ នេះមានន័យថាពួកគេអាចប្រើប្រាស់ថ្នាំដែលមិនបានសមស្រប ។ ក្នុងករណីខ្លះទៀត ពួកគេប្រើប្រាស់ថ្នាំត្រឹមត្រូវ ប៉ុន្តែក្នុងកំរិតមួយមិនគ្រប់គ្រាន់ ។ ការធ្វើបែបនេះជំរុញឱ្យមេរោគមានភាពស៊ាំទៅនឹងការព្យាបាល ។ |
| ការអប់រំ | បុគ្គលិកថែទាំសុខភាពមិនបានចំណាយពេលដើម្បីនិយាយអំពីភាពចាំបាច់ក្នុងការប្រើប្រាស់ស្រោមអនាម័យ ឬមធ្យោបាយដើម្បីបង្ការការឆ្លងរោគនៅអនាគតតាមរយៈការផ្លាស់ប្តូរការប្រព្រឹត្តគ្រប់ពេលវេលាបានទេ។ |
| ការព្យាបាលដៃគូរួមភេទ | ការព្យាបាលដៃគូរួមភេទនៃអ្នកជំងឺកាមរោគជាការចាំបាច់ដើម្បីបញ្ឈប់ការឆ្លងនៅពេលអនាគត ។ ប៉ុន្តែបញ្ហានេះមិនមែនជាការងាយស្រួលទេ ពីព្រោះ អ្នកជំងឺជារឿយៗមិនចង់ប្រាប់ដៃគូរួមភេទរបស់ពួកគេទេ ឬពួកគេមិនអាចទាក់ទងហៅដៃគូរួមភេទរបស់ពួកគេឱ្យមកទទួលការថែទាំបានទេ។ ដៃគូរួមភេទអាចមិនចង់ទទួលការព្យាបាលផងដែរ ពីព្រោះពួកគេភ័យខ្លាច ឬខ្មាស់អៀន។ |

☞ **ការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជាអ្វី?**

ចង្កោមរោគរោគសញ្ញានៃជំងឺកាមរោគ ជាការប្រមូលដាក់ជាក្រុមនូវជំងឺកាមរោគដែលបង្កឱ្យមានជាសញ្ញា និងរោគសញ្ញាដូចគ្នាដាក់ជាក្រុមៗ ។ គំនូសបំព្រួញសាមញ្ញត្រូវបានបង្កើតឡើងដើម្បីជួយអ្នកថែទាំសុខភាពក្នុងការប្រើចង្កោមរោគសញ្ញសំរាប់ធ្វើរោគវិនិច្ឆ័យ ។

ប្រភេទផ្សេងគ្នាជាច្រើននៃអ្នកថែទាំសុខភាពដែលមានភារៈកិច្ចថែទាំអ្នកជំងឺកាមរោគនឹងទទួលបានផលប្រយោជន៍ពីការបណ្តុះបណ្តាលអំពីការប្រើប្រាស់វិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។ អ្នកទាំងនោះអាចជាវេជ្ជបណ្ឌិត គ្រូពេទ្យ គិលានុប្បដ្ឋាយិកា អ្នកអប់រំសុខភាព អ្នកចិត្តវិជ្ជា ឬអ្នកផ្សេងៗទៀត ។

**ចំណុចសង្ខេបទាំង ៩ ស្តីអំពីវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា**

**១. ជំងឺកាមរោគកើតមានជាញឹកញាប់ ហើយនៅពេលដែលមិនបានព្យាបាលវាអាចបង្កឱ្យមានបញ្ហាធ្ងន់ធ្ងរដល់សុខភាព ។ ជំងឺកាមរោគដែលមានរោគសញ្ញាបង្កើនគ្រោះថ្នាក់នៃការឆ្លងមេរោគអេដស៍ ។**

**២. វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាផ្តល់នូវការព្យាបាលជំងឺកាមរោគដែលមានប្រសិទ្ធិភាព និងឆាប់រហ័សជូនអ្នកជំងឺចាប់តាំងពីពេលដែលពួកគេមកទទួលការព្យាបាលជាលើកដំបូង ។**

អ្នកជំងឺដែលព្រួយបារម្ភថា ពួកគេកើតជំងឺកាមរោគអាចទទួលការព្យាបាលត្រឹមត្រូវនៅក្នុងសហគមន៍របស់ពួកគេផ្ទាល់តែម្តង ។ អ្នកជំងឺកាមរោគទទួលបានការព្យាបាលនៅពេលដែលពួកគេមកជួបបុគ្គលិកថែទាំសុខភាពជាលើកដំបូង ។ ទោះជាថ្នាំមានតំលៃថ្លៃក៏ដោយក៏ការព្យាបាលតាមរបៀបនេះ មានតំលៃថោកជាង ការព្យាបាលដែលមានរយៈពេលយូរដែរពីព្រោះអ្នកជំងឺជាច្រើន បានជាសះស្បើយតាំងពីពេលពួកគេមកទទួលការព្យាបាលជាលើកដំបូង ។

**៣. វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជាវិធីល្អសំរាប់ថ្នាក់ថែទាំសុខភាពបឋម**

តេស្តសំរាប់ធ្វើរោគវិនិច្ឆ័យជំងឺកាមរោគជាច្រើនមានតំលៃថ្លៃ ។ តេស្តខ្លះពិបាកធ្វើទាមទារនូវការបណ្តុះបណ្តាលផ្នែកមន្ទីរពិសោធន៍ពិសេសៗឬប្រើគ្រឿងបរិក្ខារដែលទំនើបស៊ាំញ៉ាំ ។

វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកចង្កោមរោគសញ្ញា មិនទាមទារឱ្យប្រើប្រាស់នូវតេស្តទាំងនេះ ដែលជារឿយៗមិនអាចរកបាន ។ វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាសមរម្យណាស់សំរាប់សេវាថែទាំសុខភាពបឋម និងបុស្តិ៍ថែទាំសុខភាពជនបទ ពីព្រោះដោយសារហេតុផលដែលបានរៀបរាប់ខាងលើទាំងនេះ និងពីព្រោះ វាអាចត្រូវប្រើប្រាស់បានដោយអ្នកថែទាំសុខភាពគ្រប់ប្រភេទទាំងអស់ ។

## ៤. វិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាផ្តោតទៅលើជំងឺកាមរោគញឹកញាប់ភាគច្រើនដែលអាចព្យាបាលជា

ជំងឺកាមរោគដែលកើតជាញឹកញាប់ភាគច្រើន ដែលអាចព្យាបាលជាមានជំងឺស្វាយ ជំងឺប្រមេះទឹកបាយ ជំងឺបង្កដោយមេរោគក្លាមីឌីយ៉ា ជំងឺបង្កដោយទ្រីកូម៉ូណាស់ និងជំងឺបង្កដោយផ្សិតកង់ឌីដាស់ ។

អ្នកជំងឺកាមរោគប្រមាណ ៦ នាក់ ក្នុងចំណោមអ្នកជំងឺកាមរោគ ១០ នាក់ កើតជំងឺ ២ បែបផ្សេងគ្នា ឬលើសពីនេះនៅក្នុងពេលតែមួយ ។ ដោយប្រើវិធីថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ជំងឺជាច្រើនត្រូវបានយកចិត្តទុកដាក់តាំងពីលើកដំបូង ហើយអ្នកជំងឺត្រូវទទួលនូវថ្នាំដែលមានប្រសិទ្ធិភាពបំផុត ។ វិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញាគឺជាការថែទាំព្យាបាលជំងឺកាមរោគប្រកបដោយគុណភាពខ្ពស់ ពីព្រោះវាព្យាបាលអ្នកជំងឺដែលអាចមានជំងឺកាមរោគលើសពីមួយមុខដោយប្រើថ្នាំដែលមានប្រសិទ្ធិភាពខ្ពស់បំផុតដែលអាចរកបាន ។

**ការព្យាបាលជំងឺកាមរោគដោយប្រើចង្កោមរោគសញ្ញា**

| | ចង្កោមរោគសញ្ញា | ការព្យាបាល |
|---|---|---|
| **បុរស** | ការហូរខ្ទុះតាមបង្ហូរនោម | ជំងឺប្រមេះទឹកបាយនិងជំងឺបង្កដោយក្លាមីឌីយ៉ា |
| **ស្ត្រី** | ការឈឺចុកចាប់ផ្នែកខាងក្រោមនៃពោះ | ជំងឺប្រមេះទឹកបាយ ជំងឺបង្កដោយក្លាមីឌីយ៉ា និងជំងឺបង្កដោយបាក់តេរីផ្សេងទៀត |
| | ការហូរខ្ទុះតាមទ្វារមាស | ជំងឺប្រមេះទឹកបាយ ជំងឺបង្កដោយក្លាមីឌីយ៉ា ជំងឺរលាកទ្វារមាសបង្កដោយទ្រីកូម៉ូណាស់និងផ្សិតកង់ឌីដាស់ |
| **ស្ត្រី ឬបុរស** | ដំបៅលើប្រដាប់បន្តពូជ | ជំងឺស្វាយ chancriod (chancre mou) និងជំងឺដំបៅពងពែកលើប្រដាប់បន្តពូជ (genital herpes) |

៥. **វិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជាវិធីងាយស្រួលប្រើ (user friendly) ពីព្រោះវាផ្តល់នូវការព្យាបាលដែលអ្នកជំងឺនឹងងាយទៅទទួលសេវា ។**

វិធីគ្រប់គ្រងថែទាំងជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា សង្កត់ធ្ងន់លើការព្យាបាលឱ្យបានឆាប់រហ័ស ។ វាធ្វើឱ្យសេវាកាន់តែប្រសើរឡើងផងដែរ ដើម្បីឱ្យអ្នកជំងឺទទួលបាននូវការព្យាបាលដែលមានប្រសិទ្ធិភាព ហើយនឹងរឹតតែមានផាសុខភាពក្នុងការប្រើប្រាស់សេវាម្តងទៀត ។

៦. **ការព្យាបាលជំងឺកាមរោគពេញលេញរាប់បញ្ចូលទាំងការអប់រំអ្នកជំងឺ ការជំរុញការប្រើប្រាស់ស្រោមអនាម័យ (condom promotion) និងការលើកទឹកចិត្តដៃគូរួមភេទរបស់អ្នកជំងឺកាមរោគឱ្យមកទទួលការព្យាបាល ។** ទិដ្ឋភាពទាំងនេះជានិច្ចកាលត្រូវបានបញ្ចូលជាផ្នែកនៃវិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។ ការសន្ទនារវាងបុគ្គលិកថែទាំសុខភាព និងអ្នកជំងឺកាមរោគ ជួយអ្នកជំងឺកាមរោគឱ្យទទួលការព្យាបាលជំងឺរបស់ពួក

គេឱ្យបានចប់សព្វគ្រប់។ វាក៏ជួយឱ្យអ្នកជំងឺកាមរោគសំរេចចិត្តប្រើប្រាស់ស្រោមអនាម័យ ដើម្បីផ្លាស់ប្តូរការប្រព្រឹត្តផ្លូវភេទដែលប្រឈមមុខនឹងគ្រោះថ្នាក់ និងនិយាយបញ្ចុះបញ្ចូល ដៃគូរួមភេទរបស់ពួកគេឱ្យមកទទួលការព្យាបាល ។

មធ្យោបាយល្អបំផុតដើម្បីបង្ការការចំលងនាអនាគតគឺត្រូវតមការរួមភេទ ឬ រួមភេទជាមួយ ដៃគូរួមភេទតែម្នាក់ ។ ប៉ុន្តែសំរាប់អ្នកខ្លះ ការប្រើប្រាស់ស្រោមអនាម័យជាមធ្យោបាយ ជាក់ស្តែងមួយនៃការបង្ការជំងឺកាមរោគដែលសមស្របទៅនឹងរបៀបរស់នៅរបស់ពួកគេ ។ ស្រោមអនាម័យជារបាំងការពារការចំលងជំងឺកាមរោគ ដែលមានប្រសិទ្ធិភាពក្នុងពេល រួមភេទ ។

បុគ្គលិកថែទាំសុខភាពអាចកត់សំគាល់ថាពុំសូវមានការផ្តោតទៅលើការកំណត់រកមូលហេតុ នៃជំងឺកាមរោគពិសេសណាមួយ ។ ការផ្លាស់ប្តូរនេះអាចជាការពិបាកសំរាប់បុគ្គលិកថែទាំ សុខភាពដែលបានទទួលការបណ្តុះបណ្តាលឱ្យកំណត់រកមូលហេតុនៃជំងឺកាមរោគ។ ក៏ប៉ុន្តែ ទាំងបុគ្គលិកថែទាំសុខភាព ទាំងអ្នកជំងឺកាមរោគនឹងទទួលនូវការពេញចិត្តចំពោះគុណ ភាពនៃការថែទាំនៅពេលដែលការព្យាបាលដែលមានប្រសិទ្ធិភាពត្រូវបានផ្តល់ជូនបានឆាប់ រហ័ស ។

៧. **ការផ្គត់ផ្គង់សមស្របនូវឱសថសំរាប់ព្យាបាលជំងឺកាមរោគ និងកម្មវិធីបណ្តុះបណ្តាលបុគ្គលិក ថែទាំសុខភាព មានសារៈសំខាន់ជាសារវ័ន្តសំរាប់ធ្វើឱ្យការថែទាំព្យាបាលជំងឺកាមរោគមាន លក្ខណៈល្អប្រសើរឡើង ។** ការអាចរកបានថ្នាំសំរាប់ប្រើប្រាស់ជាការចាំបាច់សំរាប់ធ្វើឱ្យ មានការព្យាបាលជំងឺកាមរោគឱ្យបានត្រឹមត្រូវ ។ ការផ្តល់ឱ្យនូវថ្នាំដែលមានប្រសិទ្ធិភាព និងក្នុងកំរិតគ្រប់គ្រាន់ជួយឱ្យបានការបង្ការនូវបញ្ហាបាត់បង់គុណភាពរបស់ថ្នាំអង់ប៊ីយ៉ូទិចក្នុង ការសំលាប់មេរោគផងដែរ ។ អ្នកជំងឺនឹងឱ្យតំលៃខ្ពស់ផងដែរដល់សេវាថែទាំណាដែល ពួកគេអាចទទួលព្យាបាលបានជាសះស្បើយបានយ៉ាងឆាប់រហ័ស ។

៨. **វិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាបង្កើតឱ្យមានជាការព្យាបាល ក្នុង លក្ខណៈស្តង់ដា ។**

៩. **ចង្កោមរោគសញ្ញាបន្ថយកំហុសនិងការកើតឡើងនូវភាពស៊ាំនៃមេរោគទៅនឹងថ្នាំអង់ទីប៊ីយោទិច។** បញ្ជីនៃថ្នាំណែនាំឱ្យប្រើប្រាស់សំរាប់ព្យាបាលជំងឺកាមរាគ គួរតែធ្វើការ កែលំអយ៉ាងទៀងទាត់ ពេលដែលមានពត៌មានថ្មីអំពីប្រសិទ្ធិភាពនៃថ្នាំអង់ទីប៊ីយោទិច និងនៅពេលមានថ្នាំអង់ទីប៊ី យោទិចថ្មីៗ សំរាប់ប្រើប្រាស់ ។

☞ **ជំហានជាក់ស្តែងនានាក្នុងការដាក់ឱ្យអនុវត្តវិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញា**

**១. ការស្វែងរកការគាំទ្រផ្នែកបច្ចេកទេសចំពោះពិធីសារព្យាបាលជាតិ**

ដំបូងត្រូវបញ្ចុះបញ្ចូលគ្រូពេទ្យគ្លីនិក ។ ការទិទៀនដែលយើងឮជាញឹកញាប់មាន :

- វិធីនេះគ្មានមូលដ្ឋានវិទ្យាសាស្ត្រត្រឹមត្រូវ
- ពុំបានបង្ហាញភស្តុតាងថាមានប្រសិទ្ធិភាពពិតប្រាកដទេ
- ពុំអាចដោះស្រាយបញ្ហាកាមរោគដែលគ្មានរោគសញ្ញាបានទេ
- ព្យាបាលដោយប្រើឱសថច្រើនហួស (overtreatment) ឬខ្ជះខ្ជាយឱសថ
- ធ្វើឱ្យបាត់បង់អំណាច និងតំលៃនៃជំនាញផ្នែកគ្លីនិក (clinical expertise)

ការទទួលបានការគាំទ្រផ្នែកបច្ចេកទេស តំរូវឱ្យយើងអនុវត្តជំហានមួយចំនួនដូចតទៅ:

- ប្រមូលទិន្នន័យដែលមាននៅក្នុងតំបន់
- រៀបចំសេចក្តីព្រាងឯកសារបច្ចេកទេស
- កំណត់រកឱ្យឃើញអ្នកមានតួនាទីសំខាន់ (key players)
- រៀបចំសិក្ខាសាលា (workshop) លើកដំបូង (ដើម្បីពិភាក្សាអំពីហេតុផលនានា កែលំអនូវពង្រាងឯកសារ ដោះស្រាយបញ្ហា និងសំរេចបាននូវការឯកភាពគ្នា) ។
- រៀបចំឯកសារចុងបញ្ចប់ និង រៀបចំសិក្ខាសាលារកការគាំទ្រ ។

## សំណួរគន្លឹះទាក់ទងនឹងការដាក់ឱ្យអនុវត្តវិធីគ្រប់គ្រងជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

- តើយើងអាចធានាថាកម្មវិធីសិក្សានៃសាលាពេទ្យនិងគិលានុបដ្ឋាក-យិកាស្របជាមួយគោលការណ៍ណែនាំ ឬពិធីសារបច្ចេកទេសជាតិបានដោយវិធីណា?
- តើត្រូវឱ្យគ្រូពេទ្យឯកជនចូលរួមអនុវត្តយ៉ាងដូចម្តេចនិងនៅពេលណា?
- តើយើងធ្វើដូចម្តេចបើការព្រមព្រៀងបច្ចេកទេសប្រឆាំងនឹងការអនុវត្តវិធីគ្រប់គ្រងដោយពឹងផ្អែកលើចង្កោមរោគសញ្ញា?

២. ការចែងជាគោលនយោបាយ និងការគាំទ្រផ្នែកនយោបាយ

សូមមើលម៉ូឌុលទី៦ អំពីផ្នែកគោលនយោបាយ និងការស្វែងរកការគាំទ្រ

ការដាក់ឱ្យអនុវត្តនូវវិធីគ្រប់គ្រងដោយពឹងផ្អែកលើចង្កោមរោគសញ្ញាត្រូវមានការចូលរួមជាចាំបាច់ពីផ្នែកសុខាភិបាល និងផ្នែកដទៃទៀតនៃរដ្ឋាភិបាល (សំរាប់ស្វែងរកការគាំទ្រផ្នែកនយោបាយ) អង្គការក្រៅរដ្ឋាភិបាល និងផ្នែកឯកជន (គ្រូពេទ្យ អ្នកផ្គត់ផ្គង់ឱសថ) ។

៣. ការបណ្តុះបណ្តាល

៤. ការអនុវត្តន៍

៥. ការចុះអភិបាល និងការវាយតំលៃ

### លំហាត់ ៥.១

ការពិភាក្សាតាមក្រុម

- សូមកំណត់រកបុគ្គល ក្រុម ឬស្ថាប័ន អ្នកត្រូវធ្វើការទាក់ទង ដើម្បីបានទទួលការគាំទ្រផ្នែកបច្ចេកទេសសំរាប់ការដាក់ឱ្យប្រើប្រាស់នូវវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។

ចូរពិពណ៌នាវិធីផ្សេងៗដែលអ្នកត្រូវយកមកប្រើ ។

សូមធ្វើដូចគ្នាដែរសំរាប់ការស្វែងរកការគាំទ្រផ្នែកនយោបាយ ។

## ម៉ូឌុលទី ៦

# គោលនយោបាយ ការស្វែងរកការគាំទ្រ
# និងគោលការណ៍ណែនាំ
# សំរាប់សេវាថែទាំ

## ៦.១ ‿ គោលនយោបាយ

នៅស្ទើរតែគ្រប់ប្រទេសទាំងអស់មានប្រជាជនកំពុងកើតជំងឺកាមរោគកាន់តែច្រើនឡើងៗ ។ ប៉ុន្តែរហូតដល់ពេលនេះមានតែប្រទេសមួយចំនួនតូចប៉ុណ្ណោះ ដែលមានគោលនយោបាយសមស្របស្តីពីការបង្ការ និងព្យាបាលជំងឺកាមរោគ ។

មានតំរូវការបន្ទាន់នូវគោលនយោបាយដែលនាំទៅរក :

- ការកើនឡើងនូវមនសិការយល់ដឹង និងចំណេះដឹងអំពីការបង្ការជំងឺកាមរោគ
- ការស្វែងរកការព្យាបាលប្រសិនបើអ្នកជំងឺទាំងនោះគិតថា ខ្លួនគេមានជំងឺកាមរោគ
- ការផ្តល់សេវាថែទាំជំងឺដ៏ល្អប្រសើរសំរាប់អ្នកជំងឺកាមរោគ ។

មុនពេលពិនិត្យលើគោលនយោបាយស្តីពីជំងឺកាមរោគ ជាដំបូងសូមយើងលើកយកមកពិនិត្យអំពីវិធីនានា ដែលសង្គមមនុស្សជាច្រើនជ្រើសរើសយកដើម្បីជួយក្នុងការបង្ការ និងថែទាំជំងឺកាមរោគ ។

### ៦.១.១ ‿ វិធីនានាសំរាប់ការទប់ស្កាត់ជំងឺកាមរោគ

មធ្យោបាយដែលជាទំលាប់ធ្វើពីមុនមកក្នុងការទប់ស្កាត់នូវរាល់ជំងឺឆ្លងនានា គឺដំបូងត្រូវធ្វើតេស្តស្រាវជ្រាវរកជំងឺទាំងនោះ ព្យាបាលមនុស្សណាដែលឆ្លងជំងឺ (ជួនកាលដាក់អ្នកជំងឺឱ្យនៅដាច់ដោយឡែក) និងបន្ទាប់មកតាមដានស្វែងរក និងធ្វើតេស្តស្រាវជ្រាវរកជំងឺលើអ្នកដែលបានប៉ះពាល់ជាមួយជំងឺ ។

មានប្រទេសមួយចំនួនបានជ្រើសរើសយកនូវវិធីបែបនោះ ដើម្បីប្រយុទ្ធនឹងជំងឺកាមរោគនិងមេរោគអេដស៍ ។ ប្រទេសទាំងនេះមានច្បាប់ និងបទបញ្ញានានាដែលតំរូវឱ្យអ្នកជំងឺកាមរោគផ្តល់នូវឈ្មោះរបស់ខ្លួន និងរបស់ដៃគូដែលអ្នកជំងឺនោះបានទាក់ទងបន្ទាប់ពីមានជំងឺមក ។

នៅក្នុងប្រទេសខ្លះទៀត បានអនុម័តបង្កើតច្បាប់ ដោយស្នើសុំឱ្យអ្នកណាដែលត្រូវសង្ស័យថាមានជំងឺកាមរោគ ទទួលពិនិត្យជំងឺ និងធ្វើតេស្តស្រាវជ្រាវរកជំងឺកាមរោគ និងមេរោគអេដស៍ ហើយប្រសិនបើត្រូវបានរកឃើញថា បានឆ្លងជំងឺហើយនោះ ត្រូវទទួលការព្យាបាល និងពិនិត្យតាមដានបន្ត ។

បញ្ហាជាច្រើនដែលកើតមានដោយសារការអនុវត្តន៍វិធីបែបនេះ គឺជាញឹកញាប់វាតែងតែធ្វើអោយអ្នកដែលមានជំងឺលាក់ខ្លួន និងមិនទៅទទួលនូវការព្យាបាលសមស្របទេ ពីព្រោះពួកគេមិនចង់បង្ហាញខ្លួនឱ្យគេស្គាល់ និងភ័យខ្លាចចំពោះការត្រូវផាកពិន័យ ។

វិធីទំនើបថ្មីក្នុងការបង្ការ និងទប់ស្កាត់ជំងឺកាមរោគ (និងជាទូទៅចំពោះជំងឺឆ្លងនានា ភាគច្រើន) គឺត្រូវលើកទឹកចិត្តអ្នកទាំងឡាយណាដែលគិតថា ខ្លួនអាចកើតជំងឺ ឱ្យស្វែងរកការផ្តល់យោបល់និងការព្យាបាលជំងឺ និងផ្តល់ជូនអ្នកទាំងនោះវិញនូវការព្យាបាលដែលមានប្រសិទ្ធិភាព មានតំលៃសមរម្យ ហើយគ្មានការរើសអើង ។

តាមរយៈការផ្សព្វផ្សាយផ្តល់ពត៌មាន និងការអប់រំដល់សាធារណៈជនទូទៅ និងការដែលសំខាន់បំផុតនោះ គឺត្រូវអប់រំនិងបណ្តុះបណ្តាលបុគ្គលិកថែទាំសុខភាពដើម្បីធ្វើឱ្យអ្នកទាំងនោះគិតថាជំងឺកាមរោគ គឺជាជំងឺមួយដូចគ្នាទៅនឹងជំងឺផ្សេងៗទៀតដែរ ។

ការមាក់ងាយ និងភាពអៀនខ្មាសនៅពេលកើតជំងឺកាមរោគត្រូវបានកាត់បន្ថយ ហើយមនុស្សដែលប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគកាន់តែមានលទ្ធភាពច្រើនក្នុងការទទួលយកសេវាថែទាំ និងកម្មវិធីបង្ការជំងឺ ។

## ៦.១.២ ~ តើអ្វីទៅជាគោលនយោបាយ ?

គោលនយោបាយ គឺជាឯកសារគោលដែលនាំផ្លូវទៅដល់ការសំរេចចិត្តនៅក្នុង អង្គការ ឬរដ្ឋាភិបាលណាមួយ ។

ពាក្យថា គោលនយោបាយ គឺរួមបញ្ចូលនូវបែបផែនផ្សេងៗ នៃមធ្យោបាយអនុវត្តន៍ច្បាប់ និងការគ្រប់គ្រងរដ្ឋបាល ។ ជួនកាលមធ្យោបាយទាំងនេះចង់និយាយសំដៅទៅលើច្បាប់ស្តីអំពីសុខភាព " ឬ " និតិបញ្ញត្តិផ្នែកសុខភាពសាធារណៈ និង វិធានការណ៍ទាំងឡាយដែលទាក់ទងនឹងបញ្ញាត្តិនេះ " ។

គោលនយោបាយអាចមានទំរង់ច្រើនយ៉ាង ។ យោលទៅតាមតំបន់ ទំរង់ទាំងនោះអាចជាមធ្យោបាយសំរាប់អនុវត្តន៍ ដូចជា និតិបញ្ញតិ (Legislation), ច្បាប់, បញ្ញតិ, បទបញ្ជា, ក្រិត្យ, សេចក្តីសំរេច, សារលិខិត, កំណត់សំគាល់, កំណត់ហេតុ, បទបញ្ជា, គោលនយោបាយ, អនុសាសន៍, សារាចរ, ដំណោះស្រាយ, អនុស្សរណៈ, វិន័យ និងគោលការណ៍ណែនាំ ។

| ពាក្យ | និយមន័យ | បង្កើតឡើងដោយ |
|---|---|---|
| • គោលនយោបាយ (សុខភាព) សាធារណៈ policy | • បង្កើតឡើងនូវគោលបំនង យុទ្ធសាស្ត្រ ឬ បែបបទក្នុងការប្រតិបត្តិការងារនៃក្រសួងនានារបស់រដ្ឋាភិបាល | • ថ្នាក់ណាមួយនៅក្នុងជួររដ្ឋាភិបាលអាចបង្កើតឡើងនូវគោលនយោបាយដែលសមស្របជាមួយនឹងអំណាចគ្រប់គ្រងរបស់ខ្លួន |
| • ច្បាប់ (Law) | • សំរាប់ជាមធ្យោបាយអនុវត្តត្រឹមត្រូវតាមច្បាប់ (ឧទាហរណ៍ : ក្រមច្បាប់រឿងក្តី ឬ "ច្បាប់ដែលឥតមានជាលាយលក្សអក្សរ ") (common law) | • ត្រូវបានបង្កើតឡើងជាទូទៅដោយថ្នាក់ដឹកនាំកំពូលរបស់រដ្ឋ ឬអង្គនិតិបញ្ញតិនានា ។ |
| • បទបញ្ជា (regulation) | • ជាមធ្យោបាយអនុវត្តតាមផ្លូវច្បាប់ ឬ រដ្ឋបាលដែលមិនមានអនុភាពដូចច្បាប់ | • ត្រូវបានបង្កើតឡើងជាទូទៅដោយក្រសួង ឬ ស្ថាប័នបច្ចេកទេសរបស់រដ្ឋាភិបាលនានា (ឧទាហរណ៍ : ក្រសួងសុខាភិបាល) |
| • គោលការណ៍ណែនាំបច្ចេកទេស (guideline) | • និតិវិធីប្រតិបត្តិត្រូវបានប្រើប្រាស់នៅក្នុងស្ថាប័ន ឬ កម្មវិធីនានារបស់រដ្ឋាភិបាល វាអាចមានលក្ខណៈបង្ខិតបង្ខំ ឬ ការស្ម័គ្រចិត្ត | • កម្មវិធី ឬ ស្ថាប័នផ្នែកបច្ចេកទេសនានា |

តាមធម្មតា គឺថ្នាក់ផ្សេងៗរបស់រដ្ឋាភិបាលជាអ្នកទទួលខុសត្រូវសំរាប់ការបង្កើត និងអនុវត្តគោលនយោបាយសាធារណៈទាំងអស់នោះ ។

⇨ **គោលការណ៍ជាមូលដ្ឋានស្តីអំពីគោលនយោបាយសាធារណៈ**

ច្បាប់ និងបទបញ្ញាទាំងឡាយត្រូវបានរក្សាទុកដោយគ្មានការផ្លាស់ប្តូរនៅក្នុងឯកសារទាំងអស់ជាលាយលក្សអក្សរដែលត្រូវបានរៀបចំឡើង (ឧទាហរណ៍ : ក្រមច្បាប់) យោលទៅតាមទំលាប់របស់រដ្ឋាភិបាលនានា ។ ក៏ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ នៅក្នុងកម្មវិធីនានាដែលទាក់ទងនឹងបច្ចេកទេស តែងមានញឹកញយនូវការរំពឹងទុកជាមុន ឬ បែបបទធ្វើការងារនានា ដែលមិនបានសរសេរនៅក្នុងឯកសារ តែត្រូវបានផ្សព្វផ្សាយតាមរយៈបទពិសោធន៍ ឬ ទំនាក់ទំនងក្រៅផ្លូវការនានា ។ វិធានការណ៍ខ្លះនៃទិដ្ឋភាពក្រៅផ្លូវការនេះត្រូវបានគេរំពឹងទុកថានឹងកើតមានឡើងនៅក្នុងកម្មវិធីណាមួយ ។

ការសំខាន់បំផុត គឺអ្នកគ្រប់គ្រងកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគទាំងអស់ត្រូវបែងចែកឱ្យបានច្បាស់លាស់រវាងបែបបទអនុវត្តការងារមិនផ្លូវការ និងគោលនយោបាយ ។

❖ **គោលការណ៍សំខាន់ៗ ទាំង ៦ របស់គោលនយោបាយសាធារណៈ**

មធ្យោបាយអនុវត្តគោលនយោបាយសាធារណៈ (Public policy instruments) ត្រូវពិនិត្យពិចារណាអំពីបរិបទសង្គម ប្រពៃណីទំនៀមទំលាប់ ក្រមសីលធម៌ និងបែបគ្រប់គ្រង ដែលឯកសារនេះត្រូវរៀបរៀងឡើង និងយកមកអនុវត្ត ។

**១ - <u>សមភាព</u> (Equity) :**

គេមិនអាចអនុវត្តគោលនយោបាយចំពោះប្រជាជនខ្លះ ហើយមិនអនុវត្តចំពោះអ្នកដទៃទៀតតាមអំពើចិត្តបានទេ ។ នៅទីកន្លែងណាដែលមានការចាត់ទុកប្រជាជនមួយចំនួនខុសប្លែកពីអ្នកដទៃទៀតនោះ គោលនយោបាយនោះត្រូវតែចែងអោយបានច្បាស់លាស់អំពីភាពខុសប្លែកពីគ្នានេះ និងមានភាពសមហេតុផលត្រឹមត្រូវយកជាការបាន ។

**២ - <u>សារៈសំខាន់ (ឬភាពទាក់ទងគ្នា)</u>** (important / relevance) :

គោលនយោបាយមួយគួរតែឆ្លើយតបទៅនឹងបញ្ហានានាដែលមានសារៈសំខាន់សមល្មមគ្រប់គ្រាន់នឹងសរសេរជាគោលការណ៍នយោបាយជាលាយលក្សអក្សរមួយបាន ។

បញ្ហានៃការគ្រប់គ្រងរដ្ឋបាលតូចតាចមួយចំនួនមិនសក្តិសមក្នុងការបង្កើត និងការផ្សព្វផ្សាយ គោលនយោបាយជាផ្លូវការឡើយ ។

**៣ - ប្រសិទ្ធិភាព** (effectiveness) :

ដើម្បីជឿជាក់ថា គោលនយោបាយមួយនឹងមានប្រសិទ្ធិភាព ឬ មានសារៈប្រយោជន៍ក្នុងការដោះស្រាយបញ្ហានោះ គេត្រូវសំអាងទៅលើហេតុផលត្រឹមត្រូវណាមួយ ។ វាត្រូវតែមាននូវឱកាសប្រាកដប្រជាមួយដែលអាចសំរេចបាននូវផលប្រយោជន៍ជាក់ស្តែង ។

**៤ - តុល្យភាព (ឬភាពមានសមាមាត្រ)** (balance / proportion) :

ត្រូវធ្វើឱ្យមានតុល្យភាពមួយចំនួនរវាងលទ្ធផលល្អដែលគោលនយោបាយអាចសំរេចបាននិងភាពលំបាក ឬ ឧបសគ្គនៃការអនុវត្តនូវគោលនយោបាយនេះ ។

**៥ - លទ្ធភាពផ្នែកបច្ចេកទេស** (Technical feasibility) :

គោលនយោបាយសាធារណៈត្រូវតែជាគោលនយោបាយដែលអាចមានលទ្ធភាពអនុវត្តបាននៅក្នុងបរិបទជាក់ស្តែងដោយលើកយកមកពិចារណាអំពីឧបសគ្គផ្នែកសេដ្ឋកិច្ច និងកំរិតបច្ចេកទេសដែលបានជួបប្រទះនៅក្នុងក្របខ័ណ្ឌពិសេសមួយ ។

**៦ - ភាពដែលសង្គមយល់ព្រមទទួលយកបាន** (social acceptability) :

គោលនយោបាយដែលមានប្រយោជន៍ គឺត្រូវទទួលបានការយល់ព្រមពីសហគមន៍នានាទាំងផ្នែកសង្គម និងប្រពៃណីទំនាមទំលាប់ដែលជាទីកន្លែងដែលគោលនយោបាយនោះត្រូវយកទៅអនុវត្ត ។

### ៦.១.៣ - ការបង្កើតគោលនយោបាយស្តីអំពីសេវាថែទាំកាមរោគ

ការពិនិត្យពិចារណានៅលើវិធីទប់ស្កាត់ជំងឺកាមរោគនៅក្នុងប្រទេស ឬ តំបន់របស់អ្នក គឺមានសារៈសំខាន់ណាស់ នៅពេលដែលមានការព្យាយាមបង្កើតឡើងនូវគោលនយោបាយអំពីសេវាថែទាំជំងឺកាមរោគនានា ។

តើមានច្បាប់ និងបទបញ្ញាដែលធ្វើឱ្យប្រជាជនអស់ទឹកចិត្តក្នុងការទទួលការព្យាបាល ឬការទិញស្រោមអនាម័យប្រើប្រាស់ដែរឬទេ ?

តើបទបញ្ញាទាំងនោះបានលើកទឹកចិត្តដល់ការលាក់ការសំងាត់ជូនអ្នកជំងឺឬទេ ?

ឧទាហរណ៍ដូចជា ៖

- តើឈ្មោះរបស់អ្នកជំងឺកាមរោគត្រូវបានរាយការណ៍ទៅឱ្យអាជ្ញាធរមានសមត្ថកិច្ចឬទេ ?
- តើមានការចេញបទបញ្ញាហាមប្រាមដល់ការផ្សាយពាណិជ្ជកម្មស្រោមអនាម័យឬទេ ?

ប្រសិនបើមានច្បាប់ ឬបទបញ្ញាបែបនេះ នោះភារកិច្ចមួយក្នុងចំណោមភារកិច្ចដ៏ច្រើនរបស់អ្នក គឺព្យាយាមធ្វើឱ្យអាជ្ញាធរ ឬ រដ្ឋអំណាចកែប្រែ ឬ ផ្លាស់ប្តូរច្បាប់ ឬបទបញ្ញាទាំងនោះ ដើម្បីធានាឱ្យប្រជាជននឹងមានឆន្ទៈស្វែងរកការព្យាបាលជំងឺបែបវេជ្ជសាស្ត្រ និងយល់ដឹងអំពីការប្រើប្រាស់ស្រោមអនាម័យព្រមទាំងទីកន្លែងដែលអាចរកទិញវាបាន ។

នៅក្នុងកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ វាមានសារសំខាន់ជាពិសេសផងដែរទៅលើការបែងចែកឱ្យបានច្បាស់លាស់រវាងបញ្ហាទាំងឡាយដែលអាចត្រូវដោះស្រាយបានដោយការកែសំរួលគោលនយោបាយ និងបញ្ហាផ្សេងៗទៀតដែលមិនអាចនឹងដោះស្រាយបានសោះ ។

❖ **តើមានគោលនយោបាយអ្វីខ្លះដែលមានសារៈសំខាន់ចាំបាច់ដើម្បីគាំទ្រដល់ការថែទាំអ្នកជំងឺកាមរោគ?**

មានវិស័យបីនៃកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ គឺ ការបង្ការ - ការជូនដំណឹង និងការព្យាបាល អ្នកបង្កើតគោលនយោបាយត្រូវប្រឈមមុខនឹងសំនួរយ៉ាងច្រើន ។ វាក៏មានបញ្ហាទាក់ទងនឹងច្បាប់ទូទៅផងដែរ ដែលអាចប៉ះពាល់ដល់កម្មវិធីទាំងនេះផងដែរ ។

**១ ៖ ការបង្ការការចំលងជំងឺកាមរោគ**

១.១ - ការចុះក្នុងបញ្ជីនូវគ្រឹះស្ថាន ឬ បុគ្គលដែលត្រូវបានគេយល់ថា ជាអ្នកដើរតួក្នុងការបង្ការការចំលងជំងឺកាមរោគ ៖

**បញ្ហាដែលត្រូវចោទសួរចំពោះការចុះបញ្ជី**

❖ តើគួរចុះទៅក្នុងបញ្ជីនូវឈ្មោះរបស់អ្នកណា ឬកន្លែងអ្វីខ្លះ (ជាបុគ្គលម្នាក់ៗ ឬ ជាគ្រឹះស្ថាននានា) ?

- ផ្ទះបន
- រង្គសាល ឬ មណ្ឌលកំសាន្តដែលអ្នករកស៊ីផ្លូវភេទទៅញឹកញាប់
- អ្នកប្រកបរបរជួញដូរផ្លូវភេទ (យកតែភេទស្រីប៉ុណ្ណោះ ? យកតែភេទប្រុសប៉ុណ្ណោះ ? ឬទាំងពីរភេទ ?)

- អ្នកបំរើការក្នុងជំនួញផ្នែកបដិសណ្ឋារកិច្ច និងទទួលភ្ញៀវមកកំសាន្ត ? (Hospitality industries)
- អ្នកដទៃទៀត ?
- តើរក្សាទុកបញ្ជីចុះឈ្មោះទាំងនោះនៅទីណា ?
- តើមានវិន័យ និង ខសន្យាអ្វីដើម្បីរក្សាឱ្យបាននូវការសំងាត់នៃបញ្ជីឈ្មោះទាំងអស់នោះ ?
- តើមានការទទួលខុសត្រូវអ្វីខ្លះសំរាប់ការចុះឈ្មោះបុគ្គល ឬគ្រឹះស្ថានទាំងនោះនៅក្នុងបញ្ជី ?
- តើត្រូវធ្វើការស្រាវជ្រាវរកជំងឺលើអ្នកទាំងនោះប៉ុន្មានដង ?
- តើស្ថាប័នណាដែលត្រូវធ្វើការស្រាវជ្រាវរក និង/ឬ ព្យាបាលជំងឺ ?
- តើការអនុវត្តទៅតាមគោលនយោបាយនៃការចុះបញ្ជីទាំងនោះត្រូវបានត្រួតពិនិត្យ តាមដាន និង ពង្រឹងតាមរបៀបណា ?

១.២ - ការធ្វើតេស្តស្រាវជ្រាវជំងឺលើក្រុមមនុស្សដែលត្រូវគេយល់ថា ជាអ្នកប្រឈមមុខខ្លាំងនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគ

**បញ្ហាដែលត្រូវចោទសួរចំពោះការធ្វើតេស្តស្រាវជ្រាវរកជំងឺ**

❖ តើត្រូវធ្វើតេស្តស្រាវជ្រាវរកជំងឺលើមនុស្សប្រភេទណាខ្លះ ?

- អ្នកជួញដូរផ្លូវភេទ
- ជនពនេចរ (អ្នកផ្លាស់ប្តូរពីទីកន្លែងមួយទៅទីកន្លែងមួយ) - អ្នកធ្វើការទៅតាមរដូវ
- ជនអន្តោប្រវេសន៍
- ស្ត្រីមានផ្ទៃពោះ
- ជនរងគ្រោះដោយឧក្រិដ្ឋកម្មផ្លូវភេទ (ការចាប់រំលោភ ការរួមភេទជាមួយនឹងសាច់សារលោហិតឯង)
- អ្នកសុំច្បាប់រៀបអាពាហ៍ពិពាហ៍
- អ្នកទេសចរណ៍ជាតិដែលបានវិលត្រឡប់មកពីបរទេស
- និស្សិតសកលវិទ្យាល័យ (អ្នកសុំចុះឈ្មោះចូលរៀន ឬ អ្នកដែលត្រឡប់មកពីសិក្សាវិញ)
- អ្នកដែលមានដៃគូរួមភេទដូចគ្នា
- ឧក្រិដ្ឋជនដែលជាប់ក្នុងពន្ធនាគារ ឬ ត្រូវជាប់ពន្ធនាគារ
- និយោជិកធ្វើការនៅក្នុងឧស្សាហកម្មឯកទេស (អ្នកធ្វើការក្នុងរោងចក្រផលិតស្បៀងកងទ័ព, អ្នកធ្វើការនៅលើនាវាសមុទ្រ)

- អ្នកដែលទើបនឹងជ្រើសរើសចូលបំរើកងទ័ពថ្មីៗ, អ្នកដែលបានចូលបំរើកងទ័ព
- ការទាក់ទងផ្លូវភេទជាមួយមនុស្សដែលបានវិនិច្ឆ័យថា មានកើតជំងឺកាមរោគ
- យុវជន ឬ យុវនារីដែលត្រូវរំលោភផ្លូវភេទ

❖ តើធ្វើតេស្តស្រាវជ្រាវរកជំងឺនោះធ្វើដោយស្ម័គ្រចិត្ត ឬ ដោយគ្មានការស្ម័គ្រចិត្ត ?

❖ តើត្រូវយកលទ្ធផលនៃការធ្វើតេស្តស្រាវជ្រាវមកប្រើក្នុងបំណងអ្វីខ្លះ ?

- រាយការណ៍ជូនទៅអាជ្ញាធរផ្សេងៗទៀត
- បញ្ជូនដើម្បីស្វែងរកការធ្វើរោគវិនិច្ឆ័យ និង/ឬ ការថែទាំព្យាបាល

## ១.៣ - ការពង្រឹងកម្មវិធីអប់រំផ្នែកផ្លូវភេទ

**បញ្ហាដែលត្រូវចោទសួរចំពោះការអប់រំផ្នែកផ្លូវភេទ**

- តើខ្លឹមសារនៃកម្មវិធីទាំងនោះមានអ្វីខ្លះ ? (ឧទាហរណ៍ : អាយុដែលត្រូវប្រាប់ឱ្យដឹងអំពីបញ្ហាផ្សេងៗ)
- តើប្រធានបទពិសេសណាខ្លះដែលអាចត្រូវលើកយកមកបង្ហាញ ឬ មិនអាចលើកយកមកបង្ហាញប្រាប់ដល់យុវជន យុវនារី ? (ឧទាហរណ៍ : ការរំលូតកូន, ការបង្ហាញ ពីរបៀបប្រើស្រោមអនាម័យ)
- តើបុគ្គលិកសុខាភិបាលត្រូវការនូវការបណ្តុះបណ្តាលដែរឬទេ ដើម្បីអាចធ្វើការជាមួយយុវជន យុវនារី ដែលស្ថិតនៅក្នុងវ័យសិក្សាបាន ?

## ១.៤ - ការអប់រំជាសាធារណៈ និងការលើកកំពស់កម្មវិធី

**បញ្ហាដែលត្រូវចោទសួរចំពោះការអប់រំជាសាធារណៈ**

- តើអ្វីដែលអាចទទួលយល់ព្រមដើម្បីបង្ហាញ ឬ ពិភាក្សាជាសាធារណៈដោយគ្មានការវិនិច្ឆ័យ ?
- តើត្រូវផ្តោតទៅលើក្រុមនៃអាយុ និង/ឬ ក្រុមមនុស្សណាខ្លះ ?

## ២ ៊ ការជូនដំណឹងអំពីជំងឺកាមរោគ

២.១ - ជំងឺកាមរោគ គឺជាជំងឺដែលអាចរាយការណ៍បាន :

**បញ្ហាដែលត្រូវចោទសួរចំពោះការរាយការណ៍**

- តើត្រូវរាយការណ៍អំពីជំងឺកាមរោគណាខ្លះ ?
- តើអ្នកណាដែលគួរត្រូវប្រាប់ឱ្យដឹង និងឆ្លងកាត់តាមរយៈមធ្យោបាយណាខ្លះ ?
- តើត្រូវស្រង់យកឯកសារ និងពត៌មានអ្វីខ្លះដាក់ក្នុងការជូនដំណឹងនេះ ?
- តើភាពជាក់លាក់នៃការធ្វើរោគវិនិច្ឆ័យក្នុងករិតណាដែលទាមទារអោយមានក្នុងការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ ?
- តើត្រូវយកការជូនដំណឹងនេះមកប្រើប្រាស់ក្នុងបំណងអ្វីខ្លះ ?
  - ការវិភាគស្ថិតិ (សំរាប់របាយការណ៍អនាមិក)
  - ការតាមដានរកដៃគូរួមភេទ (contact tracing) (សំរាប់របាយការណ៍ដែលមានប្រាប់ឈ្មោះ)
- តើត្រូវលាក់ការសំងាត់ក្នុងកំរិតណាសំរាប់ការជូនដំណឹងនេះ ?
  - តើវាមានលក្ខណៈអនាមិកឬទេ ?
  - តើដៃគូត្រូវបានដឹងបញ្ជាក់ដោយឈ្មោះ ហើយក្រោយពីនោះមកជួបប្រាស្រ័យទាក់ទងផ្ទាល់ឬទេ ?
  - តើឪពុកម្តាយនៃអ្នកជំងឺដែលមានអាយុមិនទាន់ពេញច្បាប់ត្រូវបានជួបប្រាស្រ័យទាក់ទង និងប្រាប់ឱ្យដឹងដែរ ?
  - តើមានកាលៈទេសៈណាខ្លះដែលការលាក់ការសំងាត់របស់អ្នកជំងឺទាំងនោះត្រូវបានបដិសេធចោលឬទេ ? (ឧទាហរណ៍ : ការឆ្លងជំងឺកាមរោគលើជនដែលរំលោភបំពាន ឬ ចាប់រំលោភផ្លូវភេទលើកុមារ ។)

## ៣ ៊ ការព្យាបាល និងការបង្ការជំងឺកាមរោគ

៣.១ - បទបញ្ញាដែលចែងអំពីថ្នាំព្យាបាលជំងឺកាមរោគ :

**បញ្ហាដែលត្រូវចោទសួរចំពោះឱសថ**

- តើឱសថប្រភេទណាខ្លះដែលកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគត្រូវការចាំបាច់សំរាប់ការព្យាបាល?
- តើគុណភាព និងសុវត្ថិភាពរបស់ឱសថកាមរោគទាំងនោះត្រូវបានធានា និងត្រួតពិនិត្យយ៉ាងដូចម្តេច ?

- តើត្រូវកំណត់ស្តង់ដាណាខ្លះនៅក្នុងកិច្ចសន្យានៃការទិញនេះ ?
- តើគំរោងផ្គត់ផ្គង់អ្វីដែលត្រូវផ្តល់ជូនសំរាប់ការតាមដានពិនិត្យមើលក្រោយពីការទិញ ?

- តើថ្លៃថ្នាំទាំងនេះត្រូវបានផ្គត់ផ្គង់ដោយរដ្ឋាភិបាល ឬមានការជួយចេញថ្លៃពីអ្នកជំងឺ ឬគំរោងធានារ៉ាប់រងផ្សេងៗទៀត ?

## ៣.២- តួនាទីការពង្រីកបុគ្គលិកសុខាភិបាលក្នុងការថែទាំជំងឺកាមរោគ :

**បញ្ហាដែលត្រូវចោទសួរចំពោះតួនាទីរបស់បុគ្គលិកសុខាភិបាល**

- តើបុគ្គលិកសុខាភិបាលប្រភេទណាដែលអាចត្រូវបានអនុញ្ញាតិឱ្យធ្វើរោគវិនិច្ឆ័យ និងព្យាបាលជំងឺកាមរោគ ?
- តើមានអាជ្ញាធរពិសេសថ្មីណាខ្លះដែលបានទទួលការអនុញ្ញាតិ ?
- តើមានតំរូវការណាខ្លះក្នុងការធ្វើការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិក ?
- តើមានការចេញលិខិតអនុញ្ញាតិ ឬ ឯកសារបន្ថែមណាដែលផ្តល់ដល់អ្នកដែលត្រូវច្បាប់អនុញ្ញាតិឱ្យបំពេញមុខងារបន្ថែមឬទេ ?
- តើបុគ្គលិកត្រូវការនូវការអភិបាលការងារបន្ថែមក្នុងករិតណា ?

## ៣.៣- ការធ្វើឱ្យកាន់តែប្រសើរឡើងនូវសេវាថែទាំកាមរោគដែលប្រកបដោយប្រសិទ្ធិភាពពេញលេញ :

**បញ្ហាដែលត្រូវចោទសួរចំពោះប្រសិទ្ធិភាពពេញលេញ** (cost-effectiveness)

- តើកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគជាតិ ឬ ខេត្តត្រូវអនុម័តយកលក្ខណៈសម្បត្តិ និងសមាសភាគជាក់លាក់ណាខ្លះសំរាប់នៃវិធីគ្រប់គ្រង និងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ?
- តើមានការធានាឱ្យបាននូវការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលអំពីវិធីរបៀបនេះដែរឬទេ ?
- តើការប្រើប្រាស់វិធីគ្រប់គ្រង និងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញានឹងត្រូវអនុវត្តដាច់ខាតនៅក្នុងគ្រប់កាលៈទេសៈទាំងអស់ ឬ ក៏បុគ្គលិកដែលព្យាបាលអ្នកជំងឺកាមរោគអាចនឹងត្រូវអនុញ្ញាតិឱ្យមានការបត់បែនសមស្របទៅនឹងករណីជំងឺពិសេសៗខ្លះបាន?

## ៤ ~ បញ្ហានៃច្បាប់ពិសេសៗ

## ៤.១- យុវជន និងជំងឺកាមរោគ :

**បញ្ហាដែលត្រូវចោទសួរអំពីយុវជន**

- តើយុវជនដែលមានអាយុចាប់ពីប៉ុន្មានឆ្នាំទៅទើបអាចស្វែងរក និងទទួលនូវសេវាថែទាំជំងឺកាមរោគដែលអាចរក្សាការសំងាត់បាន ?
- តើយុវជនយល់ព្រមទៅទទួលការពិនិត្យព្យាបាលនៅសេវាថែទាំជំងឺកាមរោគណាខ្លះ ?
  - តើមានសេវាណាខ្លះដែលយុវជនទាំងនោះមិនព្រមទៅទទួលការពិនិត្យព្យាបាល ?
  - តើត្រូវប្រាប់ឪពុកម្តាយរបស់យុវជនទាំងនោះក្នុងស្ថានភាពណាខ្លះ ?
  - តើស្ថាប័ននៃរដ្ឋាភិបាលណាខ្លះដែលសមត្ថកិច្ចនៅក្នុងវិស័យនេះ ឬដែលយើងគួរតែទៅពិគ្រោះយោបល់មុនពេលរៀបចំបង្កើតគោលនយោបាយ ?

## ៤.២- ការផ្តន្ទាទោស

**បញ្ហាដែលត្រូវចោទសួរចំពោះការផ្តន្ទាទោស**

- តើគួរបង្កើតឱ្យមានការផ្តន្ទាទោសតាមផ្លូវច្បាប់សំរាប់ជនណាដែលបានចំលងជំងឺកាមរោគដល់ អ្នកដទៃដោយចេតនាដែរឬទេ ?
- តើត្រូវរកភ័ស្តុតាងបញ្ជាក់ថា គេត្រូវបានឆ្លងជំងឺកាមរោគដែរឬទេ ? តើការបង្ហាញថានរណាម្នាក់ប្រឈមមុខនឹងគ្រោះថ្នាក់នៃការឆ្លងជំងឺកាមរោគដោយអ្នកម្នាក់ផ្សេងទៀតជាការគ្រប់គ្រាន់ដែរឬទេ ?
- តើបុគ្គលិកសុខាភិបាលត្រូវបានតំរូវឱ្យរាយការណ៍ពីឥរិយាបថប្រព្រឹត្តបែបនេះឬទេ ?

❖ **តើអ្នកណាខ្លះគួរជាអ្នកបង្កើតគោលនយោបាយស្ដីអំពីសេវាថែទាំជំងឺកាមរោគ ?**

អ្នកគួរតែគិតពិចារណាទៅដល់ការចូលរួមពីគ្រប់បណ្ដាផ្នែកសុខាភិបាលនៃតំបន់ផ្សេងៗដើម្បីជួយក្នុងការបង្កើតនូវគោលនយោបាយដែលអធិប្បាយប្រាប់ថាវិធីសហការក្នុងការផ្ដល់នូវសេវាថែទាំជំងឺកាមរោគដែលបានធ្វើសមាហរណកម្ម ហើយ (integrated STD service) ។ លុះណាតែពួកគេត្រូវបានចូលរួមផ្ទាល់តែម្ដងចាប់តាំងពីដើមដំបូង ទើបគេមានអារម្មណ៍ថា ពួកគេគឺជាផ្នែកនៃកម្មវិធីដ៏សំខាន់នេះ ហើយចាត់ទុកថា ការអនុវត្តកម្មវិធីជាការងាររបស់ពួកគេ ។

អ្នកដែលត្រូវបានអញ្ជើញមកចូលរួមដើម្បីបង្កើតគោលនយោបាយ គួរតែជាមន្ត្រីថ្នាក់ខ្ពស់ដែលមានបទពិសោធន៍ច្រើន និងជាអ្នកដែលស្ថិតក្នុងតំណែងមួយដែលអាចយល់ព្រមសំរេចអោយតំបន់គ្រប់គ្រងរបស់ពួកគេទទួលយកនូវការងារថ្មី និងរបៀបធ្វើការងារថ្មី ។

**លំហាត់ ៦.១**

**ការពិភាក្សាតាមក្រុម :**

សូមពិភាក្សាអំពីគោលនយោបាយមួយស្ដីពីជំងឺកាមរោគដែលអ្នកដឹងថា កំពុងចូលជាធរមាននៅក្នុងប្រទេសរបស់អ្នក ។ សូមជ្រើសរើសយកគោលនយោបាយណាមួយដែលអ្នកយល់ថាសក្ដិសមក្នុងការយកមកពិចារណា ។

ចូរពន្យល់ថា ហេតុអ្វីបានជាគោលនយោបាយថ្មីនេះមានសារៈប្រយោជន៍ ។

ចូរពិភាក្សាថា តើអ្នកណាដែលអ្នកគិតថានឹងត្រូវបានអញ្ជើញឱ្យមកចូលរួមដើម្បីបង្កើតជាគោលនយោបាយនេះ ហើយតើអ្នកទាំងនោះត្រូវចូលរួមជាមួយអ្នកនេះយ៉ាងដូចម្ដេច ?

សរសេរចំលើយរបស់អ្នកនៅលើក្រដាសថ្លា ។

## ៦.២ ‐ ការស្វែងរកគាំទ្រ និងយុទ្ធសាស្ត្រស្វែងរកការគាំទ្រ

ក្រោយពីបានសំរេចចិត្តថាត្រូវរៀបចំបង្កើតគោលនយោបាយអ្វីដើម្បីធានាអោយកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគរបស់អ្នកកាន់តែល្អប្រសើរឡើងហើយ អ្នកចាំបាច់ត្រូវបញ្ចុះបញ្ចូលបុគ្គលិកសុខាភិបាលនិងរដ្ឋអំណាចផ្សេងៗ ទៀតនៅក្នុងសង្គមរបស់រដ្ឋាភិបាលព្រមទាំងបណ្ដាផ្នែកផ្សេងៗ នៅក្នុងសង្គមរបស់អ្នកឱ្យយល់អំពីសារៈសំខាន់នៃកម្មវិធីនេះ ។

អ្នកនឹងត្រូវបង្ហាញនូវហេតុផលនៃការផ្លាស់ប្ដូរគោលនយោបាយ និងមធ្យោបាយនៃការធ្វើការងារដែលអ្នកជឿជាក់ថា មានការចាំបាច់សំរាប់ការអនុវត្តនូវកម្មវិធីថ្មីនោះទៅដល់ពួកគេ ។ ជាពិសេស

អ្នកត្រូវធ្វើឱ្យម្ចាស់មូលនិធិ (រដ្ឋាភិបាល ឬ មិនមែនរដ្ឋាភិបាល) ជឿជាក់នូវសារៈសំខាន់នៃការផ្តល់មូលនិធិចំពោះកម្មវិធីនោះ ។

### ៦.២.១. ការគាំទ្រ

ប្រសិនបើចង់ឱ្យកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគរបស់អ្នកទទួលបានជោគជ័យ ការសំខាន់អ្នកត្រូវស្វែងរកការគាំទ្រនូវគោលនយោបាយ និងកម្មវិធីទាំងនោះ គឺមានសារៈសំខាន់ណាស់ ។ ចាំបាច់ត្រូវបញ្ចុះបញ្ចូលឱ្យបុគ្គល និងអង្គការជាច្រើនដើម្បីឱ្យ គោលនយោបាយ និងកម្មវិធីនេះពិតជាមានសារៈសំខាន់ ហើយវាគឺជាវិធីដ៏ល្អបំផុត សំរាប់ដោះស្រាយបញ្ហាជំងឺកាមរោគ ។

ការដែលមានសារៈសំខាន់បំផុតនោះ គឺ អ្នកមិនគ្រាន់តែធ្វើឱ្យមានការចូលរួមពីអ្នកដែលគាំទ្រ ឬ អ្នកដែលជាសមាជិកនៃកម្មវិធីនេះតែប៉ុណ្ណោះទេ ប៉ុន្តែអ្នកចាំបាច់ធ្វើឱ្យអ្នកដែលអាចប្រឆាំងនឹងគំនិតរបស់អ្នកជឿជាក់ផងដែរ ។

ឧទាហរណ៍ ប្រហែលជាមានភាពងាយស្រួលក្នុងការបញ្ចុះបញ្ចូលអ្នកគ្រប់គ្រងក្នុងវិស័យអប់រំថាពួកគេអាចមានតួនាទីមួយនៅក្នុងកម្មវិធីនេះ ។ ប៉ុន្តែអាចមានការលំបាកជាងនេះក្នុងការឱ្យពួកគេជួយធ្វើការងារដែលពួកគេបានយល់ព្រមជួយ ពីព្រោះពួកគេមានអាទិភាពជាបន្ទាន់ច្រើនផ្សេងៗទៀតដែលត្រូវធ្វើដែរ ។
ផ្ទុយទៅវិញ ក្នុងបណ្តាប្រទេសជាច្រើនដោយមានមូលហេតុជាច្រើនមានការលំបាកក្នុងការទទួលបាននូវការគាំទ្រយ៉ាងពេញលេញពីបណ្តាមេដឹកនាំ និងអ្នកឯកទេសខាងជំងឺកាមរោគ ។

មេដឹកនាំសាសនាជាច្រើន តែងតែប្រឆាំងនឹងកម្មវិធីបង្ការនិងថែទាំជំងឺកាមរោគ ដោយពួកគេភ័យខ្លាចថា ការជំរុញអោយមានការប្រព្រឹត្តរួមភេទដោយសុវត្ថិភាពអាចនឹងលើកទឹកចិត្តដល់ប្រជាជនពិសេសពួកយុវជនក្មេងៗឱ្យមានដៃគូរួមភេទច្រើន ។ បទពិសោធន៍ជាច្រើនបានបង្ហាញថា វិធីដោះស្រាយមួយដ៏ល្អ គឺ ត្រូវទៅជួបទាក់ទងជាមួយមេដឹកនាំសាសនាទាំងនោះដើម្បីបង្ហាញឱ្យពួកគេយល់ពីទំហំនៃបញ្ហាជំងឺកាមរោគ និងពន្យល់ពីហេតុផលនៃយុទ្ធវិធី និងគោលនយោបាយដែលអ្នកជឿជាក់ថា នឹងដំណើរការល្អ ។

អ្នកឯកទេសជំងឺកាមរោគជាច្រើនដែលកំពុងធ្វើការនៅគ្លីនិកឯកទេស ជារឿយៗ តែងតែប្រឆាំងជំទាស់នូវគោលនយោបាយមួយ ដែលបញ្ចូលនូវវិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញាទៅក្នុងគ្លីនិកដែលមិនមែនឯកទេស ។ ការសំខាន់គឺយើងត្រូវទៅជួបប្រាស្រ័យទាក់ទងនឹងអ្នកទាំងអស់នោះម្តងទៀត ។ បន្ទាប់មកអ្នកអាច :

- ពន្យល់អំពីវិសាលភាពនៃការរាតត្បាតរបស់ជំងឺកាមរោគ
- ពន្យល់ឱ្យអ្នកទាំងនោះជឿថា មានករណីជំងឺកាមរោគច្រើនណាស់ដែលមិនបានទទួលការព្យាបាលក្នុងពេលបច្ចុប្បន្ននេះ
- ធ្វើឱ្យគេជឿជាក់ថា មានភ័ស្តុតាងច្បាស់លាស់ដែលថា វិធីគ្រប់គ្រងថែទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមានដំណើរការល្អ ។
- បញ្ជាក់ឱ្យបានច្បាស់ថា ពួកគេនឹងបន្តមានតួនាទីដ៏សំខាន់មួយក្នុងការផ្តល់នូវការថែទាំព្យាបាលជំងឺកាមរោគ ។
- កំណត់ឱ្យច្បាស់លាស់នូវរបៀបដែលអ្នកឯកទេសព្យាបាលជំងឺទាំងនោះ (រួមជាមួយនឹងការពឹងផ្អែកលើមន្ទីរពិសោធន៍) អាចសហការជាមួយអ្នកដែលមិនមែនឯកទេសព្យាបាល ជំងឺទាំងនោះបាន ។

ក្រុមខ្លះអាចជាអ្នកគាំទ្រ និងជាអ្នកប្រឆាំនឹងធ្វើការផ្លាស់ប្តូរ ។ ឧទាហរណ៍ : បុគ្គលិកដែលកំពុងធ្វើការក្នុងការថែទាំសុខភាពបឋម គ្លីនិកផែនការគ្រួសារ និងសេវាថែទាំសុខភាពមាតា និងទារកអាចទទួលស្គាល់ថាពួកគេ គឺមានតួនាទីយ៉ាងសំខាន់ក្នុងការបង្ការ និងថែទាំជំងឺកាមរោគ ហើយពួកគេមានចំណងយ៉ាងខ្លាំងក្នុងការសិក្សានូវជំនាញថ្មីទាំងនេះ ។
ពួកគេហាក់ដូចជាមានអារម្មណ៍លើសពីនេះទៅទៀតថា គេមានកិច្ចការសំរាប់ធ្វើច្រើនពេករួចទៅហើយជាមួយធនធានដែលតិចតួចហួសហេតុនោះ ។ ពួកគេនឹងស្ទាក់ស្ទើរក្នុងចិត្តក្នុងការទទួលធ្វើការងារថ្មីនេះ ។ ការស្វែងរកការគាំទ្រដ៏ប៉ិនប្រសប់និងការបញ្ចុះបញ្ចូលលួងលោមដោយស្លូតបូតទន់ភ្លន់ មានសារៈសំខាន់ជាសារវ័ន្តប្រសិនបើអ្នកចង់ឱ្យគោលនយោបាយនៃការពង្រីកសេវាថែទាំជំងឺកាមរោគរបស់អ្នកទៅដល់ថ្នាក់ថែទាំសុខភាពបឋមទទួលបានជោគជ័យ ។

អ្នកនឹងយល់ឃើញថា អ្នកត្រូវចាប់ប្រើយុទ្ធសាស្ត្រផ្សេងៗជាច្រើនទៀត ។ យុទ្ធវិធីណាមួយដែលល្អបំផុតអាស្រ័យទៅលើអ្នក លើសង្គមរបស់អ្នក និងអាស្រ័យលើប្រជាជន ឬ អង្គការទាំងឡាយដែលអ្នកកំពុងព្យាយាមធ្វើឱ្យមានឥទ្ធិពលលើពួកគេ ។

### ៦.២.២ ~ យុទ្ធវិធីស្វែងរកការគាំទ្រ

ការស្វែងរកការគាំទ្រជាច្រើននឹងជាប់ទាក់ទងជាមួយអ្នកផ្ទាល់ដែលជា អ្នកគ្រប់គ្រងកម្មវិធី, វិធីដែលខិតខំរកមធ្យោបាយទាក់ទងបុគ្គលដែលមានឥទ្ធិពល ដែលជួយលើកកំពស់នូវគោលនយោបាយនិងកម្មវិធីប្រាប់ដល់អ្នកដទៃផ្សេងៗនៅពេលបន្ទាប់មកទៀត ។

ឧទាហរណ៍ ៖ ប្រសិនបើអ្នកបានធ្វើឱ្យអ្នកឯកទេសជាន់ខ្ពស់ផ្នែកជំងឺកាមរោគជឿជាក់ថា វិធីគ្រប់គ្រងថៃទាំដោយពឹងផ្អែកលើចង្កោមរោគសញ្ញាមានប្រសិទ្ធិភាពនោះ ពួកគេនឹងខិតខំស្វែងរកការគាំទ្រឱ្យអ្នកនៅពេលមានការដោះស្រាយបញ្ហាជាមួយអាជ្ញាធរសុខាភិបាល ។

ដូចគ្នានេះដែរ អ្នកគួរតែឆ្លៀតយកគ្រប់ឱកាសទាំងអស់ដើម្បីជួបជាមួយនឹងអ្នកផលិតកម្មវិធីវិទ្យុ-ទូរទស្សន៍ អ្នកនិពន្ធសារពត៌មាននិងអ្នកសារពត៌មានផ្សេងទៀត តារាភាពយន្ត និងអ្នកល្បីល្បាញក្នុងស្រុកដទៃៗទៀត ។ ប្រសិនបើមានអ្នកខ្លះក្នុងចំណោមអ្នកទាំងនោះ ជឿជាក់អំពីតំរូវការជាបន្ទាន់ក្នុងការដោះស្រាយបញ្ហានៃការរាតត្បាតនៃជំងឺកាមរោគ នោះពួកគេនឹងក្លាយជាអ្នកជួយស្វែងរកការគាំទ្រដ៏សំខាន់ ចំពោះកម្មវិធីនៅចំពោះមុខសាធារណៈជនទូទៅ ។

ការស្វែងរកការគាំទ្រខ្លះនឹងមានលក្ខណៈជាសាធារណៈខ្លាំងណាស់ ប៉ុន្តែមានសកម្មភាពជាច្រើនដែលមិនបង្ហាញឱ្យដឹងជាសាធារណៈទេ ។ អ្នកត្រូវសំរេចថា តើវិធីណាមួយដែលសមស្របហើយពេលណាដែលត្រូវប្រើវានោះ ។

ជួនកាល ការជួបប្រជុំជាសាធារណៈជាមួយក្រុមមហាជន គឺ ជាយុទ្ធសាស្ត្រមួយមានសារៈប្រយោជន៍ណាស់ ។ ឧទាហរណ៍ ៖ ការជួបប្រជុំជាមួយបុគ្គលិកសិក្សាទាំងអស់ ឬ មាតាបិតារបស់សិស្សដែលរៀននៅសាលារៀនណាមួយ ការជួបប្រជុំជាមួយសមាជិកនៃសមាគមន៍នារី ឬក៏ជាមួយនិយោជិកដែលជួលពួកកម្មករពនេចរ(កម្មករដែលដើរធ្វើការពីកន្លែងមួយទៅកន្លែងមួយទៀត)។

ប្រព័ន្ធផ្សព្វផ្សាយពត៌មានអាចមានប្រយោជន៍ផងដែរ ។ ផ្សាយនូវទិន្នន័យប្រចាំឆ្នាំអំពីរបាយការណ៍ស្ដីអំពីជំងឺកាមរោគ អាចជាឱកាសមួយសំរាប់រៀបចំជាសន្និសីទសារពត៌មានដើម្បីផ្សព្វផ្សាយជាសាធារណៈអំពីវិសាលភាព និងទំនោរវិវត្តនៃការរាតត្បាតរបស់ជំងឺកាមរោគ ។

ផ្ទុយទៅវិញ ផ្សព្វផ្សាយយ៉ាងទូលំទូលាយជាសាធារណៈអំពីបញ្ហាចំរូងចំរាស់ណាមួយកាន់តែច្រើនអាចផ្ដល់នូវលទ្ធផលមិនល្អ ។ ផ្សាយជាសាធារណៈដែលលើកដំកើងគំនិតដែលថា “ការអប់រំផ្នែកផ្លូវភេទ គឺ ជាការអប់រំត្រូវតែធ្វើទៅនៅគ្រប់សាលារៀនទាំងអស់” អាចទទួលបាននូវការផ្ដល់យោបល់ប្រឆាំងពីសំណាក់មេដឹកនាំ នយោបាយ និង សាសនា នៅមុនពេលដែលអ្នកមានឱកាសដើម្បីជួបប្រជុំជាមួយអ្នកទាំងនោះ ។ ជាការប្រសើរណាស់ដែលអ្នកត្រូវខិតខំទៅជួបប្រាស្រ័យដោយផ្ទាល់ជាមួយមន្ត្រីក្នុងវិស័យអប់រំ គ្រូបង្រៀន មាតាបិតា មេដឹកនាំសាសនា និងអ្នកនយោបាយដើម្បីពន្យល់អំពី និងលើកកំពស់នូវសារៈសំខាន់ នៃការអប់រំផ្នែកផ្លូវភេទចំពោះយុវជន វ័យក្មេង ។

### ៦.២.៣ ~ ការសន្និដ្ឋាន

ការស្វែងរកការគាំទ្រ គឺជាការសំខាន់ណាស់ ប៉ុន្តែវាជួបនឹងការលំបាកជាច្រើន និងទាមទារឱ្យមានការប្រឹងប្រែងជាប់ជាប្រចាំ មានន័យថា ត្រូវយកនូវគ្រប់ឱកាសដើម្បីលើកកំពស់ គោលនយោបាយ និងកម្មវិធីរបស់អ្នក ។ កិច្ចការនេះអាចធ្វើឡើងនៅពេលមានអង្គប្រជុំជាផ្លូវការមួយដែលអ្នកបានរៀបចំឡើងជាមួយបុគ្គលម្នាក់ ឬអង្គការផ្សេងៗជាពិសេសក្នុងគោលបំណងពន្យល់អំពីកម្មវិធីនេះ ។ វាអាចធ្វើឡើងនៅក្នុងអង្គប្រជុំដែលរៀបចំឡើងក្នុងគោលបំណងមួយផ្សេងទៀត ឧទាហរណ៍ដូចជាពិភាក្សាអំពីផែនការគ្រួសារ ។ វាអាចនឹងធ្វើឡើងនៅក្នុងសន្និសិទ ឬ ការប្រជុំនៃអ្នកវិជ្ជាជីវៈផ្សេងៗទៀត និងថែមទាំងអាចធ្វើឡើងក្នុងពិធីជួបជុំសង្គមផ្សេងៗ ។

## ៦.៣ ~ ការបង្កើតនូវគោលការណ៍ណែនាំបច្ចេកទេស

ដោយបានការយល់ព្រមលើគោលនយោបាយនៃការពង្រីកសេវាថែទាំជំងឺកាមរោគ និងលើគោលដៅសំរាប់អនុវត្តនូវសេវានេះរួចហើយ ជាការចាំបាច់គេត្រូវបង្កើតនូវគោលការណ៍ណែនាំផ្សេងៗសំរាប់ជួយធានាឱ្យមានការអនុវត្តត្រឹមត្រូវ និងជាប់ជាប្រចាំនូវសកម្មភាពទាំងឡាយដែលបានគ្រោងទុកនេះ ។
គោលការណ៍ណែនាំទាំងឡាយគួរតែអធិប្បាយបែបបទអនុវត្តឱ្យបានលំអិត និងគួរអនុលោមទៅតាមគោលនយោបាយ និងគោលដៅទាំងនោះ ។ វាមានសារៈសំខាន់ណាស់នៅពេលដែលគេត្រូវការចាំបាច់នូវវិធីគំរូដូចគ្នាតែមួយ ។ គោលការណ៍ណែនាំទាំងនោះត្រូវបានគេប្រើជាទូទៅគឺ ដើម្បីរៀបរាប់នូវបែបបទអនុវត្តនៃការគ្រប់គ្រងករណីជំងឺកាមរោគទាំងឡាយដែលបុគ្គលិកសុខាភិបាលទាំងអស់ត្រូវអនុវត្តតាម ។

ជំហានសំខាន់ដំបូងក្នុងការបង្កើត ឬ កែសំរួលគោលការណ៍ណែនាំ គឺដើម្បីកំណត់រកផ្នែកចំបងៗទាំងឡាយដែលត្រូវការនូវគោលការណ៍ណែនាំទាំងនោះ ។ ខាងក្រោមនេះ គឺជាបញ្ជីនៃផ្នែកផ្សេងៗដើម្បីបង្កើតឡើងនូវគោលការណ៍ណែនាំមួយសំរាប់កម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគនៅក្នុងប្រទេសភាគច្រើន :

- ការគ្រប់គ្រងថែទាំករណីជំងឺកាមរោគ
- ការជ្រើសរើស និងការប្រើប្រាស់តេស្តសំរាប់ការធ្វើរោគវិនិច្ឆ័យជំងឺកាមរោគ
- វិធីសាស្រ្តសំរាប់ការអង្កេតតាមដានអេពីដេមីសាស្រ្តនៃជំងឺកាមរោគ
- ការគ្រប់គ្រងថែទាំដៃគូរួមភេទ

- ការធ្វើតេស្តស្រាវជ្រាវរកជំងឺស្វាយលើស្ត្រីមានផ្ទៃពោះមុនពេលសំរាល
- ការធានានូវគុណភាពសំរាប់មន្ទីរពិសោធន៍កាមរោគ
- ការធានានូវគុណភាពសំរាប់ស្រោមអនាម័យ ។ល។

នៅក្នុងប្រទេសភាគច្រើន អ្នកជំនាញការបច្ចេកទេសជាច្រើនជាអ្នកទទួលខុសត្រូវក្នុងការបង្កើតគោលការណ៍ណែនាំអំពីផ្នែកដែលពាក់ព័ន្ធ ។ ការទទួលខុសត្រូវចំបងសំរាប់បុគ្គលិកគ្រប់គ្រងកម្មវិធី គឺត្រូវធានាយ៉ាងណាឱ្យគោលការណ៍ណែនាំឆ្លើយតបត្រឹមត្រូវទៅនឹងកត្តាសំខាន់ៗ ហើយគោលការណ៍ណែនាំទាំងនោះត្រូវ :

- មានលក្ខណៈច្បាស់លាស់ចំគោលដៅ និងពេញលេញគ្រប់គ្រាន់
- សមស្របទៅតាមពត៌មានបែបវិទ្យាសាស្ត្រថ្មីៗ
- សកម្មភាពការពារ និងព្យាបាលជំងឺទាំងឡាយប្រកបដោយប្រសិទ្ធិភាព
- សមស្របទៅតាមគោលនយោបាយរបស់រដ្ឋាភិបាលដែលបានអនុម័តយល់ព្រមហើយ និង
- ណែនាំអំពីការអនុវត្តន៍ជាក់ស្តែងទាំងឡាយដែលត្រូវធ្វើជាមួយនឹងធនធានដែលគេអាចរកបាន

**លំហាត់ ៦.២**

<u>លំហាត់ផ្ទាល់ខ្លួន</u> :

ចូររៀបរាប់ខ្លឹមសារនៃគោលការណ៍ណែនាំអំពីការគ្រប់គ្រងថែទាំដៃគូរួមភេទរបស់អ្នកជំងឺកាមរោគនៅក្នុងប្រទេសរបស់អ្នក ។

## ៥.៣ ~ ការពិភាក្សាពេញអង្គអំពីការផ្តល់ការគាំទ្រ និងការបង្កើតគោលការណ៍ណែនាំ

## ឧបសម្ព័ន្ធទី ១

**ឧទាហរណ៍មួយចំនួននៃគោលនយោបាយ :**

- "គ្លីនិកឯកទេសជំងឺកាមរោគដែលមានស្រាប់ គួរដើរតួជាមជ្ឈមណ្ឌលបង្អែកសំរាប់ថែទាំអ្នកជំងឺដែលបញ្ជូនមកពីគ្លីនិកមិនមែនឯកទេស ហើយព្រមពេលជាមួយគ្នានោះដែរត្រូវបន្តការផ្តល់សេវាថែទាំជំងឺកាមរោគជូនដល់អ្នកជំងឺដែលការព្យាបាលនៅគ្លីនិកឯកទេសនេះតទៅទៀត។ គ្លីនិកឯកទេសទាំងនេះ ត្រូវទទួលខុសត្រូវផងដែរក្នុងការបណ្តុះបណ្តាលបុគ្គលិកដែលមកពីគ្លីនិកមិនមែនឯកទេស" ។

- "គ្លីនិកថែទាំសុខភាពបឋម គ្លីនិកផែនការគ្រួសារ និងគ្លីនិកគាំពារសុខភាពមាតា និងទារកទាំងអស់មានតួនាទីនៅក្នុងការគ្រប់គ្រងថែទាំជំងឺកាមរោគ ។ បុគ្គលិកនៅគ្លីនិកទាំងនោះគួរត្រូវទទួលការបណ្តុះបណ្តាលអំពីការគ្រប់គ្រង និងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា ។

- "បុគ្គលិកនៃគ្លីនិកជំងឺកាមរោគ គ្លីនិកថែទាំសុខភាពបឋម គ្លីនិកផែនការគ្រួសារ និងគ្លីនិកគាំពារសុខភាពមាតា និងទារក ត្រូវទទួលការបណ្តុះបណ្តាលដើម្បីធ្វើឱ្យកាន់តែប្រសើរឡើងនូវជំនាញរបស់គេស្តីពីការពិភាក្សាជាមួយអ្នកជំងឺអំពីការរួមភេទ សុខភាពផ្លូវភេទ និងជំងឺកាមរោគទាំងឡាយ" ។

- "ក្នុងកំឡុងពេលនៃការបណ្តុះបណ្តាលត្រូវរំលឹកបុគ្គលិកទាំងអស់ឱ្យចងចាំថា ពួកគេមិនត្រូវប្រាប់ពត៌មានអំពីអ្នកជំងឺម្នាក់ទៅឱ្យអ្នកដទៃម្នាក់មួយទៀតដឹងបានឡើយ លុះណាតែពួកគេបានការយល់ព្រមពីអ្នកជំងឺនោះសិន" ។

- " បុគ្គលិកសុខាភិបាលគួរត្រូវទទួលការបណ្តុះបណ្តាលក្នុងការកំណត់រក (តាមដែលអាចធ្វើបាន) ជំងឺកាមរោគដែលមាននៅលើអ្នកជំងឺដែលមិនបានត្អូញត្អែរប្រាប់ពីរោគសញ្ញានៃជំងឺកាមរោគរបស់ខ្លួនដល់គ្រូពេទ្យ "

- "របៀបគ្រប់គ្រង និងបុគ្គលិកទាំងអស់នៃគ្លីនិកជំងឺកាមរោគ គ្លីនិកថែទាំសុខភាពបឋម គ្លីនិកផែនការគ្រួសារ និងគ្លីនិកគាំពារសុខភាពមាតា និងទារក ត្រូវធានាយ៉ាងណាឱ្យអ្នកជំងឺអាចទទួលការជួបពិគ្រោះ ក្នុងលក្ខណៈស្ងាត់កំបាំង "

- “សេវាថែទាំជំងឺកាមរោគនៅក្នុងគ្លីនិកថែទាំសុខភាពបឋម គ្លីនិកផែនការគ្រួសារ និងគ្លីនិកគាំពារ សុខភាពមាតា និងទារក គឺជាផ្នែកមួយនៃសេវាថែទាំទូទៅរបស់គ្លីនិក ។ សេវាថែទាំជំងឺកាមរោគនេះត្រូវបានបង្ហាញឱ្យឃើញថាជាសេវាថែទាំជំងឺកាមរោគឡើយ ។ ”
- “ ការចាត់ចែងគ្រប់គ្រងនៃគ្លីនីកជំងឺកាមរោគ, គ្លីនិកថែទាំសុខភាពបឋម, គ្លីនិកផែនការគ្រួសារ និងគ្លីនិកគាំពារសុខភាពមាតា និងទារក ត្រូវធានាឱ្យមាន ឱសថចាំបាច់ទាំងអស់សំរាប់ព្យាបាលជំងឺកាមរោគសំរាប់ប្រើប្រាស់នៅតាមបណ្ដាគ្លីនិកទាំងនោះ ។ ”

## ម៉ូឌុលទី ៧

# ការគ្រប់គ្រងកម្មវិធីប្រយុទ្ធនឹងជំងឺកាមរោគ

### ៧.១ ~ ការធ្វើផែនការ (Planing)

នៅពេលដែលមានការព្រមព្រៀងគ្នាលើការកែលំអ និងការពង្រីកសេវាថែទាំកាមរោគរួចហើយៗជាការចាំបាច់យើងត្រូវកំណត់កម្មវត្ថុក្នុងការអនុវត្តគោនយោបាយ និងយុទ្ធសាស្ត្រ និង សកម្មភាពនានាដែលធ្វើឱ្យសំរេចបាននូវកម្មវត្ថុទាំងនោះ ។ ដើម្បីសំរេចបាននូវការងារនេះ អ្នកគប្បីបង្កើតនូវក្រុមការងារមួយឡើង ។

**ក្រុមការងារ** (Working Group)

ដោយហេតុថាអ្នកចង់ឱ្យសេវាមួយចំនួនដែលមានស្រាប់រួមសហការគ្នា ការសំខាន់គឺ គេត្រូវធ្វើឱ្យស្ថាប័នទាំងនោះចូលរួមក្នុងដំណាក់កាលនានា ក្នុងការធ្វើផែនការ ។ ការធ្វើឱ្យបុគ្គលិកទាំងអស់ដែលផ្តល់សេវាថែទាំកាមរោគចូលរួមក្នុងការធ្វើផែនការនឹងជួយអោយអ្នកទាំងនោះយល់អំពីតួនាទីផ្ទាល់របស់គេនៅក្នុងការផ្តល់សេវា និងតួនាទីរបស់អ្នកដទៃៗ ទៀត ។

គេអាចបង្កើតក្រុមការងារមួយដែលមានតំណាងមកពីគ្រប់ផ្នែកទាំងអស់ (ដូចជាគ្លីនិកឯកទេសព្យាបាលជំងឺកាមរោគ គ្លីនិកថែទាំសុខភាពបឋម ពន្យាកំណើត។ល។) ដើម្បីជួយក្នុងការធ្វើផែនការ ។ សមាជិកភាគច្រើននៃក្រុមការងារ គប្បីជាអ្នកមានបទពិសោធន៍គ្រប់គ្រាន់ក្នុងផ្នែកដែលខ្លួនធ្វើជាអ្នកតំណាង និងក្នុងការប្តេជ្ញាចិត្តអនុវត្តការងារតាមបែបថ្មី ។

ក្រោយពីបានជំរុញគំនិតកែលំអ និងសេវាថែទាំជំងឺកាមរោគរួចហើយ អ្នករួមជាមួយក្រុមការងារត្រូវសំរេច ចិត្តលើគោលបំណង យុទ្ធសាស្ត្រ និងសកម្មភាពនានា សំរាប់កម្មវិធីថ្មីក្នុងរយៈពេល ១-២ ឆ្នាំដំបូង ។

**កម្មវត្ថុ យុទ្ធសាស្ត្រ និងសកម្មភាព**

ខាងក្រោមនេះ គឺជាឧទាហរណ៍ខ្លះៗ នៃកម្មវត្ថុយុទ្ធសាស្ត្រ និងសកម្មភាព :

***កម្មវត្ថុទី១*** : ធានាយ៉ាងណាឱ្យប្រជាពលរដ្ឋគ្រប់រូបដែលកើតកាមរោគទទួលបាននូវការព្យាបាលត្រឹមត្រូវ ។

***យុទ្ធសាស្ត្រ*** ៖

1. ជ្រើសរើសយកវិធីគ្រប់គ្រងថែទាំកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាជាវិធីគ្រប់គ្រងថែទាំកាមរោគសំរាប់ជាតិទាំងមូល ។

**សកម្មភាព ៖**

- បង្កើតគោលនយោបាយថ្មីស្តីអំពីការព្យាបាលជំងឺកាមរោគ
- ស្វែងរកការគាំទ្រចំពោះគោលនយោបាយថ្មីពីសំណាក់អ្នកឯកទេស និងថ្នាក់ដឹកនាំ
- ស្នើសុំការសំរេចពីក្រសួងសុខាភិបាល
- ផ្សព្វផ្សាយគោលនយោបាយទៅកាន់ថ្នាក់ខេត្ត ស្រុក ។ល។

2. បង្កើនចំណេះដឹងបុគ្គលិកសុខាភិបាលស្តីអំពីការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញា

**សកម្មភាព ៖**

- រៀបរៀងឯកសារបណ្តុះបណ្តាល
- បណ្តុះបណ្តាលគ្រូបង្ហាត់ចំនួន... នាក់ សំរាប់ខេត្តនិមួយៗ
- បណ្តុះបណ្តាលបុគ្គលិកសុខាភិបាលនៃមណ្ឌលសុខភាពសំរាប់ខេត្តនិមួយៗ ។ល។

3. បញ្ចូលវិធីគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាទៅក្នុងកម្មវិធីសិក្សានៃមហាវិទ្យាល័យវេជ្ជសាស្ត្រ សាលាបច្ចេកទេសថែទាំវេជ្ជសាស្ត្រ

**សកម្មភាព ៖**

- ធ្វើការកែលំអកម្មវិធីសិក្សានៅមហាវិទ្យាល័យវេជ្ជសាស្ត្រ និងសាលាបច្ចេកទេសថែទាំសុខភាព
- ដាក់ឱ្យប្រើប្រាស់នូវកម្មវិធីសិក្សាថ្មី
- វាយតំលៃចំណេះដឹងសិក្ខាកាមក្រោយពេលបណ្តុះបណ្តាល ។ល។

4. ធានាយ៉ាងណាឱ្យមានការផ្គត់ផ្គង់សមស្របនូវឱសថសំរាប់ព្យាបាលជំងឺកាមរោគនៅតាមសេវាថែទាំសាធារណៈ

**សកម្មភាព :**

- បញ្ចូលមុខឱសថសមស្របសំរាប់ព្យាបាលជំងឺកាមរោគទៅក្នុងបញ្ជីឱសថសារវ័ន្ត
- ប៉ាន់ស្មានតំរូវការឱសថសំរាប់ព្យាបាលកាមរោគសំរាប់ប្រទេសទាំងមូល
- ធានាឱ្យមានការផ្គត់ផ្គង់ឱសថសំរាប់ព្យាបាលជំងឺកាមរោគជារៀងរាល់ឆ្នាំ
- ធានាអោយបាននូវការបែងចែកឱសថប្រចាំត្រីមាសទៅកាន់សេវាដែលផ្តល់ការថែទាំជំងឺកាមរោគ ។ល។

គេអាចប្រើវិធីដូចគ្នានេះដែរសំរាប់គោលបំណងផ្សេងៗទៀត ដែលអ្នកបានកំណត់សំរាប់កម្មវិធីរបស់អ្នក ដូចជា :

***កម្មវត្ថុទី ២*** : បង្ការការចំលងកាមរោគថ្មីៗ រួមទាំងមេរោគអេដស៍ផងដែរ ក្នុងចំណោមប្រជាពលរដ្ឋ

***កម្មវត្ថុទី ៣*** : លើកទឹកចិត្តអ្នកដែលយល់ឃើញថាខ្លួនគេកើតកាមរោគ ឱ្យទៅស្វែងរកការព្យាបាលត្រឹមត្រូវ

***កម្មវត្ថុទី ៤*** : ស្វែងរក និងព្យាបាលអ្នកផ្ទុកជំងឺកាមរោគដែលពុំបានគិតថា ខ្លួនកើតជំងឺកាមរោគ ។

បន្ទាប់ពីបានបង្កើតគំរោងផែនការធ្វើសកម្មភាព (workplan) រួចមក ជាការសំខាន់អ្នកនិងក្រុមការងារត្រូវសំរេចចិត្តលើយុទ្ធសាស្ត្រ និងសកម្មភាពទាំងឡាយដែលត្រូវអនុវត្តជាអាទិភាព ជារៀងរាល់ឆ្នាំ ។

**ការផ្តល់អាទិភាពដល់យុទ្ធសាស្ត្រ និង សកម្មភាព**

ដោយហេតុថា ប្រភពធនធាន (មនុស្ស និងថវិកា) សំរាប់កម្មវិធីមានកំរិត អ្នកត្រូវសំរេចចិត្តជ្រើសរើសយកតែយុទ្ធសាស្ត្រ និងសកម្មភាពទាំងឡាយណាដែលសំខាន់បំផុតមកអនុវត្តតែប៉ុណ្ណោះ ។

បន្ទាប់មក អ្នកត្រូវធ្វើការសំរេចចិត្តលើយុទ្ធសាស្ត្រ និងសកម្មភាពណាដែលអាចសំរេចបានដោយពឹងផ្អែកលើប្រភពធនធានបច្ចុប្បន្នដែលកម្មវិធីមាន ។ *ឧទាហរណ៍ : អ្នកអាចសំរេចចិត្តថាការសំខាន់ គឺត្រូវឱ្យមណ្ឌលសុខភាព ឬ គ្លីនិកផែនការគ្រួសារនិមួយៗ មានស្តុកស្រោមអនាម័យសំរាប់ប្រើប្រាស់ ។ ក៏ប៉ុន្តែប្រសិនបើការផ្គត់ផ្គង់ស្រោមអនាម័យមានកំរិតតិចតួចនោះ គ្លីនិក ឬមណ្ឌលសុខភាពអាចទទួលបានស្រោមអនាម័យតិចតួច ហើយអាចខ្វះ ឬ ដាច់ស្តុកស្រោមអនាម័យសំរាប់ប្រើប្រាស់ ជាហេតុនាំឱ្យ បុគ្គលិក និងអ្នកជំងឺបាត់បង់នូវទំនុកចិត្តលើកម្មវិធី ។ ដូច្នេះ*

*ដំណោះស្រាយ គឺត្រូវផ្តោតលើការផ្គត់ផ្គង់ ស្រោមអនាម័យដល់កន្លែងណាដែលអ្នកយល់ឃើញថាមានអត្រាកើតជំងឺកាមរោគខ្ពស់ ឬ ក៏មានការ ប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ ។*

ក្រោយពីបានសំរេចជ្រើសរើសយកយុទ្ធសាស្ត្រ និងសកម្មភាពទាំងឡាយដែលអាចសំរេចបានរួច អ្នកត្រូវសួរខ្លួនឯងថា តើមានយុទ្ធសាស្ត្រ និងសកម្មភាពប៉ុន្មាន និងតើត្រូវធ្វើដូចម្តេចដើម្បីសំរេចឱ្យបាន*ក្នុងកំឡុងពេលដែលអ្នកមាន* ។ និយាយម្យ៉ាងទៀតថា អ្នកត្រូវគិតអំពីការប្រើប្រាស់ពេលវេលារបស់អ្នក ។

នៅពេលដែលអ្នកបានសំរេចអំពីអ្វីដែលអ្នកត្រូវធ្វើក្នុងកំឡុងពេលមួយកំណត់ (ឧទាហរណ៍ក្នុងឆ្នាំដំបូងនៃកម្មវិធី) រួចមក អ្នកត្រូវគិតអំពីទំនាក់ទំនងរវាងផ្នែកផ្សេងៗទៀតនៃកម្មវិធី ។ អ្នកត្រូវសំរេចចិត្តអំពី***លំដាប់*** ដែលត្រូវអនុវត្តយុទ្ធសាស្ត្រ និងសកម្មភាពទាំងនោះ ។ *ឧទាហរណ៍ : មុននឹងធ្វើការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលអំពីការគ្រប់គ្រងថែទាំជំងឺកាមរោគដោយពឹងផ្អែកលើចង្កោមរោគសញ្ញាអ្នកត្រូវធានាយ៉ាងណាឱ្យមានការផ្គត់ផ្គង់ឱសថ សំភារៈបរិក្ខារ និងស្រោមអនាម័យឱ្យបានទៀងទាត់ជាមុនសិនដើម្បីឆ្លើយតបនឹងតំរូវការរបស់អ្នកជំងឺ ។*

សង្ខេបមក ការសំខាន់នោះគឺមិនត្រូវមានមហិច្ឆិតាហួសហេតុ ត្រូវសំរេចចិត្តអនុវត្តអ្វីដែលអាចសំរេចបានស្របទៅតាមប្រភពធនធានដែលមានក្នុងកំឡុងពេលមួយដែលអ្នកបានកំណត់ ។ ទោះបីជាអ្នកលើកផែនការអនុវត្តការងារណាមួយក៏ដោយអ្នកគប្បី :

- កំណត់កម្មវត្ថុ យុទ្ធសាស្ត្រ និងសកម្មភាព ។ល។ រួចចាត់ថ្នាក់តាមលំដាប់នៃ***សារៈសំខាន់របស់វា។***
- ធ្វើការសំរេចចិត្តយកកម្មវត្ថុ យុទ្ធសាស្ត្រ និងសកម្មភាពណាដែលអាចសំរេចបានយោលទៅតាម***ប្រភពធនធាន*** (មនុស្ស និងថវិកា) ដែលមាន ។
- ធ្វើការសំរេចចិត្តជ្រើសរើសយកអ្វីដែលអ្នកអាចសំរេចបានទៅតាម***រយៈពេលដែលមាន*** ។
- ធ្វើការសំរេចចិត្តលើ***លំដាប់***ដែលត្រូវអនុវត្តការងារ ។

សូមចងចាំថា ប្រសិនបើអ្នកចង់ធ្វើឱ្យសហគមន៍ និងបុគ្គលិកសុខាភិបាលមានទំនុកចិត្តមកលើកម្មវិធីរបស់អ្នក យកល្អអ្នកគប្បីធ្វើអ្វីបានតិច ជាជាងធ្វើអ្វីបានច្រើនហើយសំរេចលទ្ធផលមិនបានល្អ ។ នៅពេលដែលក្រុមការងារសំរេចលើអាទិភាពនានា រួចហើយនោះ គេត្រូវរៀបចំបង្កើតជាគំរោងផែនការ (workplan) សំរាប់រយៈពេលណាមួយកំណត់ ។ គំរោងផែនការនេះត្រូវបញ្ជាក់អំពីកាលវិភាគ

(timetable) និងថវិកា (budget) ឱ្យមានលក្ខណៈប្រាកដនិយម ។ វិធីមួយ គឺត្រូវរៀបចំតារាងមួយដែលមានរាយឈ្មោះសកម្មភាព និងកាលវិភាគ (timetable) ដែលបង្ហាញអំពីកាលកំណត់ដែលត្រូវអនុវត្តសកម្មភាពនិមួយៗ ។

នៅពេលដែលមានការព្រមព្រៀងគ្នាលើគំរោងផែនការរួចមក គេត្រូវចាប់ផ្តើមអនុវត្តសកម្មភាពនៅកន្លែងណាដែលគេយល់ថា មានអត្រាកើតកាមរោគខ្ពស់ និង/ឬ មានការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ ។ កន្លែងដែលត្រូវធ្វើសកម្មភាពជាអាទិភាពត្រូវអាស្រ័យលើពត៌មានដែលទទួលបានពីប្រភពចំនួន ៤ ដូចជា :

- ទិន្នន័យអេពីដេមីសាស្ត្រដែលមានស្រាប់
- លទ្ធផលនៃការសិក្សាស្រាវជ្រាវអំពីស្ថានភាពអេពីដេមីសាស្ត្រនៃជំងឺ
- លទ្ធផលនៃការសិក្សាអំពីកិរិតនៃការប្រព្រឹត្តប្រឈមមុខនឹងគ្រោះថ្នាក់នៃការចំលងកាមរោគ
- ការយល់ដឹងអំពីអត្ថិភាពនៃ " ក្រុមស្នូល " (core group) (ដែលជាប្រភពនៃការឆ្លង និងចំលងជំងឺ)
- ពត៌មានដែលទទួលបានពីមូលដ្ឋាននានា (ដូចជា ពត៌មានដែលបានពីនគរបាល សារពត៌មាន ។ល។)

ក្រុមការងារត្រូវតាមដានមើលការអនុវត្តសកម្មភាព ហើយត្រូវបង្កើតជាក្រុមសំរបសំរួលការងារ (coordinating group) សំរាប់ការធ្វើសមាហរណកម្មសេវាថែទាំកាមរោគ (integrated service) ។

**លំហាត់ ៧.១**

<u>**ការពិភាក្សាតាមក្រុម**</u> :

បែងចែកសិក្ខាកាមជា ៤ក្រុម ។ ក្រុមនិមួយៗត្រូវពិចារណាលើយុទ្ធសាស្ត្រ និងសកម្មភាពដែលត្រូវយកមកអនុវត្តដើម្បីសំរេចបាននូវគោលបំណងនិមួយៗ ដូចខាងក្រោមនេះ ។

ក្រុមទី ១ : ធានាយ៉ាងណាឱ្យអ្នកជំងឺកាមរោគរាល់រូបអាចទទួលបាននូវការព្យាបាលត្រឹមត្រូវ ។
ក្រុមទី ២ : បង្ការប្រជាពលរដ្ឋកុំឱ្យឆ្លងជំងឺកាមរោគ (រួមទាំងជំងឺអេដស៍) សាជាថ្មីម្តងទៀត ។

| | |
|---|---|
| ក្រុមទី ៣ : | លើកទឹកចិត្តអ្នកដែលយល់ឃើញថា ខ្លួនអាចកើតជំងឺកាមរោគឱ្យមកស្វែងរកការព្យាបាលត្រឹមត្រូវ ។ |
| ក្រុមទី ៤ : | ស្វែងរកនិងព្យាបាលអ្នកផ្ទុកជំងឺកាមរោគដែលពុំបានយល់ឃើញខ្លួនអាចកើតកាមរោគ។ |
| បន្ទាប់មក សូមអោយតំណាងក្រុមនិមួយៗ ឡើងរាយការណ៍លទ្ធផលនៃការពិភាក្សាតាមក្រុមតូច ។ | |

## ៧.២ ~ ការតាមដានត្រួតពិនិត្យ និងវាយតំលៃ (Monitoring and Evaluation)

### សេចក្តីផ្តើម

ការតាមដានត្រួតពិនិត្យ និងវាយតំលៃមានសារសំខាន់ជាសារវ័ន្តសំរាប់គ្រប់កម្មវិធីទាំងអស់ ហើយទាមទារឱ្យមានការពិចារណាចាប់តាំងពីដំណាក់កាលធ្វើផែនការ ។ ប្រសិនបើអ្នកចង់ដឹងថា តើកម្មវិធីរបស់អ្នកផ្តល់នូវសេវាថែទាំកាមរោគដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយដែលអាចទទួលយកបានដោយអ្នកជំងឺ អ្នកត្រូវតាមដានត្រួតពិនិត្យអំពីដំណើរការនៃការផ្តល់សេវាដោយប្រមូលយកទិន្នន័យសមស្រប ហើយបន្ទាប់មកត្រូវធ្វើការវាយតំលៃវា ។ បើគ្មានការតាមដានត្រួតពិនិត្យ និងការវាយតំលៃទេនោះ អ្នកពុំអាចដឹងថា ទិដ្ឋភាពណាខ្លះនៃការផ្តល់សេវាមានដំណើរការល្អ និងផ្នែកណា ខ្លះដែលមានបញ្ហានោះទេ ។

***សំរាប់ការតាមដាន និងវាយតំលៃមានចំណុចសំខាន់ៗ :***

- ត្រូវរៀបចំឱ្យមានការតាមដានត្រួតពិនិត្យ និង/ឬ វាយតំលៃនៃសេវាថែទាំកាមរោគក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងសេវាថែទាំឱ្យបានឆាប់បំផុត

- បុគ្គលិកផ្តល់សេវាថែទាំត្រូវទំលាប់ប្រមូលនិងរាយការណ៍នូវពត៌មានដែលចាំបាច់ឱ្យបានជាប់ជាប្រចាំ

- មិនត្រូវឱ្យបុគ្គលិកប្រមូលយកពត៌មានច្រើនពេកទេ ហើយក៏មិនត្រូវចំណាយពេលវេលាច្រើនពេកដែរ សំរាប់ការប្រមូលយកពត៌មានទាំងនោះ ។

- ត្រូវសុំឱ្យបុគ្គលិកទាំងនោះប្រមូលយកតែពត៌មានណាដែលត្រូវការយកមកប្រើប្រាស់ប៉ុណ្ណោះ ។

- ការប្រមូលយកពត៌មានត្រូវមានលក្ខណៈងាយស្រួលក្នុងការប្រមូល ហើយត្រូវស្ថិតជាផ្នែកមួយនៃសកម្មភាពដែលត្រូវអនុវត្តជាប្រចាំនៅតាមគ្លីនិក ឬ ក្នុងកំឡុងពេលដ៏ខ្លី ចុះត្រួតពិនិត្យដល់ទីកន្លែង

- បុគ្គលិកត្រូវយល់អំពីសារៈសំខាន់នៃការប្រមូលយកពត៌មាន

- គប្បីផ្តល់ចំលើយតប (feedback) លើលទ្ធផលនៃការវាយតំលៃទៅកាន់បុគ្គលិកដែលប្រមូលយកទិន្នន័យដើម្បីឱ្យអ្នកទាំងនោះបានយល់អំពីតំលៃនៃពត៌មានទាំងនោះ ។

ការតាមដានត្រួតពិនិត្យ និងការវាយតំលៃត្រូវធ្វើទៅដោយប្រមូលយកនូវការងារដែលអនុវត្តបានសំរេច (output) និងដោយប្រើប្រាស់នូវសន្ទស្សន៍ (indicators) នានា តែត្រូវបានជ្រើសរើសយកមកប្រើប្រាស់ ។

តារាងខាងក្រោមនេះ បង្ហាញអំពីពត៌មានមួយចំនួនដែលអ្នកចង់ដឹង

| ***ចំណុចដែលអ្នកអាចធ្វើការតាមដានត្រួតពិនិត្យ*** | ***សំណួរដែលអ្នកត្រូវសួរ*** |
|---|---|
| ស្តង់ដារនៃសេវាថែទាំដែលបានផ្តល់ជូន | - តើបុគ្គលិកថែទាំ<br>♦ បានស្រង់ប្រវត្តិជំងឺដែរឬទេ ?<br>♦ ពិនិត្យអ្នកជំងឺបានត្រឹមត្រូវឬទេ ?<br>- តើមាន :<br>♦ ឱសថប្រើប្រាស់ជាប់ជានិច្ចដែរឬទេ ?<br>♦ ស្រោមអនាម័យសំរាប់ចែកឱ្យអ្នកជំងឺជាប់ជានិច្ចដែរឬទេ ? |
| គុណភាពអនុវត្តការងាររបស់បុគ្គលិក (Staff performance) | - តើបុគ្គលិកប្រើប្រាស់វិធីគ្រប់គ្រងថែទាំតាមរោគបានត្រឹមត្រូវដែរឬទេ ?<br>- តើបុគ្គលិកមានធ្វើការបង្ហាញអំពីរបៀបប្រើប្រាស់ស្រោមអនាម័យដែរឬទេ ? |

| | |
|---|---|
| ចំនួនបុគ្គលិក (Staff level) | - តើមានបុគ្គលិកគ្រប់គ្រាន់សំរាប់អនុវត្តការងារថ្មីនេះដែរឬទេ ?<br>- តើមានបុគ្គលិក ប្រុស និងស្រ្តី យ៉ាងហោចណាស់ម្នាក់សំរាប់ថៃទាំអ្នកជំងឺដែរឬទេ ? |
| ការពេញចិត្តរបស់អតិថិជន (clients satisfaction) | - តើមានអ្នកជំងឺកាន់តែច្រើនមកទទួលសេវានៅគ្លីនិកដែរឬទេ ?<br>- តើមានអ្នកជំងឺប៉ុន្មានភាគរយដែលមិនបានមកពិគ្រោះជំងឺតាមការណាត់ជួបដើម្បីតាមដានការវិវត្តនៃជំងឺ ? |

គេអាចប្រមូលយកទិន្នន័យស្តីអំពី :

- មនុស្ស (ឧទាហរណ៍ : ចំនួនស្រ្តីដែលមកពិគ្រោះជំងឺនៅគ្លីនិកផែនការគ្រួសារ ហើយត្អូញត្អែរថាមានធ្លាក់ស)

- សកម្មភាព (ឧទាហរណ៍ : ចំនួនវគ្គបណ្តុះបណ្តាលដែលត្រូវបានរៀបចំឡើងសំរាប់បុគ្គលិកមណ្ឌលសុខភាព) ។

- ឬ ជាវត្ថុ (ឧទាហរណ៍ : ចំនួនស្រោមអនាម័យដែលបានផ្តល់ជូនដល់មណ្ឌលសុខភាព) ។ គេអាចប្រមូលយកទិន្នន័យទាំងនេះ ជាប់ជាប្រចាំ ឬ ក្នុងពេលកំណត់ (continuous or periodical data collection)

ពត៌មានមួយប្រភេទទៀតដែលគេអាចប្រមូលយក គឺ គុណភាពក្នុងការអនុវត្តការងាររបស់បុគ្គលិក (performance of staff) នៃកម្មវិធី (ឧទាហរណ៍ : តើបុគ្គលិកថៃទាំផ្តល់ឱសថ ឬ ដំបូន្មានដល់អ្នកជំងឺបានល្អដល់កំរិតណា ?)

អ្នកក៏អាចប្រមូលយកពត៌មានពីសេវាផ្សេងៗពីគ្នា និង ពីមន្ទីរពិសោធន៍ដែលធ្វើតេស្តរករោគវិនិច្ឆ័យជំងឺកាមរោគផងដែរ (ឧទាហរណ៍ : ដូចជាការធ្វើតេស្តជំងឺស្វាយចំពោះស្រ្តីដែលមកពិនិត្យសុខភាពមុនសំរាល) ។

យើងអាចប្រមូលយកពត៌មានមួយចំនួនអំពីការចុះបញ្ជីដែលមានតាមមណ្ឌលសុខភាព ក៏ប៉ុន្តែភាគច្រើននៃពត៌មានទាំងនោះអាចប្រមូលយកបានតាមរយៈការសង្កេត ការពិភាក្សា ឬ ការសំភាសន៍ជាមួយបុគ្គលិក ។ល។

ខាងក្រោមនេះ គឺជាប្រភេទពត៌មានដែលអ្នកអាចប្រមូលយកបានយ៉ាងងាយ ដើម្បីវាយតំលៃអំពីស្តង់ដារនៃការផ្តល់សេវាថែទាំ :

- ចំនួនអ្នកជំងឺដែលមកកាន់គ្លីនិក(បែងចែកតាមភេទ អាយុ ក្នុងមួយថ្ងៃ - សប្តាហ៍ - ខែ ។ល។)
- ចំនួនចង្កោមរោគសញ្ញាដែលបានធ្វើរោគវិនិច្ឆ័យ (ឧទាហរណ៍ : ដំបៅលើប្រដាប់បន្តពូជ ធ្លាក់ស ។ល។)
- ចំនួនស្រោមដែលបែងចែកឱ្យអ្នកជំងឺ ។ល។

សន្ទស្សន៍ (indicators) អាចបញ្ជាក់ជាចំនួនដូចជា :

- **ភាគរយ (percentage)** : ឧទាហរណ៍ 50% នៃបុរសមានអាយុពី ១៥ - ៤៩ឆ្នាំ ដែលយើងបានសាកសួរដឹងអំពីទីកន្លែងដែលអាចរកស្រោមអនាម័យប្រើប្រាស់បាន ។
- **សមាមាត្រ (proportion)** : 0.50 នៃបុរសមានអាយុពី ១៥ - ៤៩ឆ្នាំ ដែលយើងបានសាកសួរដឹងអំពីទីកន្លែងដែលអាចរកស្រោមអនាម័យប្រើប្រាស់បាន ។
- **អត្រា (Rate)** : ឧទាហរណ៍ : បុរសអាយុពី ១៥ - ៤៩ឆ្នាំ ចំនួន ៥នាក់ ក្នុងចំណោមបុរស ១០នាក់ ដែលយើងបានសាកសួរ ដឹងអំពីទីកន្លែងដែលអាចរកស្រោមអនាម័យប្រើប្រាស់បាន ។
- Ration : ឧទាហរណ៍ : Ration នៃបុរសអាយុពី១៥ - ៤៩ឆ្នាំ ដែលយើងបានសាកសួរដឹងអំពីទីកន្លែងដែលអាចរកស្រោមអនាម័យប្រើប្រាស់ ប្រៀបធៀបនឹងចំនួនបុរសដែលមិនដឹងពីទីកន្លែងរកស្រោមអនាម័យប្រើប្រាស់ គឺ 1:2 ។
- **ប្រភាគ (Fraction)** : ឧទាហរណ៍ : បុរសអាយុពី ១៥ - ៤៩ឆ្នាំ ចំនួនពាក់កណ្តាល (1/2) ដែលយើងបានសាកសួរដឹងអំពីទីកន្លែងដែលអាចរកស្រោមអនាម័យប្រើប្រាស់បាន ។

សន្ទស្សន៍ត្រូវមានលក្ខណៈជាក់លាក់ (specific) មានន័យថា វាត្រូវឆ្លុះបញ្ចាំងតែការផ្លាស់ប្តូរទាំងឡាយដែលកើតមានឡើងតែប៉ុណ្ណោះ ។

ឧទាហរណ៍ : "*នៅចុងឆ្នាំ ១៩៩៨ ៩០ភាគរយ នៃបុរសដែលកើតជំងឺរលាកបង្ហូរនោម បានទទួលការព្យាបាលសមស្រប* " គឺជាសន្ទស្សន៍ជាក់លាក់ដែលឆ្លុះបញ្ចាំងអំពីឥទ្ធិពល (impact) នៃការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាលអំពីការគ្រប់គ្រងថែទាំជំងឺកាមរោគ ។

យើងគប្បីជ្រើសរើសយកតែសន្ទស្សន៍ក្នុងចំនួនតិច ហើយអាចគ្រប់គ្រងបានតែប៉ុណ្ណោះ ហើយសន្ទស្សន៍ទាំងនោះត្រូវឆ្លុះបញ្ចាំងអំពីផ្នែកសំខាន់ៗ នៃកម្មវិធី ។

សន្ទស្សន៍អាចវាស់បាននូវផ្នែកផ្សេងៗ ជាច្រើននៃកម្មវិធី ។ ឧទាហរណ៍នៃសន្ទស្សន៍ទាំងនេះមានបង្ហាញជូននៅក្នុងតារាងខាងក្រោមនេះ :

| | |
|---|---|
| ភាពអាចរកបាន (availability) | បង្ហាញអំពីអត្ថិភាពនៃរបស់អ្វីមួយ<br>ឧទាហរណ៍ : ភាគរយនៃគ្លីនិកដែលធ្វើការចែកស្រោមអនាម័យដល់អ្នកជំងឺ ។ |
| ភាពសមស្រប (relevance) | បង្ហាញថាតើអ្វីមួយមានភាពសមស្របដល់កំរិតណា<br>ឧទាហរណ៍ : ភាគរយនៃជំងឺកាមរោគដែលបានជាសះស្បើយដោយសារ ការប្រើប្រាស់គំនូសបំព្រួញថ្មីសំរាប់ព្យាបាលជំងឺកាមរោគ។ |
| គុណភាពនៃការអនុវត្ត (performance) | បង្ហាញអំពីកំរិតអនុវត្តការងារបានល្អ ដោយប្រៀបធៀបការអនុវត្តបច្ចុប្បន្ន ទៅនឹងស្តង់ដាអនុវត្តដែលមានស្រាប់<br>ឧទាហរណ៍ : ភាគរយនៃអ្នកជំងឺដែលទទួលបាននូវការគ្រប់គ្រងថែទាំត្រឹមត្រូវនៅតាមគ្លីនិកនានា ។ |
| Accessibility | បង្ហាញអំពីអ្វីមួយដែលអាចឱ្យអ្នកដែលត្រូវការវាអាចទទួលយកបាន<br>ឧទាហរណ៍ : ភាគរយនៃមនុស្សអាយុពី ១៥ ដល់ ៤៩ឆ្នាំអាចរកបាននូវស្រោមអនាម័យសំរាប់ប្រើប្រាស់ ។ |

| | |
|---|---|
| ការប្រើប្រាស់ (use) | បង្ហាញពីកិរិតអ្វីមួយដែលមានសំរាប់ប្រើប្រាស់ និងត្រូវបានគេប្រើប្រាស់ក្នុងបំណងណាមួយ ។<br>ឧទាហរណ៍ : អត្រានៃយុវជនជំទង់អាយុលើ ១៣ ដល់ ១៨ឆ្នាំ ដែលប្រើប្រាស់ស្រោមអនាម័យក្នុងពេលរួមភេទជាមួយដៃគូរួមភេទដែលជួបដោយចៃដន្យ ។ |
| ចំណេះដឹង (knowledge) | ឧទាហរណ៍ : ភាគរយនៃប្រជាជនដែលមានអាយុពី ១៥ ដល់ ៤៩ឆ្នាំ ដែលអាចបង្ហាញកន្លែងផ្តល់សេវាថែទាំកាមរោគ ។ |
| ការគ្របដណ្តប់ (coverage) | បង្ហាញពីសមាមាត្រនៃអ្នកដែលត្រូវការសេវាអ្វីមួយនិង អាចទទួលបានសេវានោះ<br>ឧទាហរណ៍ : ភាគរយអ្នកជំងឺកាមរោគដែលទទួលការព្យាបាលនៅតាមបណ្តាគ្លីនិកនានា ។ |
| ផល / ឥទ្ធិពល (impact) | បង្ហាញពីអ្វីដែលមានការផ្លាស់ប្តូរដែលកើតឡើងក្រោយពេលដែលយើងបានធ្វើសកម្មភាព<br>ឧទាហរណ៍ : ការប្រែប្រួលក្នុងការប្រើប្រាស់ស្រោមអនាម័យចំនួន ...ភាគរយ ក្នុងចំណោមបុរសដែលមានការរួមភេទប្រឈមមុខនឹងគ្រោះថ្នាក់ខ្ពស់ ។ |
| គុណភាព (Quality) | បង្ហាញអំពីកិរិតល្អរបស់អ្វីមួយដែលយើងបានធ្វើកន្លងមក :<br>ឧទាហរណ៍ : ភាគរយនៃអ្នកជំងឺកាមរោគដែលបានទទួលការគ្រប់គ្រងថែទាំត្រឹមត្រូវនៅតាមបណ្តាគ្លីនិក ។ |

នៅពេលដែលអ្នកជ្រើសរើសយកផ្នែកផ្សេងៗមកវាយតំលៃ ជាការចាំបាច់ត្រូវកំណត់អំពីកិរិតដែលអ្នកចង់សំរេចបាននៅក្នុងកំឡុងពេលមួយកំណត់ បានសេចក្តីថា អ្នកត្រូវសំរេចចិត្តលើទិសដៅ (target) របស់អ្នក ។

ទិសដៅសំរាប់សមិទ្ធិផល (outputs) និងសន្ទស្សន៍ (indicator) ត្រូវមានលក្ខណៈប្រាដកនិយម និងអាចសំរេចបាន បើពុំនោះសោតវានឹងធ្វើឱ្យអ្នកគ្រប់គ្រង និងបុគ្គលិកនៃកម្មវិធីនឹងអស់សង្ឃឹមជាមិនខាន ។

ឧទាហរណ៍ ៖ ទិសដៅដែលចែងថា “ *នៅចុងឆ្នាំដំបូងនៃគំរោងសាកល្បងនឹងមានបុរសដែលមានការហូរខ្ទុះតាមបង្ហូរនោមចំនួនតែ ៥០ភាគរយប៉ុណ្ណោះ ដែលទទួលបាននូវការថែទាំត្រឹមត្រូវ* ” មានលក្ខណៈទាបបន្តិច ។ ក៏ប៉ុន្តែនៅក្នុងឆ្នាំដំបូងនៃគំរោងនៅពេលដែលយើងតំរូវឱ្យបុគ្គលិកធ្វើការថែទាំជំងឺថ្មី ដោយប្រើនូវការថែទាំថ្មីនោះ បុគ្គលិកចាត់ទុកថាកម្មវត្ថុនេះមានលក្ខណៈសមស្រប (ប្រាកដនិយម) ហើយអាចសំរេចបាន ។ នៅពេលដែលគំរោងឈានចូលមកដល់ឆ្នាំទី ២ បុគ្គលិកនឹងកាន់តែមានទំលាប់ប្រើនូវវិធីថែទាំថ្មីនេះ ដូច្នេះយើងអាចបង្កើតគោលបំនងសំរាប់ឆ្នាំទី ២ បានដូចតទៅ “*៨០ ភាគរយនៃបុរសដែលកើតជំងឺហូរខ្ទុះតាមបង្ហូរនោមនឹងត្រូវទទួលការថែទាំត្រឹមត្រូវ ហើយបានទទួលការអប់រំអំពីការប្រើប្រាស់ស្រោមអនាម័យ* ” ។

**សេចក្តីសន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ និងការវាយតំលៃពុំមែនជាការងារមួយស្រួលទេ ប៉ុន្តែវាជាការងារដែលមានសារៈសំខាន់ ។ ទោះបីជាមានការលំបាកក្នុងការប្រមូលយក នឹងបកស្រាយនូវពត៌មានដែលត្រូវកំដោយ ក៏ពត៌មានទាំងនោះមានសារៈសំខាន់ជាសារវន្តផងដែរ ។ អ្នកអាចធ្វើការកែលំអកម្មវិធីបានដោយសារការផ្តល់ពត៌មាន ដែលបានមកពីការតាមដាន ត្រួតពិនិត្យ និងវាយតំលៃ ។

## លំហាត់ ៧.២

<u>ក្រុមពិភាក្សាតាមក្រុម</u> ៖

- សូមពិចារណាររកពត៌មានដែលអ្នកគប្បីប្រមូលយកក្នុងរយៈពេល ១ ឆ្នាំដំបូងនៃគំរោងសាកល្បងពង្រីកសេវាថែទាំជំងឺកាមរោគ
- សូមបញ្ជាក់អំពីវិធីដែលត្រូវប្រមូលយកពត៌មានទាំងនោះ
- ចំនួនដងដែលអ្នកត្រូវប្រមូលយកវា
- និងមូលហេតុដែលនាំឱ្យអ្នកប្រមូលយក ពត៌មានទាំងនេះ

## ៧.៣ .ការគ្រប់គ្រងការងារ ( Operational Management )

គោលបំណងរបស់អ្នកគឺត្រូវសំរេចឱ្យបាននូវការបញ្ចូលសេវាថែទាំកាមរោគ ទៅក្នុងសេវាថែទាំដ៏ទៃៗ ទៀត ( integrated STD service ) ដែល :

- ផ្នែកផ្សេងៗនៃកម្មវិធី ( គ្លីនិកឯកទេស មណ្ឌលសុខភាព។ល។ ) ត្រូវផ្តល់នូវការថែទាំជំងឺកាមរោគ ដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ហើយសមស្របទៅតាមជំនាញរបស់ខ្លួន
- ផ្នែកទាំងនោះត្រូវមានទំនាក់ទំនងល្អជាមួយគ្នាយ៉ាងជិតស្និទ
- មានការសំរបសំរួលការងាររបស់កម្មវិធីដែលត្រូវបានបញ្ចូលគ្នានោះ ។

**សមាសភាគមួយចំនួននៃការគ្រប់គ្រងការងារ**

- **របៀបគ្រប់គ្រង (Management style)**
  - autocratic /participatory
  - បែបចាស់ (traditional) / បែបថ្មី (innovative )
  - Centralized / decentralized
- **បែបបទរដ្ឋបាល ( Administrative procedures )**
- **ការចុះអភិបាលការងារ (supervision)**
- **ការបង្កើនសមត្ថភាពបុគ្គលិក (staff development)**
- **ការផ្គត់ផ្គង់សំភារៈនិងបរិក្ខារ**

ឧទាហរណ៍ : ការគ្រប់គ្រងឱសថ “ដោយវាយតំលៃតំរូវការ ការជ្រើសរើសមុខឱសថ ការទិញ ការរក្សាទុក ការបែងចែក និងការស្វែងរកមូលនិធិសំរាប់ឱសថ ”

**ការស្វែងរកថវិកា (Fund raising )**

- ពត៌មានសំរាប់ការគ្រប់គ្រង ( Management information )
- ទំនាក់ទំនងជាមួយស្ថាប័ននានា ( Public relation )
- ទំនាក់ទំនងជាមួយកម្មវិធីនិងអង្គការផ្សេងៗទៀត
  - ផ្នែកគាំពារមាតានិងទារក
  - កម្មវិធីប្រយុទ្ធនឹងជំងឺរបេង
  - កម្មវិធីពន្យាកំណើត
  - ក្រសួងអប់រំ - ក្រសួងការពារជាតិ ...
  - ម្ចាស់ជំនួយ - ភ្នាក់ងារនានានៃអង្គការសហប្រជាជាតិ ។ ល ។

**លំហាត់ ៧ .៣**

ការពិភាក្សាក្រុមធំ

- សូមពិនិត្យមើលផ្នែកសំខាន់នានានៃការផ្គត់ផ្គង់ឱសថ ហើយពិភាក្សាអំពីដំណាក់កាលអនុវត្តនានារបស់វា ។
- តើយើងកំពុងជួបបញ្ហាអ្វីខ្លះ ?
- តើគួរកែលំអរបញ្ហាទាំងនោះយ៉ាងដូចម្តេច ?